2/47. عَنْ مُحَمَّدِ بْنِ عَلِيٍّ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، قَالَ: سَأَلْتُهُ عَنْ قَوْلِهِ تَعَالَى: ﴿يَا بَنِي إِسْرَائِيلَ﴾. قَالَ: «هِيَ خَاصَّةٌ بِآلِ مُحَمَّدٍ». (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢١٠ الحديث: ٩٩/ ٤٦٧، تفسير العيّاشي – الجزء: ١ الصفحة: ٤٤ الحديث : ٤٤)**

៤៧/២. រាយការណ៍ដោយ មូហ្ម៉ាម៉ាដ្ធ ប៊ិន អ៊ីលី តមកពី អាប៊ូ អ៊ីប់ឌុលឡោះហ្ស៊ីﷺ ថាខ្ញុំបានសួរព្រះអង្គﷺអំពីព្រះបន្ទូលអល់ឡោះហ្ស៊ីﷻ *[២:៤៧] កូនចៅអ៊ីសរ៉ាអ៊ីលអើយ !* ព្រះអង្គﷺមានវចនៈថា៖ "នេះគឺព្រះរាជបុត្ររាជនត្តាﷺរបស់មូហ្ម៉ាម៉ាដ្ធﷺជាពិសេស ។" (تفسير العيّاشي 1: 44/ 44)

***

3/47. عَنْ أَبِي دَاوُدَ، عَمَّنْ سَمِعَ رَسُولَ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) يَقُولُ: «أَنَا عَبْدُ اللَّهِ اسْمِي أَحْمَدُ، وَ أَنَا عَبْدُ اللَّهِ اسْمِي إِسْرَائِيلُ، فَمَا أَمَرَهُ فَقَدْ أَمَرَنِي، وَ مَا عَنَاهُ فَقَدْ عَنَانِي». (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢١٠ الحديث: ٩٩/ ٤٦٧، تفسير العيّاشي – الجزء: ١ الصفحة: ٤٤ الحديث : ٤٥)**

៤៧/៣. រាយការណ៍ដោយ អាប៊ូ ដ្ធាវុដ្ធ តមកពីបុរសម្នាក់ដែលបានឮរ៉ាស៊ូលុលឡោះហ្ស៊ីﷺមានព្រះវចនៈថា៖ "ខ្ញុំﷺជាបាវបម្រើម្នាក់របស់អល់ឡោះហ្ស៊ីﷻ ឈ្មោះរបស់ខ្ញុំﷺគឺអាស្ម៉ាម៉ាដ្ធﷺ ។ ខ្ញុំﷺជាបាវបម្រើម្នាក់របស់អល់ឡោះហ្ស៊ីﷻ ឈ្មោះរបស់ខ្ញុំﷺគឺអ៊ីសរ៉ាអ៊ីលﷺ ។ ដូច្នេះអ្វីក៏ដោយដែលព្រះអង្គﷻបញ្ជា ព្រះអង្គﷻបញ្ជាវាមកលើរូបខ្ញុំﷺ ។ អ្វីក៏ដោយដែលព្រះអង្គﷻចង់និយាយដល់ ព្រះអង្គﷻចង់និយាយដល់មកខ្ញុំﷺ" (تفسير العيّاشي 1: 45/44)

وَٱتَّقُواْ يَوۡمٗا لَّا تَجۡزِي نَفۡسٌ عَن نَّفۡسٖ شَيۡـٔٗا وَلَا يُقۡبَلُ مِنۡهَا شَفَٰعَةٞ وَلَا يُؤۡخَذُ مِنۡهَا عَدۡلٞ وَلَا هُمۡ يُنصَرُونَ ٤٨

៤៨. ពួកអ្នកចូរកោតខ្លាចថ្ងៃមួយដែលពុំមានអ្នកណាមួយគ្រប់គ្រាន់សម្រាប់អ្នកណាមួយឡើយ ។ ការជួយធ្វើអន្តរាគមន៍នឹងពុំត្រូវទទួលយកពីអ្នកណាមួយឡើយ ។ ការលោះខ្លួននឹងពុំត្រូវទទួលយកពីអ្នកណាមួយឡើយ ។ ពួកគេនឹងពុំត្រូវជួយសង្គ្រោះឡើយ ។

អធិប្បាយអាយ៉ាស់ ៤៨

1/48. ثُمَّ قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿وَ اِتَّقُوا يَوْماً لاٰ تَجْزِي نَفْسٌ عَنْ نَفْسٍ شَيْئاً﴾ لاَ تَدْفَعُ عَنْهَا عَذَاباً قَدِ اِسْتَحَقَّتْهُ عِنْدَ اَلنَّزْعِ. ﴿وَ لاٰ يُقْبَلُ مِنْهٰا شَفٰاعَةٌ﴾ يَشْفَعُ لَهَا بِتَأْخِيرِ اَلْمَوْتِ عَنْهَا. ﴿وَ لاٰ يُؤْخَذُ مِنْهٰا عَدْلٌ﴾ لاَ يُقْبَلُ [مِنْهَا] فِدَاءٌ [بِمَكَانِهِ] مَكَانَهُ يُمَاتُ وَ يُتْرَكُ هُوَ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 241)

៤៨/១. បន្ទាប់មកអល់ឡោះហ្ស៊ីﷻមានព្រះរាជបន្ទូលថា៖ *[២:៤៨] ពួកអ្នកចូរកោតខ្លាចថ្ងៃមួយដែលពុំមានអ្នកណាមួយគ្រប់គ្រាន់សម្រាប់អ្នកណាមួយឡើយ* នឹងមិនអាចគេចខ្លួនរួចបានឡើយពីទណ្ឌកម្មដែលអ្នកនោះត្រូវទទួលនៅពេលស្លាប់ *ការជួយធ្វើអន្តរាគមន៍នឹងពុំត្រូវទទួលយកពីអ្នកណាមួយឡើយ* ការជួយសូមឲ្យពន្យារពេលឲ្យអ្នកនោះ *ការលោះខ្លួននឹងពុំត្រូវទទួលយកពីអ្នកណាមួយឡើយ* ការលោះខ្លួនឬការផ្លាស់ជួសអ្នកដែលស្លាប់នឹងពុំត្រូវទទួលយកទេ មានតែខ្លួនអ្នកនោះទេដែលនឹងត្រូវនៅតែឯង ។" (التفسير المنسوب إلى الإمام العسكري عليه السلام 1: 241)

***

2/48. فِي تَفْسِيرِ عَلِيِّ بْنِ إِبْرَاهِيمَ: قَوْلُهُ: ﴿وَ اِتَّقُوا يَوْماً لاٰ تَجْزِي نَفْسٌ عَنْ نَفْسٍ شَيْئاً وَ لاٰ يُقْبَلُ مِنْهٰا شَفٰاعَةٌ﴾ وَ هُوَ قَوْلُهُ عَلَيْهِ السَّلاَمُ، وَ اَللَّهِ لَوْ أَنَّ كُلَّ مَلَكٍ مُقَرَّبٍ وَ كُلَّ نَبِيٍّ مُرْسَلٍ شَفَعُوا فِي نَاصِبٍ مَا شَفَعُوا. (تفسير نور الثقلين , ج 1 , ص 77)

៤៨/២. នៅក្នុងតាហ្វ៊សៀររបស់ អាលី ប៊ិន អ៊ីបរ៉ហ៊ីម ស្តីអំពីព្រះបន្ទូលអល់ឡោះហ្ញ៉ *[២:៤៨] ពួកអ្នកចូរកោតខ្លាចថ្ងៃមួយដែលពុំមានអ្នកណាមួយគ្រប់គ្រាន់សម្រាប់អ្នកណាមួយឡើយ ។ ការជួយធ្វើអន្តរាគមន៍នឹងពុំត្រូវទទួលយកពីអ្នកណាមួយឡើយ ។ ការលោះខ្លួននឹងពុំត្រូវទទួលយកពីអ្នកណាមួយឡើយ ។* អ៊ីម៉ាំ ﷺមានវចនៈថា៖ "សូមស្បថនឹងអល់ឡោះហ្ញ៉! ទោះបីទេវតាជំនិតទាំងអស់និងព្រះសាស្តាប្រេសិតﷺជួយសូមទោសឲ្យអ្នកប្រទូសប្រឆាំង (ពួកណាស៊្ហីប៊ី) ក៏ដោយ ក៏គេនឹងមិនព្រមទទួលយកការជួយធ្វើអន្តរាគម៍នោះទេ ។" (تفسير نور الثقلين 1: 77)

***

3/48. قَالَ اَلصَّادِقُ عَلَيْهِ السَّلاَمُ: وَ هَذَا [اَلْيَوْمُ] يَوْمُ اَلْمَوْتِ، فَإِنَّ اَلشَّفَاعَةَ وَ اَلْفِدَاءَ لاَ يُغْنِي عَنْهُ. فَأَمَّا فِي اَلْقِيَامَةِ، فَإِنَّا وَ أَهْلَنَا نَجْزِي عَنْ شِيعَتِنَا كُلَّ جَزَاءٍ، لَيَكُونَنَّ عَلَى اَلْأَعْرَافِ بَيْنَ اَلْجَنَّةِ وَ اَلنَّارِ « مُحَمَّدٌ وَ عَلِيٌّ وَ فَاطِمَةُ وَ اَلْحَسَنُ وَ اَلْحُسَيْنُ عَلَيْهِمُ السَّلاَمُ وَ اَلطَّيِّبُونَ مِنْ آلِهِمْ»

៤៨/៣. [ព្រះបរមអ៊ីម៉ាំ] អាល់-ស្វ៊ឌិក្ញﷺមានព្រះវចនៈថា៖ *"ថ្ងៃ* នេះ (ក្នុងអាយ៉ាត់ខាងលើ) ជាថ្ងៃស្លាប់ ។ ក្នុងថ្ងៃនេះការជួយធ្វើអន្តរាគមន៍ ការលោះ ប្តូរផ្លាស់ (ឲ្យរួចពីការស្លាប់) ពុំមានប្រយោជន៍ទេ ។ តែចំណែកឯថ្ងៃជំនុំជម្រះនោះវិញ យើងﷺនិងព្រះរាជកុលដ្ឋានﷺយើងﷺ នឹងឲ្យរង្វាន់ស៊្ហីអាត់យើងនូវរង្វាន់ទាំងអស់របស់ពួកគេ ។ មូហាំម៉ាដ្ញ ﷺ អាលីﷺ ហ្វាទីម៉ាត់ﷺ អាល់-ហាសាន់ﷺ អាល់-ហ៊ូសៃន៍ﷺ និងបណ្តាកូនចៅﷺល្អរបស់អស់ព្រះអង្គﷺនឹងស្ថិតនៅលើទីខ្ពស់ (អាល់-អាក់រ៉ហ្វ) ត្រង់ចន្លោះឋានសួគ៌និងឋាននរក ។

فَنَرَى بَعْضَ شِيعَتِنَا فِي تِلْكَ اَلْعَرَصَاتِ مِمَّنْ كَانَ مِنْهُمْ مُقَصِّراً فِي بَعْضِ شَدَائِدِهَا فَنَبْعَثُ عَلَيْهِمْ خِيَارَ شِيعَتِنَا كَسَلْمَانَ وَ اَلْمِقْدَادِ وَ أَبِي ذَرٍّ وَ عَمَّارٍ وَ نَظَائِرِهِمْ فِي اَلْعَصْرِ اَلَّذِي يَلِيهِمْ، ثُمَّ فِي كُلِّ عَصْرٍ إِلَى يَوْمِ اَلْقِيَامَةِ، فَيَنْقَضُّونَ عَلَيْهِمْ كَالْبُزَاةِ وَ اَلصُّقُورِ وَ يَتَنَاوَلُونَهُمْ كَمَا تَتَنَاوَلُ اَلْبُزَاةُ وَ اَلصُّقُورُ صَيْدَهَا، فَيَزِفُّونَهُمْ إِلَى اَلْجَنَّةِ زَفّاً.

យើងﷺនឹងឃើញស៊្ហីអាត់យើងមួយចំនួន នៅឯវាលនេះ ដែលជាជនដែលខ្វះការយកចិត្តទុកដាក់ជួបប្រទះការលំបាក ។ យើងﷺនឹងចាត់បញ្ជូនទៅរកពួកគេនូវស៊្ហីអាត់ល្អរបស់យើងដូចជា សាល់ម៉ានﷺ, មីក្ទដ្ញាដ្ញﷺ, អាប៊ូ-ស្ហារ, អាំម៉ារﷺ និងបណ្តាអ្នកដូចពួកគេﷺនៃសម័យកាលក្រោយពួកគេﷺនិងគ្រប់សម័យកាលរហូតដល់ថ្ងៃជំនុំជម្រះ ។ ពួកគេﷺនឹងឆក់យកពួកគេទាំងនោះចេញពីស្ថានភាពនេះដូចស្ទាំងនិងឥន្ទ្រីឆក់យករំពា នាំពួកគេទៅឯឋានសួគ៌យ៉ាងរហ័ស ។

وَ إِنَّا لَنَبْعَثُ عَلَى آخَرِينَ مِنْ مُحِبِّينَا مِنْ خِيَارِ شِيعَتِنَا كَالْحَمَامِ فَيَلْتَقِطُونَهُمْ مِنَ اَلْعَرَصَاتِ كَمَا يَلْتَقِطُ اَلطَّيْرُ اَلْحَبَّ، وَ يَنْقُلُونَهُمْ إِلَى اَلْجِنَانِ بِحَضْرَتِنَا.

យើងﷺនឹងចាត់បញ្ជូនទៅរកបណ្តាអ្នកដែលស្រឡាញ់យើងﷺ នូវស៊្ហីអាត់ប្រសើរជាច់គេរបស់យើងﷺដូចសត្វព្រាប ។ ពួកគេនឹងចាប់យកពួកគេពីក្នុងវាលដូចសត្វស្លាបចាប់យកគ្រប់សត្រូវ នាំពួកគេមកជួបយើងﷺនៅឯឋានសួគ៌

وَ سَيُؤْتَى بِالْوَاحِدِ مِنْ مُقَصِّرِي شِيعَتِنَا فِي أَعْمَالِهِ، بَعْدَ أَنْ قَدْ حَازَ الْوَلاَيَةَ وَ التَّقِيَّةَ وَ حُقُوقَ إِخْوَانِهِ، وَ يُوقَفُ بِإِزَائِهِ مَا بَيْنَ مِائَةٍ وَ أَكْثَرَ مِنْ ذَلِكَ إِلَى مِائَةِ أَلْفٍ مِنَ النُّصَّابِ فَيُقَالُ لَهُ: هَؤُلاَءِ فِدَاؤُكَ مِنَ النَّارِ. فَيَدْخُلُ هَؤُلاَءِ الْمُؤْمِنُونَ الْجَنَّةَ، وَ أُولَئِكَ النُّصَّابُ النَّارَ.

ចំណែកឯស្ទីអ្ទ្ធ៉ាស៊ុំយើងណាមួយដែលទន់ខ្សោយក្នុងទង្វើ ក្រោយពីបានវីឡាយ៉ាស៊ុំយើងហើយ បានអនុវត្តការលាក់ចាំង (តាគ្ទីយ៉ាស៊ុ) និងបានគោរពសិទ្ធិបងប្អូនខ្លួនហើយ ។ គេនឹងនាំអ្នកនោះទៅដាក់នៅពីមុខពួកណាស្ទ្ធ៉ីបី (ពួកប្រឆាំង) ដែលមានចំនួនវាងមួយរយឬលើសពីនោះដល់ទៅមួយរយពាន់នាក់ ។ គេនឹងប្រាប់អ្នកនោះថា៖ "ពួកគេទាំងនេះជាបន្ទាស់របស់អស់លោកពីភ្លើងនរក (ជាអ្នកដែលគេយកមកដូរនឹងស្ទ្ធ៉ីអ្ទ្ធ៉ាស៊ុំខ្សោយទង្វើនោះ) ។ ដូច្នេះបណ្តាអ្នកមានសទ្ធាជ្រះថ្លាមុមីនីនទាំងនេះ នឹងបានចូលឋានសួគ៌ ឯពួកប្រទូសប្រឆាំងទាំងនេះ (ណាស្ទ្ធ៉ីបី) នឹងចូលឋាននរក ។

وَ ذَلِكَ مَا قَالَ اللَّهُ عَزَّ وَ جَلَّ: ﴿رُبَمَا يَوَدُّ الَّذِينَ كَفَرُوا﴾ يَعْنِي بِالْوَلاَيَةِ ﴿لَوْ كَانُوا مُسْلِمِينَ﴾ فِي الدُّنْيَا مُنْقَادِينَ لِلْإِمَامَةِ، لِيُجْعَلَ مُخَالِفُوهُمْ فِدَاءَهُمْ مِنَ النَّارِ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 241)

នោះគឺអ្វីដែលអល់ឡោះហ្ស៊ីជ្ជ៉ាមានព្រះរាជបន្ទូលថា៖ *[១៥:២] ជួនកាលពួកបដិសេធសទ្ធា* ពោលគឺបដិសេធសទ្ធាវីឡាយ៉ាស៊ុ *ចង់ទៅជាអ្នកចុះចូល* ក្នុងលោកនេះទៅរកអ៊ីម៉ាម៉ាស៊ុ ដើម្បីនឹងបានលោះខ្លួនពួកគេពីភ្លើងនរកនឹងខ្លួនសត្ត្រូវពួកគេ ។" (التفسير المنسوب إلى الإمام العسكري عليه السلام 1: 241)

وَإِذْ نَجَّيْنَٰكُم مِّنْ ءَالِ فِرْعَوْنَ يَسُومُونَكُمْ سُوٓءَ ٱلْعَذَابِ يُذَبِّحُونَ أَبْنَآءَكُمْ وَيَسْتَحْيُونَ نِسَآءَكُمْ ۚ وَفِى ذَٰلِكُم بَلَآءٌ مِّن رَّبِّكُمْ عَظِيمٌ ﴿٤٩﴾

៤៩. [ចូរនឹកឃើញ]កាលយើងបានរំដោះពួកអ្នកពីប្រជាជាតិហ្ទ្ធ៉ារអ្ទ្ធ៉ន ដែលបានប្រព្រឹត្តលើពួកអ្នកនូវទារុណកម្មអប្រិយ ដោយសម្លាប់បណ្តាកូនប្រុសរបស់ពួកអ្នក ទុកជីវិតឲ្យបណ្តាស្ត្រីរបស់ពួកអ្នក ។ ត្រង់នេះឯងដែលពួកអ្នកនៅក្នុងការល្បងពិសោធន៍ដ៏ធ្ងន់ពីម្ចាស់ពួកអ្នក ។

អធិប្បាយអាយ៉ាស៊ុ ៤៩

1/49. قَالَ الْإِمَامُ عَلَيْهِ السَّلاَمُ: قَالَ تَعَالَى: وَ اذْكُرُوا يَا بَنِي إِسْرَائِيلَ ﴿إِذْ نَجَّيْنَاكُمْ﴾ أَنْجَيْنَا أَسْلاَفَكُمْ ﴿مِنْ آلِ فِرْعَوْنَ﴾ وَ هُمُ الَّذِينَ كَانُوا يَدْنُونَ إِلَيْهِ بِقَرَابَتِهِ وَ بِدِينِهِ وَ مَذْهَبِهِ ﴿سُومُونَكُمْ﴾ كَانُوا يُعَذِّبُونَكُمْ ﴿سُوءَ الْعَذَابِ﴾ شِدَّةَ الْعَذَابِ كَانُوا يَحْمِلُونَهُ عَلَيْكُمْ.

៤៩/១. អ៊ីមុាំ[صلوات الله عليه والسلام] [អាល់-ហ្ជាសាន់ អាល់-អ្ទ្ធ៉ាស់ការ៉ី] មានថវន:ថា៖ "អល់ឡោះហ្ស៊ីតាឡាមានព្រះរាជបន្ទូលថា៖ "ចូរនឹកឃើញ កូនចៅអ៊ីសរ៉ាអ៊ីលអឺយ ! *[២:៤៩] កាលយើងបានរំដោះពួកអ្នក* គឺជួយសង្គ្រោះជួនតាពួកអ្នក *ពីប្រជាជាតិហ្ទ្ធ៉ារអ្ទ្ធ៉ន* ពួកដែលទៅជ្រកក្រោមបារមីរបស់ហ្ទ្ធ៉ារអ្ទ្ធ៉ន ជាជំនិតរបស់វា[لعن الله] នៅក្នុងសាសនារបស់វា[لعن الله] នៅក្នុងនិកាយរបស់វា[لعن الله] *ដែលបានធ្វើមកលើពួកអ្នក* ធ្វើទណ្ឌកម្មពួកអ្នកដោយ *ទារុណកម្មអប្រិយ* ដាក់ទណ្ឌកម្មធ្ងន់លើពួកអ្នក ។"

قَالَ: وَ كَانَ مِنْ عَذَابِهِمُ الشَّدِيدِ أَنَّهُ كَانَ فِرْعَوْنُ يُكَلِّفُهُمْ عَمَلَ الْبِنَاءِ وَ الطِّينِ وَ يُخَافُ أَنْ يَهْرُبُوا عَنِ الْعَمَلِ، فَأَمَرَ بِتَقْيِيدِهِمْ فَكَانُوا يَنْقُلُونَ ذَلِكَ الطِّينَ عَلَى السَّلاَلِيمِ إِلَى السُّطُوحِ، فَرُبَّمَا سَقَطَ الْوَاحِدُ مِنْهُمْ فَمَاتَ أَوْ زَمِنَ وَ لاَ يَحْفِلُونَ بِهِمْ إِلَى أَنْ أَوْحَى اللَّهُ عَزَّ وَ جَلَّ إِلَى مُوسَى عَلَيْهِ السَّلاَمُ: قُلْ لَهُمْ: لاَ يَبْتَدِءُونَ عَمَلاً إِلاَّ بِالصَّلاَةِ عَلَى مُحَمَّدٍ وَ آلِهِ الطَّيِّبِينَ لِيَخِفَّ عَلَيْهِمْ. فَكَانُوا يَفْعَلُونَ ذَلِكَ، فَيَخِفُّ عَلَيْهِمْ.

ព្រះអង្គ صلوات الله عليه وسلامه មានចវនៈថា៖ "ទណ្ឌកម្មធ្ងន់ទាំងនោះគឺ ហ្ចៀរអ៊ុ៌ន رضي الله عنه បានបង្ខំឲ្យពួកគេធ្វើការសាងសង់ និងធ្វើការក្នុងភក់ (គឺធ្វើឥដ្ឋយកមកធ្វើសំណង់) ។ វា رضي الله عنه ខ្លាចពួកគេរត់គេចពីការ ដូច្នេះវា رضي الله عنه ដាក់បញ្ជាឲ្យគេ ឃុំឃាំងពួកគេ ។ ពួកគេជញ្ជូនភក់ទៅដាក់លើពិតានសំណង់ ។ ជួនកាលមានពួកគេម្នាក់ធ្លាក់ស្លាប់ឬ ពិការ ពួកគេមិនយកចិត្តទុកដាក់រំលែកទុក្ខទេ ទាល់តែអល់ឡោះ ﷻ បានបើកឲ្យមូសា عليه السلام ដឹងថា៖ "អ្នក عليه السلام ចូរប្រាប់ពួកគេឲ្យឧទ្ទិសព្រះពរ[ស្ង៊ីឡាវ៉ាត]ឆ្ពោះទៅមូហ្ចាំម៉ាដ្ធ៉ូ صلى الله عليه وآله وسلم និងបណ្ដាកូនចៅ عليهم السلام ល្អ របស់គេ صلى الله عليه وآله وسلم មុនចាប់ផ្ដើមធ្វើការ វានឹងងាយស្រួលដល់ពួកគេ ។" ពួកគេក៏បានធ្វើដូចនេះ ការងារក៏បាន ងាយស្រួលសម្រាប់ពួកគេ ។

وَ أَمَرَ كُلَّ مَنْ سَقَطَ وَ زَمِنَ مِمَّنْ نَسِيَ اَلصَّلاَةَ عَلَى مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ أَنْ يَقُولَهَا عَلَى نَفْسِهِ إِنْ أَمْكَنَهُ أَيِ اَلصَّلاَةَ عَلَى مُحَمَّدٍ وَ آلِهِ أَوْ يُقَالَ عَلَيْهِ إِنْ لَمْ يُمْكِنْهُ، فَإِنَّهُ يَقُومُ وَ لاَ يَضُرُّهُ ذَلِكَ فَفَعَلُوهَا فَسَلِمُوا.

"អ្នក عليه السلام ចូរប្រាប់បណ្ដាអ្នកដែលធ្លាក់ហើយទៅជាពិការនោះ ដែលភ្លេចសូត្រឧទ្ទិសព្រះពរឆ្ពោះទៅ មូហ្ចាំម៉ាដ្ធ៉ូ صلى الله عليه وآله وسلم និងបណ្ដាកូនចៅ عليهم السلام ល្អរបស់មូហ្ចាំម៉ាដ្ធ៉ូ صلى الله عليه وآله وسلم ឲ្យពួកគេត្រឧទ្ទិសព្រះពរនេះលើខ្លួនឯង បើ អាចធ្វើបាន ពោលគឺសូត្រស្ង៊ីឡាវ៉ាតឧទ្ទិសឲ្យទៅមូហ្ចាំម៉ាដ្ធ៉ូ صلى الله عليه وآله وسلم និងបណ្ដាកូនចៅ عليهم السلام ល្អរបស់មូហ្ចាំម៉ាដ្ធ៉ូ صلى الله عليه وآله وسلم ។ បើមិនអាចធ្វើបានទេ ចូរពឹងគេឲ្យសូត្រឲ្យខ្លួនអ្នកនោះ អ្នកនោះឈរបាន (នឹងមានកម្លាំងធ្វើការ) ការធ្លាក់នោះនឹងមិនធ្វើឲ្យអ្នកនោះរងគ្រោះទេ ។ ពួកគេក៏បានធ្វើដូចនេះ បានរួចផុតពីគ្រោះថ្នាក់ ។

﴿يُذَبِّحُونَ أَبْنَاءَكُمْ﴾ وَ ذَلِكَ لَمَّا قِيلَ لِفِرْعَوْنَ: أَنَّهُ يُولَدُ فِي بَنِي إِسْرَائِيلَ مَوْلُودٌ يَكُونُ عَلَى يَدِهِ هَلاَكُكَ، وَ زَوَالُ مُلْكِكَ. فَأَمَرَ بِذَبْحِ أَبْنَائِهِمْ،

ដោយសម្លាប់បណ្ដាកូនប្រុសរបស់ពួកអ្នក នេះបណ្ដាលមកពីគេបានប្រាប់ហ្ចៀរអ៊ុ៌ន رضي الله عنه ថា៖ "នឹងមាន ទារកមួយចាប់កំណើតពីពួកកូនចៅអ៊ីសរ៉ាអ៊ីល ។ កូននេះនឹងធ្វើឲ្យព្រះអង្គ رضي الله عنه វិនាសសាបសូន្យ អំណាច ព្រះអង្គ رضي الله عنه និងដុនដាប ។" ដូច្នេះវា رضي الله عنه បានបញ្ជាឲ្យសម្លាប់កូនប្រុសៗពួកគេ ។

فَكَانَتِ اَلْوَاحِدَةُ [مِنْهُنَّ] تُصَانِعُ اَلْقَوَابِلَ عَنْ نَفْسِهَا لِئَلاَّ يَتِمَّ عَلَيْهَا [وَ يَتِمَّ] حَمْلُهَا، ثُمَّ تُلْقِي وَلَدَهَا فِي صَحْرَاءَ، أَوْ غَارِ جَبَلٍ، أَوْ مَكَانٍ غَامِضٍ وَ تَقُولُ عَلَيْهِ عَشْرَ مَرَّاتٍ اَلصَّلاَةُ عَلَى مُحَمَّدٍ وَ آلِهِ، فَيُقَيِّضُ اَللَّهُ [لَهُ] مَلَكاً يُرَبِّيهِ، وَ يُدِرُّ مِنْ إِصْبَعٍ لَهُ لَبَناً يَمُصُّهُ، وَ مِنْ إِصْبَعٍ طَعَاماً [لَيِّناً] يَتَغَذَّاهُ إِلَى أَنْ نَشَأَ بَنُو إِسْرَائِيلَ وَ كَانَ مَنْ سَلِمَ مِنْهُمْ وَ نَشَأَ أَكْثَرَ مِمَّنْ قُتِلَ.

ស្រីៗតែងតែសូកឆ្ងបដើម្បីជួយលាក់ការមានផ្ទៃពោះនោះលុះដល់ពេលសម្រាលកូន ។ ពេលសម្រាល កូន ពួកនាងលាក់កូនក្នុងរូងភ្នំឬកន្លែងសម្ងាត់ណាមួយ ដោយសូត្រដប់ដងលើកូននោះនូវពាក្យឧទ្ទិស ព្រះពរឆ្ពោះទៅមូហ្ចាំម៉ាដ្ធ៉ូ صلى الله عليه وآله وسلم និងបណ្ដាកូនចៅ عليهم السلام របស់មូហ្ចាំម៉ាដ្ធ៉ូ صلى الله عليه وآله وسلم ។ អល់ឡោះ ﷻ ក៏បានបញ្ជាឲ្យ ទេវតាមួយអង្គផ្ដត់ផ្ដង់ទារកនោះ ទឹកដោះហូរចេញពីម្រាមដៃមួយរបស់ទារកឲ្យវាបៅ ។ អាហារទន់ ចេញមកពីម្រាមដៃមួយទៀតរបស់ទារកសម្រាប់ទ្រទ្រង់ជីវិតវា ទាល់តែកូនចៅអ៊ីសរ៉ាអ៊ីលធំ ។ លទ្ធផល គឺចំនួនក្មេងដែលបានរួចជីវិតដោយរបៀបនេះច្រើនជាងចំនួនក្មេងដែលត្រូវសម្លាប់ ។

﴿وَ يَسْتَحْيُونَ نِسَاءَكُمْ﴾ يُبْقُونَهُنَّ وَ يَتَّخِذُونَهُنَّ إِمَاءً، فَضَجُّوا إِلَى مُوسَى وَ قَالُوا: يَقْتَرِعُونَ بَنَاتِنَا وَ أَخَوَاتِنَا.

ទុកជីវិតឲ្យបណ្ដាស្ត្រីរបស់ពួកអ្នក ពួកគេទុកជីវិតឲ្យស្រី ដោយយកជាទាសីរបស់ពួកគេ ។ បន្ទាប់មក ពួកគេបានមកប្ដឹងមូសា عليه السلام ថា៖ "ពួកគេបានចាប់យកកូនស្រីនិងបងប្អូនស្រីយើង !"

فَأَمَرَ اَللَّهُ تِلْكَ اَلْبَنَاتِ كُلَّمَا رَابَهُنَّ رَيْبٌ مِنْ ذَلِكَ صَلَّيْنَ عَلَى مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ فَكَانَ اَللَّهُ يَرُدُّ عَنْهُنَّ أُولَئِكَ اَلرِّجَالَ، إِمَّا بِشُغُلٍ أَوْ مَرَضٍ أَوْ زَمَانَةٍ أَوْ لُطْفٍ مِنْ أَلْطَافِهِ فَلَمْ يَفْتَرِشْ مِنْهُنَّ اِمْرَأَةً، بَلْ دَفَعَ اَللَّهُ عَزَّ وَ جَلَّ ذَلِكَ عَنْهُنَّ بِصَلاَتِهِنَّ عَلَى مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ.

អល់ឡោះហ្ស៊ីរ៉ាន ១ បានបញ្ជាឲ្យបណ្តាកូនស្រីពួកគេ សូត្រឧទ្ទិសព្រះពរឲ្យទៅមូហ្ចាំម៉ាដ្ធ៉ូ ﷺ និងបណ្តាកូនចៅ ១ របស់មូហ្ចាំម៉ាដ្ធ៉ូ ﷺ រាល់ពេលដែលគេចាប់អារម្មណ៍មកលើពួកនាង ។ អាស្រ័យការសូត្រឧទ្ទិសព្រះពរឲ្យទៅមូហ្ចាំម៉ាដ្ធ៉ូ ﷺ និងបណ្តាកូនចៅ ១ របស់មូហ្ចាំម៉ាដ្ធ៉ូ ﷺ នេះ អល់ឡោះហ្ស៊ីរ៉ាន ១ បានរាំងពួកប្រុសៗ[ប្រជាជាតិហ្ចៀរអ៊ូន ១]ឲ្យនៅឆ្ងាយពីពួកនាង ។ ដោយសារវិធីនេះដែរ ពួកគេ (ពួករបស់ហ្ចៀរអ៊ូន ១) ខ្ជល់តែធ្វើការងារឬឈឺថ្កាត់ ពួកគេមិនអាចយកបណ្តាស្ត្រីរបស់ពួកគេ (ប្រជាជាតិអ៊ីសរ៉ាអ៊ីល) បានទេ ។ អល់ឡោះហ្ស៊ីរ៉ាន ១ បានកម្ចាត់អ្វីទាំង នេះពីពួកគេដោយសារឧទ្ទិសព្រះពរឲ្យទៅមូហ្ចាំម៉ាដ្ធ៉ូ ﷺ និងបណ្តាកូនចៅ ១ ល្អឥតខ្ចោះរបស់មូហ្ចាំម៉ាដ្ធ៉ូ ﷺ ។

ثُمَّ قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿وَ فِي ذٰلِكُمْ﴾ أَيْ فِي ذَلِكَ اَلْإِنْجَاءِ اَلَّذِي أَنْجَاكُمْ مِنْهُمْ رَبُّكُمْ ﴿بَلاٰءٌ﴾ نِعْمَةٌ ﴿مِنْ رَبِّكُمْ عَظِيمٌ﴾ كَبِيرٌ.

បន្ទាប់មកអល់ឡោះហ្ស៊ីរ៉ាន ១ មានព្រះរាជបន្ទូលថា៖ *ត្រង់នេះឯង* ពោលគឺក្នុងការរំដោះនោះដែលម្ចាស់ ១ ពួកអ្នកបានស្រង់ពួកអ្នក *ដែលពួកអ្នកនៅក្នុងការល្បងពិសោធន៍ដ៏ធ្ងន់* ជាព្រះគុណដ៏ធំ *ពីម្ចាស់ពួកអ្នក* ព្រះដ៏មហាធំថ្កើង ។

قَالَ اَللَّهُ عَزَّ وَ جَلَّ: يَا بَنِي إِسْرَائِيلَ اُذْكُرُوا إِذْ كَانَ اَلْبَلاَءُ يُصْرَفُ عَنْ أَسْلاَفِكُمْ وَ يَخِفُّ بِالصَّلاَةِ عَلَى مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ، أَ فَمَا تَعْلَمُونَ أَنَّكُمْ إِذَا شَاهَدْتُمُوهُ، وَ آمَنْتُمْ بِهِ كَانَتِ اَلنِّعْمَةُ عَلَيْكُمْ أَعْظَمَ [وَ أَفْضَلَ] وَ فَضْلُ اَللَّهِ عَلَيْكُمْ [أَكْثَرَ] وَ أَجْزَلَ؟ (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 242-244)

អល់ឡោះហ្ស៊ីរ៉ាន ១ មានព្រះរាជបន្ទូលថា៖ "កូនចៅអ៊ីសរ៉ាអ៊ីលអើយ ! ចូរពួកអ្នកនឹកឃើញកាលទុក្ខវេទនាដែលធ្លាប់មានលើដូនតាពួកអ្នកត្រូវបញ្ជៀសចេញឆ្ងាយពីពួកគេ បានធូរស្រាល ដោយសារឧទ្ទិសព្រះពរឲ្យទៅមូហ្ចាំម៉ាដ្ធ៉ូ ﷺ និងបណ្តាកូនចៅ ១ របស់មូហ្ចាំម៉ាដ្ធ៉ូ ﷺ ។ ពួកអ្នកមិនដឹងទេថា ដែលពួកអ្នកបានដឹងអំពីពួកគេនោះនិងបានជឿនោះ ជាព្រះគុណមកលើពួកអ្នកដែលធំជាងនោះនិងប្រសើរជាងនោះ ។ ព្រះគុណ្ឌបការរបស់អល់ឡោះហ្ស៊ីរ៉ាន ១ មកលើពួកអ្នកសម្បើមណាស់និងច្រើនណាស់ ?"
(التفسير المنسوب إلى الإمام العسكري عليه السلام 1: 242-244)

وَإِذْ فَرَقْنَا بِكُمُ ٱلْبَحْرَ فَأَنجَيْنَٰكُمْ وَأَغْرَقْنَآ ءَالَ فِرْعَوْنَ وَأَنتُمْ تَنظُرُونَ ﴿٥٠﴾

៥០. កាលយើងបានញែកសមុទ្រឲ្យពួកអ្នក យើងបានរំដោះពួកអ្នក យើងបានពន្លង់ប្រជាជាតិហ្ចៀរអ៊ូន ១ ។ ពួកអ្នកបានសម្លឹងមើល ។

អធិប្បាយអាយ៉ាស៊ុ ៥០

1/50. قَالَ اَلْإِمَامُ عَلَيْهِ اَلسَّلاَمُ: قَالَ اَللَّهُ عَزَّ وَ جَلَّ: وَ اُذْكُرُوا إِذْ جَعَلْنَا مَاءَ اَلْبَحْرِ فَرَقاً يَنْقَطِعُ بَعْضُهُ مِنْ بَعْضٍ. ﴿فَأَنْجَيْنٰاكُمْ﴾ هُنَاكَ وَ أَغْرَقْنَا فِرْعَوْنَ وَ قَوْمَهُ ﴿وَ أَنْتُمْ تَنْظُرُونَ﴾ إِلَيْهِمْ وَ هُمْ يَغْرَقُونَ.

៥០/១. អ៊ីមុាំ صلوات الله عليه والسلام [អាល់-ហ្ចាសាន់ អាល់-អ៊ាស់ការី صلوات الله عليه والسلام] មានវចនៈថា៖ "អល់ឡោះហ្ស៊ីរ៉ាន ១ មានព្រះរាជ

បន្ទូលថាពួកអ្នកចូរនឹកឃើញកាលយើងបានធ្វើឲ្យសមុទ្រញែក ផ្តាច់ប៉ែកមួយនៃសមុទ្រនោះពីប៉ែកឯទៀត *[២:៥០] យើងបានរំដោះពួកអ្នក* នៅទីនោះនិងបានពន្លង់ហ្ចៀរអ្ចុ៌ន និងប្រជាជាតិវា *ពួកអ្នកបានសម្លឹងមើល* ពួកវាដែលកំពុងលង់ទឹក ។

وَ ذَلِكَ أَنَّ مُوسَى عَلَيْهِ السَّلاَمُ لَمَّا اِنْتَهَى إِلَى اَلْبَحْرِ، أَوْحَى اَللَّهُ عَزَّ وَ جَلَّ إِلَيْهِ: قُلْ لِبَنِي إِسْرَائِيلَ: جَدِّدُوا تَوْحِيدِي وَ أَمِرُّوا بِقُلُوبِكُمْ ذِكْرَ مُحَمَّدٍ سَيِّدِ عَبِيدِي وَ إِمَائِي، وَ أَعِيدُوا عَلَى أَنْفُسِكُمُ اَلْوَلاَيَةَ لِعَلِيٍّ أَخِي مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ، وَ قُولُوا: اَللَّهُمَّ بِجَاهِهِمْ جَوِّزْنَا عَلَى مَتْنِ هَذَا اَلْمَاءِ. فَإِنَّ اَلْمَاءَ يَتَحَوَّلُ لَكُمْ أَرْضاً.

កាលនោះមូសាបានទៅដល់សមុទ្រ ។ អល់ឡោះហ្ស៊ូ២ បានបើកឲ្យព្រះអង្គជ្រាបថា៖ "ចូរប្រាប់បណ្តាកូនចៅអ៊ីសរ៉ាអ៊ីលថា៖ "ចូរពួកអ្នកជឿជាថ្មីទៀតថាអញ២ គឺព្រះតែមួយគត់របស់ពួកអ្នកនិងចូរពួកប្រាប់ចិត្តខ្លួនឯងឲ្យនឹករលឹកដល់មូហ្ចាំម៉ាដ្ឋ០ ព្រះអគ្គប្រមុខរបស់បណ្តាបាវបម្រើប្រុសស្រីរបស់អញ២ និងចូរត្រៀមខ្លួនពួកអ្នកទទួលវីឡាយ៉ាសុ៌អ្ចាលី ២ ប្អូនប្រុសរបស់មូហ្ចាំម៉ាដ្ឋ០ និងបណ្តាកូនចៅ២ ប្រសើររបស់គេ០ ហើយចូរពួកអ្នកថា៖ "អល់ឡោះហ្ស៊ូ២អើយ! ដោយនូវបុណ្យបារមីរបស់ព្រះអង្គទាំងនេះ២ សូមព្រះអង្គ២ នាំអស់ទូលព្រះបង្គំជាខ្ញុំឆ្លងកាត់លើផ្ទៃទឹក ។" ទឹកនឹងក្លាយទៅជាដីឲ្យពួកអ្នក ។"

فَقَالَ لَهُمْ مُوسَى ذَلِكَ. فَقَالُوا: أَ تُورِدُ عَلَيْنَا مَا نَكْرَهُ، وَ هَلْ فَرَرْنَا مِنْ [آلِ] فِرْعَوْنَ إِلاَّ مِنْ خَوْفِ اَلْمَوْتِ؟ وَ أَنْتَ تَقْتَحِمُ بِنَا هَذَا اَلْمَاءَ اَلْغَمْرَ بِهَذِهِ اَلْكَلِمَاتِ، وَ مَا يُدْرِينَا مَا يَحْدُثُ مِنْ هَذِهِ عَلَيْنَا؟

មូសាក៏បានប្រាប់ពួកគេដូចនេះ ។ ពួកគេបានថា៖ "លោកបញ្ជាយើងឲ្យធ្វើអ្វីមួយដែលយើងមិនចូលចិត្តឬ ដែលយើងរត់គេចខ្លួនពីហ្ចៀរអ្ចុ៌ន និងប្រជាជាតិវានោះព្រោះតែយើងខ្លាចស្លាប់ (យើងនឹងមិនធ្វើតាមទេ) ? លោកចង់ឲ្យយើងស្ទុះទៅរកទឹកនេះដើម្បីនឹងឲ្យមុចទៅក្នុងនោះដោយសម្តីនេះ ? លោកគិតថាអ្វីនឹងឡើងដល់យើងបើយើងធ្វើដូច្នេះ ?"

فَقَالَ لِمُوسَى عَلَيْهِ السَّلاَمُ كَالِبُ بْنُ يُوحَنَّا وَ هُوَ عَلَى دَابَّةٍ لَهُ، وَ كَانَ ذَلِكَ اَلْخَلِيجُ أَرْبَعَةَ فَرَاسِخَ: يَا نَبِيَّ اَللَّهِ أَمَرَكَ اَللَّهُ بِهَذَا أَنْ نَقُولَهُ وَ نَدْخُلَ اَلْمَاءَ؟ فَقَالَ: نَعَمْ. قَالَ: وَ أَنْتَ تَأْمُرُنِي بِهِ؟ قَالَ: بَلَى.

កាលីប ប៊ិន យ្ហូ២ាណា កំពុងតែជិះសេះ ឯឈ្ងងសមុទ្រនៅឆ្ងាយបួនហ្ចារសាក្ដ (ប្រមាណ ២៤ គីឡូម៉ែត្រ) បានទូលមូសាថា៖ "ព្រះសាស្តាអល់ឡោះហ្ស៊ូ២អើយ! អល់ឡោះហ្ស៊ូ២មែនទេដែលបានបញ្ជាព្រះអង្គឲ្យប្រាប់យើងឲ្យសូត្រពាក្យទាំងនេះ ហើយឲ្យចូលទៅក្នុងទឹក ?" មូសាបានថា៖ "ត្រូវហើយ ។" កាលីប ប៊ិន យ្ហូ២ាណា បានទូលថា៖ "ព្រះអង្គបញ្ជាអស់ទូលបង្គំឲ្យធ្វើដូចនេះមែនទេ ?" មូសាថា៖ "ត្រូវហើយ ។"

[قَالَ:] فَوَقَفَ وَ جَدَّدَ عَلَى نَفْسِهِ مِنْ تَوْحِيدِ اَللَّهِ وَ نُبُوَّةِ مُحَمَّدٍ وَ وَلاَيَةِ عَلِيِّ بْنِ أَبِي طَالِبٍ وَ اَلطَّيِّبِينَ مِنْ آلِهِمَا مَا أَمَرَهُ بِهِ، ثُمَّ قَالَ: اَللَّهُمَّ بِجَاهِهِمْ جَوِّزْنِي عَلَى مَتْنِ هَذَا اَلْمَاءِ. ثُمَّ أَقْحَمَ فَرَسَهُ، فَرَكَضَ عَلَى مَتْنِ اَلْمَاءِ، وَ إِذَا اَلْمَاءُ مِنْ تَحْتِهِ كَأَرْضٍ لَيِّنَةٍ حَتَّى بَلَغَ آخِرَ اَلْخَلِيجِ،

ព្រះអង្គ(صلوات الله عليه والسلام)មានវចនៈថា៖ "កាលីប ប៊ិន យ្ហូ២ាណា បានមកឈប់ បានទទួលស្គាល់សាថ្មីក្នុងចិត្តថាអល់ឡោះហ្ស៊ូ២គឺព្រះតែមួយគត់ បានទទួលស្គាល់មូហ្ចាំម៉ាដ្ឋ០ជាព្រះសាស្តា បានទទួលស្គាល់វីឡាយ៉ាសុ៌របស់ អ្ចាលី ២ ប៊ិន អាប៊ូ ត្ដ៊ាលីប ២ និងរបស់បណ្តាកូនចៅ២ ប្រសើររបស់អស់ព្រះអង្គ២ ដូច

ដែលគេបានបញ្ជាឲ្យលោកធ្វើនោះ ហើយលោកបានទូលថា៖ "អល់ឡោះហ្ស៊ីវ៉ាន់ﷻអើយ! ដោយនូវបុណ្យបារមីរបស់ព្រះអង្គﷺទាំងអស់នេះ សូមព្រះអង្គﷻអនុញ្ញាតឲ្យទូលព្រះបង្គំជាខ្ញុំអាចឆ្លងកាត់លើផ្ទៃទឹក ។" បន្ទាប់មកលោកបានបំបែរសេះ បានបំបោលវាទៅលើផ្ទៃទឹក ។ ទឹកនៅពីក្រោមលោកដូចដីជ្រាយ លុះលោកបានទៅដល់ចុងឈូងសមុទ្រ ។

ثُمَّ عَادَ رَاكِضاً، ثُمَّ قَالَ لِبَنِي إِسْرَائِيلَ: يَا بَنِي إِسْرَائِيلَ أَطِيعُوا مُوسَى فَمَا هَذَا اَلدُّعَاءُ إِلاَّ مِفْتَاحُ أَبْوَابِ اَلْجِنَانِ، وَ مَغَالِيقُ أَبْوَابِ اَلنِّيرَانِ، وَ مُنْزِلُ اَلْأَرْزَاقِ، وَ جَالِبٌ عَلَى عِبَادِ اَللَّهِ وَ إِمَائِهِ رِضَى [اَلرَّحْمَنِ] اَلْمُهَيْمِنِ اَلْخَلاَّقِ. فَأَبَوْا، وَ قَالُوا: [نَحْنُ] لاَ نَسِيرُ إِلاَّ عَلَى اَلْأَرْضِ.

ហើយបានបំបោលសេះត្រឡប់មកវិញ ប្រាប់កូនចៅអ៊ីសរ៉ាអ៊ីលថា៖ "កូនចៅអ៊ីសរ៉ាអ៊ីលអើយ! ចូរអស់លោកស្តាប់បង្គាប់មូសាﷺ ព្រោះការបួងសួងនេះមិនមែនអ្វីផ្សេងពីកូនសោទ្វារសួនសួគ៌នោះទេ ហើយជាកូនសោដែលចាក់បិទទ្វារភ្លើងនរក ដែលនាំចុះមកនូវគ្រឿងទ្រទ្រង់ជីវិត ដែលធ្វើឲ្យបាវបម្រើប្រុសស្រីរបស់អល់ឡោះហ្ស៊ីវ៉ាន់ﷻបាននូវព្រះមេត្តាប្រណីរបស់ព្រះដ៏មានព្រះសប្បុរសធម៌ ព្រះដ៏ខ្លាំងពូកែ ព្រះអ្នកបង្កើត ។" ពួកគេមិនព្រមទេ ហើយបានថា៖ "យើងនឹងមិនដើរលើអ្វីទេក្រៅពីដី ។"

فَأَوْحَى اَللَّهُ إِلَى مُوسَى :﴿أَنِ اِضْرِبْ بِعَصَاكَ اَلْبَحْرَ﴾ وَ قُلِ: اَللَّهُمَّ بِجَاهِ مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ لَمَّا فَلَقْتَهُ. فَفَعَلَ، « فَانْفَلَقَ »، وَ ظَهَرَتِ اَلْأَرْضُ إِلَى آخِرِ اَلْخَلِيجِ. فَقَالَ مُوسَى عَلَيْهِ السَّلاَمُ: اُدْخُلُوهَا. قَالُوا: اَلْأَرْضُ وَحِلَةٌ نَخَافُ أَنْ نَرْسُبَ فِيهَا.

អល់ឡោះហ្ស៊ីវ៉ាន់ﷻបានបើកឲ្យមូសាﷺដឹងថា៖ *"[២៦:៦៣] ចូរអ្នកវាយទឹកសមុទ្រដោយដំបងអ្នក"* ហើយចូរអ្នកﷺថា៖ "អល់ឡោះហ្ស៊ីវ៉ាន់ﷻអើយ! ដោយនូវបុណ្យបារមីរបស់មូហាំម៉ាដ់ﷺនិងព្រះរាជបុត្រារាជនត្តាﷺប្រសើររបស់មូហាំម៉ាដ់ﷺ សូមព្រះអង្គﷻញែកសមុទ្រ ។" ព្រះអង្គﷺបានធ្វើតាម សមុទ្រក៏បានញែក បង្ហាញឲ្យឃើញដីរហូតទៅដល់ឈូងសមុទ្រ ។ មូសាﷺមានវចន:ថា៖ "ចូលទៅក្នុងសមុទ្រទៅ ។" ពួកគេបានថា៖ "ដីល្អៀច ។ យើងខ្លាចតែជុងទៅក្នុងដីនោះ ។"

فَقَالَ اَللَّهُ عَزَّ وَ جَلَّ: يَا مُوسَى قُلْ: اَللَّهُمَّ بِحَقِّ مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ جَفِّفْهَا. فَقَالَهَا، فَأَرْسَلَ اَللَّهُ عَلَيْهَا رِيحَ اَلصَّبَا فَجَفَّتْ. وَ قَالَ مُوسَى : اُدْخُلُوهَا.

អល់ឡោះហ្ស៊ីវ៉ាន់ﷻមានព្រះរាជបន្ទូលថា៖ "មូសាﷺអើយ! ចូរអ្នកﷺថា៖ "អល់ឡោះហ្ស៊ីវ៉ាន់ﷻអើយ! ដោយនូវព្រះរាជសិទ្ធិរបស់មូហាំម៉ាដ់ﷺនិងព្រះរាជបុត្រារាជនត្តាﷺប្រសើររបស់ព្រះអង្គﷺ សូមព្រះអង្គﷻធ្វើឲ្យវាស្ងួត ។"" ព្រះអង្គﷺបានថាដូចនេះ អល់ឡោះហ្ស៊ីវ៉ាន់ﷻក៏បានចាត់បញ្ជូនខ្យល់ អាល់-ស្ប៊ូបា មកលើដីបានធ្វើឲ្យវាស្ងួត ។ មូសាﷺបានថា៖ "ចូលទៅក្នុងនោះទៅ!"

فَقَالُوا: يَا نَبِيَّ اَللَّهِ نَحْنُ اِثْنَتَا عَشْرَةَ قَبِيلَةً بَنُو اِثْنَيْ عَشَرَ أَباً، وَ إِنْ دَخَلْنَا رَامَ كُلُّ فَرِيقٍ مِنَّا تَقَدُّمَ صَاحِبِهِ، وَ لاَ نَأْمَنُ وُقُوعَ اَلشَّرِّ بَيْنَنَا، فَلَوْ كَانَ لِكُلِّ فَرِيقٍ مِنَّا طَرِيقٌ عَلَى حِدَةٍ لَآمَنَّا مَا نَخَافُهُ.

ពួកគេបានថា៖ "ព្រះសាស្តាﷺអល់ឡោះហ្ស៊ីវ៉ាន់ﷻអើយ! យើងជាកុលសម្ព័ន្ធទាំងដប់ពីរ កូនចៅរបស់ឪពុកដប់ពីរនាក់ ។ បើយើងចូលទៅទាំងអស់គ្នា កុលសម្ព័ន្ធនីមួយៗដណ្តើមគ្នាទៅមុនគេ នឹងមានការឈ្លោះប្រកែកគ្នា ។ បើយើងរាល់កុលសម្ព័ន្ធមានផ្លូវមួយ វានឹងជួយបន្ទូរបារម្ភយើង ។"

فَأَمَرَ اَللَّهُ مُوسَى أَنْ يَضْرِبَ اَلْبَحْرَ بِعَدَدِهِمُ اِثْنَتَيْ عَشْرَةَ ضَرْبَةً فِي اِثْنَيْ عَشَرَ مَوْضِعاً إِلَى جَانِبِ ذَلِكَ اَلْمَوْضِعِ، وَ يَقُولُ: اَللَّهُمَّ بِجَاهِ مُحَمَّدٍ

وَ آلِهِ اَلطَّيِّبِينَ بَيِّنِ اَلْأَرْضَ لَنَا وَ أَمِطِ اَلْمَاءَ عَنَّا. فَصَارَ فِيهِ تَمَامُ اِثْنَي عَشَرَ طَرِيقاً، وَ جَفَّ قَرَارُ اَلْأَرْضِ بِرِيحِ اَلصَّبَا فَقَالَ: اُدْخُلُوهَا. فَقَالُوا: كُلُّ فَرِيقٍ مِنَّا يَدْخُلُ سِكَّةً مِنْ هَذِهِ اَلسِّكَكِ لاَ يَدْرِي مَا يَحْدُثُ عَلَى اَلْآخَرِينَ.

អល់ឡោះហ្ស៊ីបានបញ្ជាមូសាឲ្យវាយសមុទ្រដោយដំបងព្រះអង្គ តាមចំនួនដប់ពីរកុលសម្ព័ន្ធនោះ ដប់ពីរកន្លែងផ្សេងគ្នានៅក្បែរៗនោះ ដោយឲ្យព្រះអង្គថា: "អល់ឡោះហ្ស៊ីអើយ! ដោយនូវបុណ្យបារមីរបស់មូហ្ហាំម៉ាដ្ធ៉ូ និងព្រះរាជបុត្ររាជនត្តាប្រសើររបស់មូហ្ហាំម៉ាដ្ធ៉ូ សូមព្រះអង្គ យកដីចេញមកឲ្យអស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ ញែកទឹកចេញពីអស់ទូលព្រះបង្គំជាខ្ញុំ ។" មានផ្លូវដប់ពីរខ្សែ ស្ងួតដោយសារខ្យល់ អាល់-ស្ង៊ីបា បក់មកលើ ។ មូសាមានវចន:ថា: "ចូលទៅក្នុងសមុទ្រទៅ!" ពួកគេបានថា: "ក្រុមទាំងអស់នឹងចូលទៅតាមផ្លូវទាំងនេះ តែមិនដឹងថានឹងមានអ្វីកើតឡើងដល់ក្រុមឯទៀតទេ ។"

فَقَالَ اَللَّهُ عَزَّ وَ جَلَّ: فَاضْرِبْ كُلَّ طَوْدٍ مِنَ اَلْمَاءِ بَيْنَ هَذِهِ اَلسِّكَكِ. فَضَرَبَ وَ قَالَ: اَللَّهُمَّ بِجَاهِ مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ لَمَّا جَعَلْتَ فِي هَذَا اَلْمَاءِ طِيقَاناً وَاسِعَةً يَرَى بَعْضُهُمْ بَعْضاً [مِنْهَا]. فَحَدَثَتْ طِيقَانٌ وَاسِعَةٌ يَرَى بَعْضُهُمْ بَعْضاً [مِنْهَا] ثُمَّ دَخَلُوهَا.

អល់ឡោះហ្ស៊ីមានព្រះរាជបន្ទូលថា: "ចូរអ្នកវាយរាល់ៗភ្នំទឹកដែលនៅចន្លោះផ្លូវនោះដោយដំបងអ្នកទៅ ។" ព្រះអង្គបានវាយ ហើយបានថា: "អល់ឡោះហ្ស៊ីអើយ! ដោយនូវបុណ្យបារមីរបស់មូហ្ហាំម៉ាដ្ធ៉ូ និងព្រះរាជបុត្ររាជនត្តាប្រសើររបស់មូហ្ហាំម៉ាដ្ធ៉ូ សូមព្រះអង្គឲ្យមានចន្លោះក្នុងទឹកដើម្បីពួកគេនឹងមើលគ្នាឃើញ ។" មានប្រហ្ពោះបើកឡើង ធំគ្រាន់បើសម្រាប់ពួកគេអាចមើលគ្នាឃើញ ។ បន្ទាប់មកពួកគេបានចូលទៅតាមផ្លូវ ។

فَلَمَّا بَلَغُوا آخِرَهَا جَاءَ فِرْعَوْنُ وَ قَوْمُهُ، فَدَخَلَ بَعْضُهُمْ، فَلَمَّا دَخَلَ آخِرُهُمْ، وَ هَمَّ أَوَّلُهُمْ بِالْخُرُوجِ أَمَرَ اَللَّهُ تَعَالَى اَلْبَحْرَ فَانْطَبَقَ عَلَيْهِمْ، فَغَرِقُوا، وَ أَصْحَابُ مُوسَى يَنْظُرُونَ إِلَيْهِمْ فَذَلِكَ قَوْلُهُ عَزَّ وَ جَلَّ: ﴿وَ أَغْرَقْنَا آلَ فِرْعَوْنَ وَ أَنْتُمْ تَنْظُرُونَ﴾ إِلَيْهِمْ.

លុះបុគ្គលក្រោយគេបានទៅដល់ចុងឈូងសមុទ្រ ហ្ហ្ការអ្ហ៊ូន និងប្រជាជាតិវាបានមកដល់ ។ ខ្លះបានចាប់ផ្តើមចូលមក ។ លុះបុគ្គលក្រោយគេបានចូលមក ឯពួកគេជាអ្នកចេញមុនគេពីក្នុងសមុទ្រ អល់ឡោះហ្ស៊ីបានបញ្ជាឲ្យទឹកសមុទ្រកជាស្រទាប់មកលើពួកគេ ពួកគេពន្លង់ទឹក ។ ក្ដីគ្នារបស់មូសាបានឈរមើលពួកគេ ។ នេះគឺព្រះរាជបន្ទូលរបស់អល់ឡោះហ្ស៊ី *[២:៥០] យើងបានពន្លង់ប្រជាជាតិហ្ហ្ការអ្ហ៊ូន ។ ពួកអ្នកបានសម្លឹងមើល* ទៅពួកគេ ។

قَالَ اَللَّهُ عَزَّ وَ جَلَّ لِبَنِي إِسْرَائِيلَ فِي عَهْدِ مُحَمَّدٍ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ: فَإِذَا كَانَ اَللَّهُ تَعَالَى فَعَلَ هَذَا كُلَّهُ بِأَسْلاَفِكُمْ لِكَرَامَةِ مُحَمَّدٍ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ، وَ دُعَاءِ مُوسَى، دُعَاءَ تَقَرُّبٍ بِهِمْ [إِلَى اَللَّهِ] أَ فَلاَ تَعْقِلُونَ أَنَّ عَلَيْكُمُ اَلْإِيمَانَ بِمُحَمَّدٍ وَ آلِهِ إِذْ [قَدْ] شَاهَدْتُمُوهُ اَلْآنَ؟ (التفسير العسكرى عليه السلام ج١ ص٢٤٥)

អល់ឡោះហ្ស៊ីមានព្រះរាជបន្ទូលចំពោះកូនចៅអ៊ីរ៉ាអ៊ីលអំពីសម័យកាលរបស់មូហ្ហាំម៉ាដ្ធ៉ូថា: "កាលអល់ឡោះហ្ស៊ីបានធ្វើអ្វីទាំងនេះឲ្យដូនតាពួកអ្នក ដោយសារកិត្យានុភាពរបស់មូហ្ហាំម៉ាដ្ធ៉ូ មូសាបានបួងសួងសូមឲ្យបានជាជំនិតរបស់អល់ឡោះហ្ស៊ីតាមរយ:ព្រះអង្គទាំងនោះ ។ ពួកអ្នកមិនប្រើសតិប្រាជ្ញាគិតទេថាពួកអ្នកត្រូវជឿមូហ្ហាំម៉ាដ្ធ៉ូ និងបណ្ដាកូនចៅរបស់គេជាចាំបាច់ នៅពេលនេះ ពេលពួកអ្នកបានឃើញផ្ទាល់ភ្នែកហើយនោះ ?"

(التفسير العسكرى عليه السلام 1: 245)

وَإِذْ وَٰعَدْنَا مُوسَىٰٓ أَرْبَعِينَ لَيْلَةً ثُمَّ ٱتَّخَذْتُمُ ٱلْعِجْلَ مِنۢ بَعْدِهِۦ وَأَنتُمْ ظَٰلِمُونَ ﴿٥١﴾

៥១. [ចូរនឹកឃើញ]កាលយើងបានណាត់ជួបនឹងមូសាសែសិបយប់ ។ បន្ទាប់មកពួកអ្នកបានយកកូនគោបា[ជាព្រះ] អត់ពីគេ ។ ពួកអ្នកជាជនទុច្ចរិត ។

អធិប្បាយអាយ៉ាស់ ៥១

1/51. قَالَ اَلْإِمَامُ عَلَيْهِ اَلسَّلاَمُ: كَانَ مُوسَى بْنُ عِمْرَانَ عَلَيْهِ السَّلاَمُ يَقُولُ لِبَنِي إِسْرَائِيلَ: إِذَا فَرَّجَ اَللَّهُ عَنْكُمْ وَ أَهْلَكَ أَعْدَاءَكُمْ آتِيكُمْ بِكِتَابٍ مِنْ رَبِّكُمْ، يَشْتَمِلُ عَلَى أَوَامِرِهِ وَ نَوَاهِيهِ وَ مَوَاعِظِهِ وَ عِبَرِهِ وَ أَمْثَالِهِ.

៥១/១. អ៊ីមុាំ صلوات الله عليه والسلام [អាល់-ហ្ហាសាន់ អាល់-អ្ហាស់ការី صلوات الله عليه والسلام] មានវចនៈថា៖ "មូសា ប៊ិន អ៊ីមរ៉ាន عليه السلام បានប្រាប់កូនចៅអ៊ីសរ៉ាអ៊ីលថា៖ "កាលណាអល់ឡោះហ្ស៊ូ ﷻ សង្គ្រោះអស់លោក កម្ទេចសត្រូវរបស់អស់លោក ខ្ញុំ عليه السلام នឹងយកមកឲ្យអស់លោកនូវព្រះគម្ពីរមួយពីម្ចាស់ ﷻ អស់លោក ។ នៅក្នុងព្រះគម្ពីរនោះមានព្រះបញ្ជា ព្រះបម្រាម ព្រះឱវាទ ព្រះសិក្ខាបទ និងព្រះអភិប្រាយ (អធិប្បាយ) ។""

فَلَمَّا فَرَّجَ اَللَّهُ تَعَالَى عَنْهُمْ، أَمَرَهُ اَللَّهُ عَزَّ وَ جَلَّ أَنْ يَأْتِيَ لِلْمِيعَادِ، وَ يَصُومَ ثَلاَثِينَ يَوْماً عِنْدَ أَصْلِ اَلْجَبَلِ، وَ ظَنَّ مُوسَى أَنَّهُ بَعْدَ ذَلِكَ يُعْطِيهِ اَلْكِتَابَ.

លុះអល់ឡោះហ្ស៊ីតាអាឡា ﷻ បានសង្គ្រោះពួកគេ អល់ឡោះហ្ស៊ូ ﷻ បានបញ្ជាមូសា عليه السلام ឲ្យមកឯកន្លែងណាត់ជួបឲ្យព្រះអង្គ عليه السلام កាន់សីលត្រណមអាហារសាមសិបថ្ងៃ ឲ្យមកឯជើងភ្នំ ។ មូសា عليه السلام គិតថាក្រោយពីនេះ ព្រះអង្គ ﷻ នឹងប្រទានព្រះគម្ពីរឲ្យព្រះអង្គ عليه السلام ។

فَصَامَ مُوسَى ثَلاَثِينَ يَوْماً [عِنْدَ أَصْلِ اَلْجَبَلِ] فَلَمَّا كَانَ فِي آخِرِ اَلْأَيَّامِ اِسْتَاكَ قَبْلَ اَلْفِطْرِ فَأَوْحَى اَللَّهُ عَزَّ وَ جَلَّ [إِلَيْهِ] يَا مُوسَى أَ مَا عَلِمْتَ أَنَّ خُلُوفَ فَمِ اَلصَّائِمِ أَطْيَبُ عِنْدِي مِنْ رِيحِ اَلْمِسْكِ؟ صُمْ عَشْراً أُخَرَ وَ لاَ تَسْتَكْ عِنْدَ اَلْإِفْطَارِ. فَفَعَلَ ذَلِكَ مُوسَى عَلَيْهِ السَّلاَمُ.

មូសា عليه السلام បានកាន់សីលត្រណមអាហារសាមសិបថ្ងៃនៅឯជើងលើភ្នំ ។ ថ្ងៃបំផុត មុនស្រាយត្រណម ព្រះអង្គ عليه السلام បានដុសធ្មេញ ។ អល់ឡោះហ្ស៊ូ ﷻ បានបើកឲ្យព្រះអង្គ عليه السلام ដឹងថា៖ "មូសា عليه السلام អើយ ! អ្នក عليه السلام ដឹងទេថាក្លិនមាត់របស់អ្នកកាន់សីលត្រណមអាហារក្រអូបបំផុតសម្រាប់អញ ﷻ លើសក្លិនក្រអូបទៅទៀត ? ចូរអ្នក عليه السلام កាន់សីលត្រណមដប់ថ្ងៃថែមទៀត ចូរអ្នក عليه السلام កុំដុសធ្មេញពេលស្រាយត្រណម ។" មូសា عليه السلام បានអនុវត្តតាម ។

وَ كَانَ وَعَدَ اَللَّهُ عَزَّ وَ جَلَّ أَنْ يُعْطِيَهُ اَلْكِتَابَ بَعْدَ أَرْبَعِينَ لَيْلَةً، فَأَعْطَاهُ إِيَّاهُ. فَجَاءَ اَلسَّامِرِيُّ فَشَبَّهَ عَلَى مُسْتَضْعَفِي بَنِي إِسْرَائِيلَ، وَ قَالَ: وَعَدَكُمْ مُوسَى أَنْ يَرْجِعَ إِلَيْكُمْ بَعْدَ أَرْبَعِينَ لَيْلَةً، وَ هَذِهِ عِشْرُونَ لَيْلَةً وَ عِشْرُونَ يَوْماً تَمَّتْ أَرْبَعُونَ أَخْطَأَ مُوسَى رَبَّهُ، وَ قَدْ أَتَاكُمْ رَبُّكُمْ، أَرَادَ أَنْ يُرِيَكُمْ: أَنَّهُ قَادِرٌ عَلَى أَنْ يَدْعُوَكُمْ إِلَى نَفْسِهِ بِنَفْسِهِ وَ أَنَّهُ لَمْ يَبْعَثْ مُوسَى لِحَاجَةٍ مِنْهُ إِلَيْهِ.

អល់ឡោះហ្ស៊ូ ﷻ បានសន្យាប្រទានព្រះគម្ពីរឲ្យព្រះអង្គ عليه السلام ក្រោយសែសិបយប់ ហើយព្រះអង្គ ﷻ បានប្រទានព្រះគម្ពីរឲ្យព្រះមូសា عليه السلام ។ សាមីរី ﷺ បានមកកកូនចៅអ៊ីសរ៉ាអ៊ីលដែលខ្សោយជំនឿ ធ្វើឲ្យពួកគេសង្ស័យ ដោយថា៖ "មូសា عليه السلام បានសន្យានឹងអស់លោកថានឹងត្រឡប់មកវិញក្រោយសែសិបយប់ ។

ពេលនេះបានម្តេយប់និងម្តេថ្ងៃ គ្រប់ពេលកំណត់ហើយ ។ មូសាﷺបានយល់ខុសអំពីម្ចាស់ﷻរបស់គេﷺ ។ ម្ចាស់ﷻអស់លោកមករកអស់លោកហើយ ដោយចង់ឲ្យអស់លោកបានឃើញព្រះអង្គﷻផ្ទាល់ភ្នែក ដើម្បីនឹងឲ្យអស់លោកឃើញថាព្រះអង្គﷻមានមហិទ្ធិឫទ្ធិហៅអស់លោកមករកព្រះអង្គﷻដោយព្រះអង្គﷻឯង ។ ព្រះអង្គﷻចាត់បញ្ជូនមូសាﷺតែពេលណាដែលព្រះអង្គﷻត្រូវការគេﷺទេ ។"

فَأَظْهَرَ لَهُمُ اَلْعِجْلَ اَلَّذِي كَانَ عَمِلَهُ فَقَالُوا لَهُ: فَكَيْفَ يَكُونُ اَلْعِجْلُ إِلَهَنَا؟ قَالَ لَهُمْ: إِنَّمَا هَذَا اَلْعِجْلُ يُكَلِّمُكُمْ مِنْهُ رَبُّكُمْ كَمَا كَلَّمَ مُوسَى مِنَ اَلشَّجَرَةِ فَالْإِلَهُ فِي اَلْعِجْلِ كَمَا كَانَ فِي اَلشَّجَرَةِ. فَضَلُّوا بِذَلِكَ وَ أَضَلُّوا.

សាមីរីﷺបានបង្ហាញពួកគេនូវកូនគោបាដែលគេﷺបានសាងឡើង ។ ពួកគេបានប្រាប់សាមីរីﷺថា៖ "កូនគោបានេះជាម្ចាស់យើងដូចម្តេចទៅ ?" សាមីរីﷺបានប្រាប់ពួកគេថា៖ "ម្ចាស់អស់លោកនឹងនិយាយរកអស់លោកមកពីកូនគោបានេះ ដូចព្រះអង្គបាននិយាយរកមូសាﷺមកពីដើមឈើនោះដែរ ។ ដូច្នេះ ព្រះរបស់គេﷺនៅក្នុងកូនគោបាដូចព្រះអង្គនៅក្នុងដើមឈើដែរ ។" ពួកពួកគេវង្វេងដោយអ្វីនេះ ពួកគេបានធ្វើខុសដោយប្រការនេះ ហើយបានធ្វើឲ្យគេខុស ។

[فَلَمَّا رَجَعَ مُوسَى إِلَى قَوْمِهِ قَالَ:] يَا أَيُّهَا اَلْعِجْلُ أَ كَانَ فِيكَ رَبُّنَا كَمَا يَزْعُمُ هَؤُلَاءِ فَنَطَقَ اَلْعِجْلُ وَ قَالَ: عَزَّ رَبُّنَا عَنْ أَنْ يَكُونَ اَلْعِجْلُ حَاوِياً لَهُ، أَوْ شَيْءٌ مِنَ اَلشَّجَرَةِ وَ اَلْأَمْكِنَةِ عَلَيْهِ مُشْتَمِلاً، لاَ وَ اَللَّهِ يَا مُوسَى وَ لَكِنَّ اَلسَّامِرِيَّ نَصَبَ عِجْلاً مُؤَخَّرَةً إِلَى اَلْحَائِطِ وَ حَفَرَ فِي اَلْجَانِبِ اَلْآخَرِ فِي اَلْأَرْضِ، وَ أَجْلَسَ فِيهِ بَعْضُ مَرَدَتِهِ فَهُوَ اَلَّذِي وَضَعَ فَاهُ عَلَى دُبُرِهِ، وَ تَكَلَّمَ بِمَا تَكَلَّمَ لَمَّا قَالَ: ﴿هٰذَا إِلٰهُكُمْ وَ إِلٰهُ مُوسىٰ﴾

ពេលមូសាﷺបានមករកប្រជាជាតិព្រះអង្គﷺវិញ ព្រះអង្គﷺមានវចន:ថា៖ "កូនគោបាអើយ ! ម្ចាស់ﷻយើងនៅក្នុងអ្នកឯងដូចពួកថាមែនទេ ?" កូនគោបាបានថា៖ "ម្ចាស់ﷻយើងមហាខ្លាំងពូកែពេកក្រៃ កូនគោបា ដើមឈើឬកន្លែងនីមួយមិនអាចបង្ហាំងព្រះអង្គﷻបានទេ ។ ទេ មូសាﷺអើយ ! សូមស្បថនឹងអល់ឡោះហ្ស៊ីﷻ !" តែសាមីរីﷺទេដែលបានដាក់កូនគោបា ដោយដាក់ប៉ែកក្រោយវាផ្ទឹបនឹងជញ្ជាំង បានចោះប្រហោងលើជញ្ជាំងនោះ ហើយបានដាក់មនុស្សអ្នកជឿវាម្នាក់នៅក្រោយប្រហោងនោះ ឲ្យអង្គុយក្រោយនោះ និយាយជាមួយពួកគេតាមប្រហោងនោះ ដែលនៅក្រោយគូទកូនគោបា ។ ពួកគេស្មានថាកូនគោបាជាអ្នកនិយាយពេលគេបានថា៖ *"[២០:៨៨] នេះគឺព្រះរបស់អស់លោក ហើយជាព្រះរបស់មូសា ។*

يَا مُوسَى بْنَ عِمْرَانَ مَا خَذَلَ هَؤُلَاءِ بِعِبَادَتِي وَ اِتِّخَاذِي إِلَهاً إِلاَّ لِتَهَاوُنِهِمْ بِالصَّلَاةِ عَلَى مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ، وَ جُحُودِهِمْ بِمُوَالاَتِهِمْ وَ بِنُبُوَّةِ اَلنَّبِيِّ مُحَمَّدٍ وَ وَصِيَّةِ اَلْوَصِيِّ حَتَّى أَدَّاهُمْ إِلَى أَنِ اِتَّخَذُونِي إِلَهاً.

[កូនគោបាបានថា៖] "មូសាﷺ ប៊ិន អ៊ីមរ៉ានﷺអើយ ! ដែលបាវបម្រើទាំងនេះបានសក្ការ:ខ្ញុំ បានយកខ្ញុំជាព្រះពួកគេនោះព្រោះតែពួកគេធុញទ្រាន់នឹងការឧទ្ទិសព្រះពរស្ត្ងឡាវ៉ាតឲ្យទៅមូហ្ហាំម៉ាដ្ធ់ﷺ និងបណ្តាកូនចៅﷺល្អប្រសើររបស់ព្រះអង្គﷺ បានច្រានចោលវីឡាយ៉ាស:ុរបស់អស់ព្រះអង្គﷺ ច្រានចោលតំណែងសាស្តារបស់មូហ្ហាំម៉ាដ្ធ់ﷺនិងអាណាព្យាបាលភាពរបស់អ្នកស្នងﷺព្រះអង្គﷺ ។ ទីបំផុតពួកគេក្លាយទៅជាសត្ត្រូវរបស់អស់ព្រះអង្គﷺ យកខ្ញុំជាព្រះ ។"

قَالَ اَللَّهُ عَزَّ وَ جَلَّ: فَإِذَا كَانَ اَللَّهُ تَعَالَى إِنَّمَا خَذَلَ عَبَدَةَ اَلْعِجْلِ لِتَهَاوُنِهِمْ بِالصَّلَاةِ عَلَى مُحَمَّدٍ وَ وَصِيِّهِ عَلِيٍّ فَمَا تَخَافُونَ مِنَ اَلْخِذْلاَنِ

اَلْأَكْبَرِ فِي مُعَانَدَتِكُمْ لِمُحَمَّدٍ وَ عَلِيٍّ وَ قَدْ شَاهَدْتُمُوهُمَا، وَ تَبَيَّنْتُمْ آيَاتِهِمَا وَ دَلَائِلَهُمَا؟ (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 247)

អល់ឡោះហ្ស៊ីយ៉ាន[ﷻ]មានព្រះរាជបន្ទូលថា៖ "អល់ឡោះហ្ស៊ីយ៉ាន[تعالى]បានឲ្យបណ្តាអ្នកដែលបានគោរពកូនគោបាអាប់ឱនកិត្តិយស ព្រោះតែពួកគេមិនយកចិត្តទុកដាក់នឹងការឧទ្ទិសព្រះពរ[ស្ល៊ីឡាវ៉ាត]ឲ្យទៅមូហ្ហាំម៉ាដ្ដ[ﷺ]និងអ៊ីម៉ាលី[عليه السلام]អ្នកស្នងគេ[ﷺ] ។ ពួកអ្នកមិនខ្លាចសេចក្ដីអាម៉ាស់ធំសម្បើមជាងនេះទេ ដោយសារតែពួកអ្នកជាសត្រូវរបស់មូហ្ហាំម៉ាដ្ដ[ﷺ]និងអ៊ីម៉ាលី[عليهما السلام] ក្រោយពីបានឃើញពួកគេ[عليهم السلام] បានឃើញព្រះសញ្ញាពួកគេ[عليهم السلام]និងព្រះភ័ស្ដុតាងទាំងឡាយរបស់ពួកគេ[عليهم السلام]ហើយនោះ ?"

(التفسير المنسوب إلى الإمام العسكري عليه السلام 1: 247)

***

2/51. الْعَيَّاشِيُّ: عَنْ مُحَمَّدِ بْنِ مُسْلِمٍ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلَامُ)، فِي قَوْلِهِ: "وَ إِذْ وَاعَدْنَا مُوسىٰ أَرْبَعِينَ لَيْلَةً". قَالَ: «كَانَ فِي الْعِلْمِ وَ التَّقْدِيرِ ثَلَاثِينَ لَيْلَةً، ثُمَّ بَدَا لِلَّهِ فَزَادَ عَشْراً، فَتَمَّ مِيقَاتُ رَبِّهِ الْأَوَّلُ وَ الْآخِرُ أَرْبَعِينَ لَيْلَةً». (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢١٧ الحديث: ٩٩/ ٤٧٤، تفسير العيّاشي – الجزء: ١ الصفحة: ٤٤ الحديث : ٤٦)**

៥១/២. រាយការណ៍ដោយ អាល់-អ្ហ្ម៉ាយ៉ាស្ស៊ី តមកពី មូហ្ហាំម៉ាដ្ដ ប៊ិន មុស្លីម តមកពី អាប៊ូ យ៉ាហ្ហ ក្ដ[عليه السلام]ហ្ការ អំពីព្រះបន្ទូលព្រះអង្គ[ﷻ] *[២:៥១] កាលយើងបានណាត់ជួបនឹងមូសាសែសិបយប់* ។ ព្រះអង្គ[عليه السلام]មានវចនៈថា៖ "នៅក្នុងព្រះអភិញ្ញានិងក្នុងព្រះបុព្វកំណត់គឺសាមសិបយប់ ។ បន្ទាប់មកអល់ឡោះហ្ស៊ីយ៉ាន[ﷻ]បានប្ដូរវា ព្រះអង្គ[ﷻ]បានបន្ថែមដប់ទៀត ។ កាលបរិច្ឆេទកំណត់ដោយម្ចាស់[ﷻ]ព្រះអង្គ[عليه السلام]គឺ[សាមសិបយប់]ដំបូងនិង[ដប់យប់]ចុងក្រោយ គ្រប់សែសិបយប់ ។" (تفسير العيّاشي 1: 44/ 46)

ثُمَّ عَفَوْنَا عَنكُم مِّنْ بَعْدِ ذَٰلِكَ لَعَلَّكُمْ تَشْكُرُونَ ﴿٥٢﴾

៥២. ហើយយើងបានអត់ឱនឲ្យពួកអ្នកក្រោយពីនោះ ដើម្បីនឹងឲ្យពួកអ្នកដឹងគុណ ។

អធិប្បាយអាយ៉ាស់ ៥២

ثُمَّ قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿ثُمَّ عَفَوْنَا عَنْكُمْ مِنْ بَعْدِ ذٰلِكَ لَعَلَّكُمْ تَشْكُرُونَ﴾ أَيْ عَفَوْنَا عَنْ أَوَائِلِكُمْ عِبَادَتَهُمُ اَلْعِجْلَ، لَعَلَّكُمْ يَا أَيُّهَا اَلْكَائِنُونَ فِي عَصْرِ مُحَمَّدٍ مِنْ بَنِي إِسْرَائِيلَ تَشْكُرُونَ تِلْكَ اَلنِّعْمَةَ عَلَى أَسْلَافِكُمْ وَ عَلَيْكُمْ بَعْدَهُمْ.

៥២/១. បន្ទាប់មកអល់ឡោះហ្ស៊ីយ៉ាន[ﷻ]មានព្រះរាជបន្ទូលថា៖ *[២:៥២] ហើយយើងបានអត់ឱនឲ្យពួកអ្នកក្រោយពីនោះដើម្បីនឹងឲ្យពួកអ្នកដឹងគុណ* មានន័យថាយើង[ﷻ]លើកទោសឲ្យគ្នាមុនៗរបស់ពួកអ្នកដែលបានសក្ការៈកូនគោបា ដើម្បីនឹងឲ្យពួកអ្នក ដែលរស់នៅក្នុងសម័យកាលរបស់មូហ្ហាំម៉ាដ្ដ[ﷺ]នេះ ដែលជាកូនចៅអ៊ីសរ៉ាអ៊ីលនោះ ដឹងគុណចំពោះព្រះឧបការៈគុណលើដូនតាពួកអ្នកនិងលើពួកអ្នកក្រោយពួកគេ ។

[ثُمَّ] قَالَ عَلَيْهِ السَّلَامُ: وَ إِنَّمَا عَفَا اَللَّهُ عَزَّ وَ جَلَّ عَنْهُمْ لِأَنَّهُمْ دَعَوُا اَللَّهَ بِمُحَمَّدٍ وَ آلِهِ اَلطَّاهِرِينَ، وَ جَدَّدُوا عَلَى أَنْفُسِهِمُ اَلْوَلَايَةَ لِمُحَمَّدٍ وَ عَلِيٍّ وَ آلِهِمَا اَلطَّيِّبِينَ. فَعِنْدَ ذَلِكَ رَحِمَهُمُ اَللَّهُ وَ عَفَا عَنْهُمْ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 247)

បន្ទាប់មកព្រះអង្គ[عليه السلام] (អ៊ីមុាំ អាល់-ហ្ការ៉ាសាន់ អាល់-អ្ហ៊ីស្ការ៉ី[عليه السلام]) មានវចនៈថា៖ "អល់ឡោះហ្ស៊ីយ៉ាន[ﷻ]បានលើកទោសឲ្យពួកគេ ព្រោះពួកគេបានបួងសួងអល់ឡោះហ្ស៊ីយ៉ាន[ﷻ]តាមរយៈមូហ្ហាំម៉ាដ្ដ[ﷺ]និងបណ្តាព្រះរាជ

បុត្ររាជនត្តាعليهم السلامបរិសុទ្ធរបស់ព្រះអង្គ صلى الله عليه وآله وسلم និងបានជឿក្នុងចិត្តពួកគេសាថ្មីលើវីឡាយ៉ាស៊ុ់របស់មូហ្ហាំម៉ាដ្ទ់ صلى الله عليه وآله وسلم របស់អ៊ាលី صلوات الله عليه والسلام និងរបស់បណ្តាកូនចៅបរិសុទ្ធعليهم السلامរបស់អស់ព្រះអង្គ ។ ពេលពួកគេបានធ្វើដូចនេះ អល់ឡោះហ្ស៊ីវជ្ជ៉ានមានព្រះមេត្តាសន្ធោសចំពោះពួកគេ ហើយបានអភ័យទោសឲ្យពួកគេ ។"
(التفسير المنسوب إلى الإمام العسكري عليه السلام 1: 247)

وَإِذۡ ءَاتَيۡنَا مُوسَى ٱلۡكِتَٰبَ وَٱلۡفُرۡقَانَ لَعَلَّكُمۡ تَهۡتَدُونَ ٥٣

٥٣. [ចូរនឹកឃើញ] កាលយើងបានប្រទានព្រះគម្ពីរនិងលក្ខណៈវិនិច្ឆ័យ [សម្រាប់វែកញែកឲ្យដឹងខុសត្រូវ]ឲ្យមូសា ដើម្បីពួកអ្នកនឹងអាចអនុចរនៅលើមាគ៌ាត្រឹមត្រូវ (ដឹកនាំខ្លួននៅលើមាគ៌ាព្រះធម៌) ។

អធិប្បាយអាយ៉ាស់ ៥៣

1/53. ثُمَّ قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿وَ إِذْ آتَيْنٰا مُوسَى اَلْكِتٰابَ وَ اَلْفُرْقٰانَ لَعَلَّكُمْ تَهْتَدُونَ﴾ قَالَ اَلْإِمَامُ عَلَيْهِ اَلسَّلاَمُ: وَ اُذْكُرُوا إِذْ آتَيْنَا مُوسَى اَلْكِتَابَ وَ هُوَ اَلتَّوْرَاةُ اَلَّذِي أَخَذَ عَلَى بَنِي إِسْرَائِيلَ اَلْإِيمَانَ بِهِ، وَ اَلِانْقِيَادَ لِمَا يُوجِبُهُ، وَ اَلْفُرْقَانَ آتَيْنَاهُ أَيْضاً فَرَّقَ بِهِ [مَا] بَيْنَ اَلْحَقِّ وَ اَلْبَاطِلِ، وَ فَرَّقَ [مَا] بَيْنَ اَلْمُحِقِّينَ وَ اَلْمُبْطِلِينَ.

៥៣/១. បន្ទាប់មកអល់ឡោះហ្ស៊ីវជ្ជ៉ានមានព្រះរាជបន្ទូលថា៖ *[២:៥៣] កាលយើងបានប្រទានព្រះគម្ពីរនិងលក្ខណៈវិនិច្ឆ័យឲ្យមូសាដើម្បីពួកអ្នកនឹងអាចអនុចរនៅលើមាគ៌ាត្រឹមត្រូវ ។* អ៊ីម៉ាំ صلوات الله عليه والسلام [អាល់-ហ្ការ៉ាសាន់ អាល់-អ៊ាស់ការី صلوات الله عليه والسلام] មានវចនៈថា៖ "ចូរនឹកឃើញកាលយើងបានប្រទានព្រះគម្ពីរឲ្យមូសាعليه السلام នោះគឺព្រះគម្ពីរតៅរ៉ាតដ៏ដែលកូនចៅអ៊ីសរ៉ាអ៊ីលសច្ចាថាជឿជាចាំបាច់ អនុវត្តតាមកាតព្វកិច្ចដែលមាននៅក្នុងនោះ ។ យើងជ្ជ៉ានបានប្រទានឲ្យដែរនូវលក្ខណៈវិនិច្ឆ័យ (អាល់-ហ្ហ៊ូ ក្ងន) ដើម្បីវែកញែកឲ្យដឹងថាអ្វីគឺសេចក្ដីពិតអ្វីគឺសេចក្ដីខុស និងវែកញែកឲ្យដឹងប្រជារាស្ត្រសច្ចៈនិងប្រជារាស្ត្រខុស ។

وَ ذَلِكَ أَنَّهُ لَمَّا أَكْرَمَهُمُ اَللَّهُ تَعَالَى بِالْكِتَابِ وَ اَلْإِيمَانِ بِهِ، وَ اَلِانْقِيَادِ لَهُ، أَوْحَى اَللَّهُ بَعْدَ ذَلِكَ إِلَى مُوسَى عَلَيْهِ السَّلاَمُ: يَا مُوسَى هَذَا اَلْكِتَابُ قَدْ أَقَرُّوا بِهِ، وَ قَدْ بَقِيَ اَلْفُرْقَانُ، فَرَّقَ مَا بَيْنَ اَلْمُؤْمِنِينَ وَ اَلْكَافِرِينَ، وَ اَلْمُحِقِّينَ وَ اَلْمُبْطِلِينَ، فَجَدِّدْ عَلَيْهِمُ اَلْعَهْدَ بِهِ، فَإِنِّي قَدْ آلَيْتُ عَلَى نَفْسِي قَسَماً حَقّاً لاَ أَتَقَبَّلُ مِنْ أَحَدٍ إِيمَاناً وَ لاَ عَمَلاً إِلاَّ مَعَ اَلْإِيمَانِ بِهِ.

ក្រោយពីបានលើកកិត្តិយសពួកគេដោយព្រះគម្ពីរ ដោយឲ្យពួកគេមានជំនឿលើព្រះគម្ពីរនោះ និងដោយឲ្យពួកគេអនុវត្តតាមព្រះគម្ពីរនោះ អល់ឡោះហ្ស៊ីវជ្ជ៉ានបានបើកឲ្យមូសាعليه السلامដឹងថា៖ "មូសាعليه السلامអើយ ! នេះគឺព្រះគម្ពីរ ។ ពួកគេព្រមទទួលព្រះគម្ពីរនេះហើយ តែនៅសល់លក្ខណៈវិនិច្ឆ័យដែលវែកញែកឲ្យដឹងថាអ្នកណាខ្លះមានសទ្ធាជ្រះថ្លា អ្នកណាខ្លះបដិសេធសទ្ធា អ្នកណាខ្លះជាអ្នកសច្ចៈនិងអ្នកណាខ្លះជាអ្នកបន្ទំ ។ ដូច្នេះចូរអ្នកعليه السلامប្រាប់ឲ្យពួកគេស្បថសាថ្មីរឿងនេះ ព្រោះអញជ្ជ៉ានបានស្បថនឹងខ្លួនអញជ្ជ៉ានថាអញជ្ជ៉ានមិនទទួលជំនឿ មិនទទួលទង្វើពីអ្នកណាមួយទេ លើកលែងតែអ្នកនោះជឿរឿងនេះផង ។

قَالَ مُوسَى عَلَيْهِ السَّلاَمُ: مَا هُوَ يَا رَبِّ؟ قَالَ اَللَّهُ عَزَّ وَ جَلَّ: يَا مُوسَى تَأْخُذُ عَلَى بَنِي إِسْرَائِيلَ: أَنَّ مُحَمَّداً خَيْرُ اَلْبَشَرِ وَ سَيِّدُ اَلْمُرْسَلِينَ. وَ أَنَّ أَخَاهُ وَ وَصِيَّهُ عَلِيّاً خَيْرُ اَلْوَصِيِّينَ. وَ أَنَّ أَوْلِيَاءَهُ اَلَّذِينَ يُقِيمُهُمْ سَادَةُ اَلْخَلْقِ. وَ أَنَّ شِيعَتَهُ اَلْمُنْقَادِينَ لَهُ، اَلْمُسَلِّمِينَ لَهُ وَ لِأَوَامِرِهِ وَ نَوَاهِيهِ وَ لِخُلَفَائِهِ، نُجُومُ اَلْفِرْدَوْسِ اَلْأَعْلَى وَ مُلُوكُ جَنَّاتِ عَدْنٍ.

មូសាعليه السلامបានទូលថា៖ "ម្ចាស់ជ្ជ៉ានអើយ ! អ្វីទៅរឿងនោះ (លក្ខណៈវិនិច្ឆ័យ) ?" អល់ឡោះហ្ស៊ីវជ្ជ៉ានមានព្រះ

រាជបន្ទូលថា: "មូសាﷺអើយ! ចូរអ្នកﷺឲ្យពួកកូនចៅអ៊ីសរ៉ាអ៊ីលស្បថ ថាមូហ្ហាំម៉ាដ្ធ:ﷺជាបុគ្គលប្រសើរដាច់អស់សត្វលោកទាំងឡាយ ជាព្រះរាជអគ្គមហាប្រមុខរបស់ព្រះសាស្ត្រាទាំងឡាយ ﷺ ថាអ៊ីលីﷺ ប្អូនប្រុសគេﷺ ព្រះឧត្តរាធិការីﷺ របស់គេﷺ នោះ ជាព្រះឧត្តរាធិការីប្រសើរដាច់អស់ព្រះឧត្តរាធិការីﷺ ថាព្រះមហាឧបរាជទាំងឡាយﷺ របស់ពួកគេﷺ ដែលព្រះអង្គﷻ បានតែងតាំងនោះ ជាអ្នកដឹកនាំប្រជារាស្ត្រ ថាស្ទ្រីអ៊ីសុ:ទាំងឡាយជាអ្នកស្តាប់បង្គាប់គេﷺ ជាអ្នកចូលខ្លួនចំពោះគេﷺ ជាអ្នកនៅក្រោមបង្គាប់គេﷺ ជាអ្នកធ្វើតាមបម្រាមគេﷺ ជាអ្នកចូលខ្លួនចំពោះខ្ញ:ុ ﷺ ។ ពួកគេﷺ ជាតារានៃឋានសួគ៌ខ្ពស់ត្រដែត អាល់-ហ្ជ្ជ៊ារដ្ជ:ាស៍ ជាមហាក្សត្ររបស់សួនសួគ៌បរមសុខទាំងឡាយ ។"

قَالَ: فَأَخَذَ عَلَيْهِمْ مُوسَى عَلَيْهِ السَّلاَمُ ذَلِكَ، فَمِنْهُمْ مَنِ اِعْتَقَدَهُ حَقّاً، وَ مِنْهُمْ مَنْ أَعْطَاهُ بِلِسَانِهِ دُونَ قَلْبِهِ، فَكَانَ اَلْمُعْتَقِدُ مِنْهُمْ حَقّاً يَلُوحُ عَلَى جَبِينِهِ نُورٌ مُبِينٌ وَ مَنْ أَعْطَى بِلِسَانِهِ دُونَ قَلْبِهِ لَيْسَ لَهُ ذَلِكَ اَلنُّورُ.

ព្រះអង្គﷺ មានវចន:ថា: "មូសាﷺ បានទទួលយកពាក្យសម្បថដូចនេះពីពួកគេ ។ នៅក្នុងចំណោមពួកគេនោះ អ្នកខ្លះជឿពិតប្រាកដ ឯអ្នកខ្លះទៀតគ្រាន់តែជឿតែមាត់ទេ ។ បណ្តាអ្នកដែលជឿពិតប្រាកដក្នុងចំណោមពួកគេនោះមានពន្លឺចែងចាំងពីលើថ្ងាសពួកគេ ឯពួកដែលគ្រាន់ជឿតែមាត់នោះមិនមានពន្លឺនោះទេ ។

فَذَلِكَ اَلْفُرْقَانُ اَلَّذِي أَعْطَاهُ اَللَّهُ عَزَّ وَ جَلَّ مُوسَى عَلَيْهِ السَّلاَمُ وَ هُوَ فَرَّقَ [مَا] بَيْنَ اَلْمُحِقِّينَ وَ اَلْمُبْطِلِينَ.

នោះគឺលក្ខណ:វិនិច្ឆ័យដែលអល់ឡោះហ្ហ:ﷻ បានប្រទានឲ្យមូសាﷺ ដើម្បីវែកញែកឲ្យដឹងថាអ្នកណាខ្លះជាអ្នកសច្ច:ស្មោះត្រង់ អ្នកណាខ្លះជាអ្នកខុស ។"

ثُمَّ قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿لَعَلَّكُمْ تَهْتَدُونَ﴾ أَيْ لَعَلَّكُمْ تَعْلَمُونَ أَنَّ اَلَّذِي [بِهِ] يُشَرِّفُ اَلْعَبْدَ عِنْدَ اَللَّهِ عَزَّ وَ جَلَّ هُوَ اِعْتِقَادُ اَلْوَلاَيَةِ، كَمَا شَرَّفَ بِهِ أَسْلاَفَكُمْ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 252)

បន្ទាប់មកអល់ឡោះហ្ហ:ﷻ មានព្រះរាជបន្ទូលថា: *ដើម្បីពួកអ្នកនឹងអាចអនុចរនៅលើមាគ៌ាត្រឹមត្រូវ* បានសេចក្តីថា ដើម្បីពួកអ្នកនឹងដឹងថាករណីដែលផ្តល់នូវកិត្យានុភាពឲ្យបាវបម្រើសម្រាប់អល់ឡោះហ្ហ:ﷻ នោះ គឺការជឿលើវីឡាយ៉ាសុ: ដូចដូនតាពួកអ្នកធ្លាប់បានទទួលនូវកិត្យានុភាពដោយសារវីឡាយ៉ាសុ: នោះដែរ ។ (التفسير المنسوب إلى الإمام العسكري عليه السلام 1: 252)

وَإِذْ قَالَ مُوسَىٰ لِقَوْمِهِۦ يَٰقَوْمِ إِنَّكُمْ ظَلَمْتُمْ أَنفُسَكُم بِٱتِّخَاذِكُمُ ٱلْعِجْلَ فَتُوبُوٓاْ إِلَىٰ بَارِئِكُمْ فَٱقْتُلُوٓاْ أَنفُسَكُمْ ذَٰلِكُمْ خَيْرٌ لَّكُمْ عِندَ بَارِئِكُمْ فَتَابَ عَلَيْكُمْ ۚ إِنَّهُۥ هُوَ ٱلتَّوَّابُ ٱلرَّحِيمُ ﴿٥٤﴾

៥៤. [ចូរនឹកឃើញ]កាលមូសាបានប្រាប់ប្រជាជាតិគេថា: "ប្រជាជាតិខ្ញ:ុអើយ! អស់លោកបានធ្វើខុសនឹងខ្លួនឯងដោយសារអស់លោកបានយកកូនគោបា[ជារូបបដិមាមកសក្ការ:] ។ អស់លោកចូរសូមស្មារលាទោសចំពោះព្រះអ្នកបង្កើតអស់លោក ។ [ពិរុទ្ធិកជនទាំងឡាយអើយ!] អស់លោកចូរសម្លាប់[គ្នាឯងដែលធ្វើខុសនោះ]ខ្លួនឯងទៅ! នោះគឺប្រការប្រសើរបំផុតសម្រាប់អស់លោកចំពោះព្រះអ្នកបង្កើតរបស់អស់លោក ។" ព្រះអង្គបានបែរមកករកពួកអ្នក [ដោយព្រះមេត្តាប្រណី] ។ ការពិតព្រះអង្គគឺព្រះដែលទទួលការស្មារលាទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី ។

អធិប្បាយអាយ៉ាស់ ៥៤

1/54. قَالَ اَلْإِمَامُ عَلَيْهِ اَلسَّلاَمُ: قَالَ اَللَّهُ عَزَّ وَ جَلَّ: وَ اُذْكُرُوا يَا بَنِي إِسْرَائِيلَ ﴿إِذْ قَالَ مُوسىٰ لِقَوْمِهِ﴾ عَبَدَةِ اَلْعِجْلِ ﴿يَا قَوْمِ إِنَّكُمْ ظَلَمْتُمْ أَنْفُسَكُمْ﴾ أَضْرَرْتُمْ بِهَا ﴿بِاتِّخَاذِكُمُ اَلْعِجْلَ﴾ إِلَهاً ﴿فَتُوبُوا إِلىٰ بَارِئِكُمْ﴾ اَلَّذِي بَرَّأَكُمْ وَ صَوَّرَكُمْ ﴿فَاقْتُلُوا أَنْفُسَكُمْ﴾ بِقَتْلِ بَعْضِكُمْ بَعْضاً، يَقْتُلُ مَنْ لَمْ يَعْبُدِ اَلْعِجْلَ مَنْ عَبَدَهُ

៥៤/១. អ៊ីមុាំ صلوات الله عليه والسلام [អាល់-ហ្ការ៉ាសាន់ អាល់-អ្ការ៉ាស់ការី صلوات الله عليه والسلام] មានវចន:ថាអល់ឡោះហ្ការ៉ា ﷻ មានព្រះរាជបន្ទូលថា: "កូនចៅអ៊ីសរ៉ាអ៊ីលអើយ! ពួកអ្នកចូរនឹកឃើញ *[២:៥៤] កាលមូសាបានប្រាប់ប្រជាជាតិគេ* ពួកសក្តារ:កូនគោបា *ថា: "ប្រជាជាតិខ្ញុំអើយ! អស់លោកបានធ្វើខុសនឹងខ្លួនឯង* ដោយធ្វើឲ្យខ្លួនឯងខូចខាត *ដោយសារអស់លោកបានយកកូនគោបា* ជាព្រះ *អស់លោកចូរសូមស្តារលោទោសចំពោះព្រះអ្នកបង្កើតអស់លោក* ដែលបានបង្កើតពួកលោក ឲ្យពួកលោកមានរូបរាង *អស់លោកចូរសម្លាប់ខ្លួនឯងទៅ!* ដោយសម្លាប់ពួកលោកមួយចំនួនដោយពួកលោកមួយចំនួនទៀត ឲ្យបណ្តាអ្នកដែលមិនបានសក្តារ:កូនគោបាសម្លាប់បណ្តាអ្នកដែលបានសក្តារ:កូនគោបា ។

﴿ذٰلِكُمْ خَيْرٌ لَكُمْ﴾ ذَلِكُمُ اَلْقَتْلُ خَيْرٌ لَكُمْ ﴿عِنْدَ بَارِئِكُمْ﴾ مِنْ أَنْ تَعِيشُوا فِي اَلدُّنْيَا وَ هُوَ لَمْ يَغْفِرْ لَكُمْ، فَيَتِمَّ فِي اَلْحَيَاةِ اَلدُّنْيَا حَيَاتُكُمْ وَ يَكُونَ إِلَى اَلنَّارِ مَصِيرُكُمْ، وَ إِذَا قُتِلْتُمْ وَ أَنْتُمْ تَائِبُونَ جَعَلَ اَللَّهُ عَزَّ وَ جَلَّ اَلْقَتْلَ كَفَّارَتَكُمْ، وَ جَعَلَ اَلْجَنَّةَ مَنْزِلَتَكُمْ وَ مَقِيلَكُمْ.

នោះគឺប្រការប្រសើរបំផុតសម្រាប់អស់លោក ការសម្លាប់នេះប្រសើរបំផុតសម្រាប់ពួកលោក *ចំពោះព្រះអ្នកបង្កើតរបស់អស់លោក* ជាងរស់នៅក្នុងលោកនេះដោយព្រះអង្គ ﷻ មិនអភ័យទោសឲ្យអស់លោកលុះអស់លោកអស់ជីវិត ជីវិតលោកនេះ បន្ទាប់ពីនោះអស់លោកនឹងទៅចូលភ្លើងនរក ។ បើពួកលោកធ្វើការកាប់សម្លាប់នេះ ហើយពួកលោកស្តារលោកំហុស អល់ឡោះហ្ការ៉ា ﷻ នឹងព្រមទទួលយកការសម្លាប់នេះជាការលោះខ្លួនលាងកំហុសពួកលោក ហើយព្រះអង្គ ﷻ នឹងទុកហានសូគ៌ជាទិសដៅអស់លោកជាទីស្នាក់អាស្រ័យ ។

ثُمَّ قَالَ اَللَّهُ عَزَّ وَ جَلَّ ﴿فَتَابَ عَلَيْكُمْ﴾ قَبْلَ تَوْبَتِكُمْ، قَبْلَ اِسْتِيفَاءِ اَلْقَتْلِ لِجَمَاعَتِكُمْ وَ قَبْلَ إِتْيَانِهِ عَلَى كَافَّتِكُمْ، وَ أَمْهَلَكُمْ لِلتَّوْبَةِ وَ اِسْتَبْقَاكُمْ لِلطَّاعَةِ ﴿إِنَّهُ هُوَ اَلتَّوَّابُ اَلرَّحِيمُ﴾

បន្ទាប់មកអល់ឡោះហ្ការ៉ា ﷻ មានព្រះរាជបន្ទូលថា: *ព្រះអង្គបានបែរមករកពួកអ្នក* មុនការស្តារលោកំហុសរបស់អស់លោក[បានចប់សព្វគ្រប់] មុនការចុះដៃធ្វើការសម្លាប់អស់លោក[ទាំងអស់] និងមុនការសម្លាប់នោះបានគ្រប់គ្រាន់ [ទើបព្រះអង្គ ﷻ ព្រមទទួលការសូមស្តារលោទោសរបស់ពួកអ្នក] ។ ព្រះអង្គ ﷻ ទុកពេលឲ្យពួកអ្នកដើម្បីស្តារលោទោសនិងទុកឲ្យពួកអ្នកមានជីវិតដើម្បីស្តាប់ឱវាទ *ការពិតព្រះអង្គគឺព្រះដែលទទួលការស្តារលោទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី ។*

قَالَ: وَ ذَلِكَ أَنَّ مُوسَى عَلَيْهِ السَّلاَمُ لَمَّا أَبْطَلَ اَللَّهُ عَزَّ وَ جَلَّ عَلَى يَدَيْهِ أَمْرَ اَلْعِجْلِ، فَأَنْطَقَهُ بِالْخَبَرِ عَنْ تَمْوِيهِ اَلسَّامِرِيِّ، فَأَمَرَ مُوسَى عَلَيْهِ السَّلاَمُ أَنْ يَقْتُلَ مَنْ لَمْ يَعْبُدْهُ مَنْ عَبَدَهُ، تَبَرَّأَ أَكْثَرُهُمْ وَ قَالُوا: لَمْ نَعْبُدْهُ.

ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា: "ពេលអល់ឡោះហ្ការ៉ា ﷻ បានធ្វើឲ្យការសក្តារ:កូនគោបាទៅជាមោយ:ដោយដៃមូសា عليه السلام អល់ឡោះហ្ការ៉ា ﷻ បានបញ្ជាវា (រូបកូនគោបា) ឲ្យអាចនិយាយបានដើម្បីប្រាប់ប្រជារាស្ត្រឲ្យដឹង

នូវការបោកបញ្ឆោតរបស់សាមីរីﷺ ។ មូសាﷺបានបញ្ជាឲ្យពួកដែលមិនបានសក្តារ:កូនគោបានោះ សម្លាប់ពួកដែលបានសក្តារ:វា តែពួកគេភាគច្រើនបានដោះខ្លួនថា: "យើងមិនបានសក្តារ:វាទេ ។"

فَقَالَ اَللَّهُ عَزَّ وَ جَلَّ لِمُوسَى عَلَيْهِ السَّلاَمُ: أُبْرُدْ هَذَا اَلْعِجْلَ اَلذَّهَبَ بِالْحَدِيدِ بَرْداً، ثُمَّ ذُرَّهُ فِي اَلْبَحْرِ، فَمَنْ شَرِبَ مِنْ مَائِهِ اِسْوَدَّتْ شَفَتَاهُ وَ أَنْفُهُ، وَ بَانَ ذَنْبُهُ. فَفَعَلَ فَبَانَ اَلْعَابِدُونَ لِلْعِجْلِ. فَأَمَرَ اَللَّهُ اِثْنَيْ عَشَرَ أَلْفاً أَنْ يَخْرُجُوا عَلَى اَلْبَاقِينَ شَاهِرِينَ اَلسُّيُوفَ يَقْتُلُونَهُمْ.

អល់ឡោះហ្ស៊ីﷻមានព្រះបន្ទូលនឹងមូសាﷺថា: "ចូរអ្នកﷺបំបែកកូនគោបានេះជាបំណែកដោយដែក ហើយយកបំណែកទាំងនោះទៅចោលក្នុងទន្លេ ។ អ្នកណាបានផឹកទឹកទន្លេនោះ បបូរមាត់និងច្រមុះអ្នកនោះនឹងទៅជាខ្មៅ វាបញ្ជាក់ឲ្យដឹងបាបកម្មរបស់ពួកគេ ។" ព្រះអង្គﷺបានធ្វើដូច្នេះ ។ ពួកសក្តារ:កូនគោបានលេចមុខច្បាស់ឡើង ។ អល់ឡោះហ្ស៊ីﷻបានបញ្ជាឲ្យពួកទាំងដប់ពីរពាន់នាក់[នោះដែលមិនបានសក្តារ:កូនគោ]ចេញទៅដោយកាន់ដាវ ហើយឲ្យសម្លាប់ពួកឯទៀតដែលនៅសល់នោះ [ដែលបានសក្តារ:កូនគោបា] ។

وَ نَادَى مُنَادِيهِ: أَلاَ لَعَنَ اَللَّهُ أَحَداً أَبْقَاهُمْ بِيَدٍ أَوْ رِجْلٍ، وَ لَعَنَ اَللَّهُ مَنْ تَأَمَّلَ اَلْمَقْتُولَ لَعَلَّهُ تَبَيَّنَهُ حَمِيماً أَوْ قَرِيباً فَيَتَوَقَّاهُ، وَ يَتَعَدَّاهُ إِلَى اَلْأَجْنَبِيِّ، فَاسْتَسْلَمَ اَلْمَقْتُولُونَ.

មានសម្លេងប្រកាសបន្លឺឡើងថា: "បណ្តាសារបស់អល់ឡោះហ្ស៊ីﷻពើបពះលើអ្នកណាដែលការពារខ្លួនពីការសម្លាប់ដោយដៃឬដោយជើងឯង ។ ព្រះបណ្តាសារបស់អល់ឡោះហ្ស៊ីﷻពើបពះលើអ្នកសម្លាប់ដែរ ដែលចៀសសម្លាប់ព្រោះតែអ្នកត្រូវសម្លាប់នោះជាអ្នកជំនិតនិងជាទីស្រឡាញ់របស់ខ្លួន ដែលសម្លាប់តែអ្នកណាដែលខ្លួនមិនស្គាល់ ។" ជនមានកំហុសបានចូលខ្លួនឲ្យគេសម្លាប់ ។

فَقَالَ اَلْقَاتِلُونَ: نَحْنُ أَعْظَمُ مُصِيبَةً مِنْهُمْ، نَقْتُلُ بِأَيْدِينَا آبَاءَنَا [وَ أُمَّهَاتِنَا] وَ أَبْنَاءَنَا وَ إِخْوَانَنَا وَ قَرَابَاتِنَا، وَ نَحْنُ لَمْ نَعْبُدْ، فَقَدْ سَاوَى بَيْنَنَا وَ بَيْنَهُمْ فِي اَلْمُصِيبَةِ. فَأَوْحَى اَللَّهُ تَعَالَى إِلَى مُوسَى: يَا مُوسَى [إِنِّي] إِنَّمَا اِمْتَحَنْتُهُمْ بِذَلِكَ لِأَنَّهُمْ (مَا اِعْتَزَلُوهُمْ لَمَّا عَبَدُوا اَلْعِجْلَ، وَ لَمْ) يَهْجُرُوهُمْ، وَ لَمْ يُعَادُوهُمْ عَلَى ذَلِكَ.

ពួកអ្នកសម្លាប់បានថា: "យើងពិបាកខ្លាំងជាងពួកគេទៅទៀត ។ យើងត្រូវតែសម្លាប់ឪពុកឯង ម្តាយឯង កូនឯង បងប្អូនឯង សាច់ញាតិឯងដោយដៃឯង ទោះបីយើងមិនបានសក្តារ:កូនគោបាក៏ដោយ ។ យើងក៏ដូចពួកគេដែរក្នុងទណ្ឌកម្មនេះ ។" អល់ឡោះហ្ស៊ីﷻបានបើកឲ្យមូសាﷺដឹងថា: "មូសាﷺអើយ! អញﷻបានធ្វើដូច្នេះដើម្បីល្បងពិសោធពួកគេព្រោះ ពេលពួកគេនោះបានសក្តារ:កូនគោបា ពួកឯទៀតមិនបានដោះខ្លួនចេញពីពួកប្រព្រឹត្តអំពើបាបទេ មិនបានទៅជាសត្រូវរបស់ពួកគេនោះទេដែលបានប្រព្រឹត្តប្រការនេះ ។"

قُلْ لَهُمْ: مَنْ دَعَا اَللَّهَ بِمُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ، يُسَهَّلُ عَلَيْهِ قَتْلُ اَلْمُسْتَحِقِّينَ لِلْقَتْلِ بِذُنُوبِهِمْ. فَقَالُوهَا، فَسُهِّلَ عَلَيْهِمْ [ذَلِكَ]، وَ لَمْ يَجِدُوا لِقَتْلِهِمْ لَهُمْ أَلَماً. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 254)

ព្រះអង្គﷺបានប្រាប់ពួកគេថា: "អ្នកណាបានបួងសួងអល់ឡោះហ្ស៊ីﷻតាមរយ:មូហ្ហាំម៉ាដ្ឋﷺនិងបណ្តាកូនចៅបរិសុទ្ធﷺរបស់ព្រះអង្គﷺ វានឹងទៅជាងាយស្រួលសម្រាប់អ្នកនោះក្នុងការសម្លាប់ពួកទាំងនោះដែលតម្រូវឲ្យសម្លាប់ដោយសារពួកគេបានសាងបាបកម្ម ។" ពួកគេបានសូត្របែបនេះ វាក៏ទៅជាងាយស្រួលសម្រាប់ពួកគេ ពួកគេមិនមានអារម្មណ៍ឈឺចាប់ទេពេលសម្លាប់ពួកគេទាំងនោះ ។"

(التفسير المنسوب إلى الإمام العسكري عليه السلام 1: 254)

وَإِذْ قُلْتُمْ يَـٰمُوسَىٰ لَن نُّؤْمِنَ لَكَ حَتَّىٰ نَرَى ٱللَّهَ جَهْرَةً فَأَخَذَتْكُمُ ٱلصَّـٰعِقَةُ وَأَنتُمْ تَنظُرُونَ ﴿٥٥﴾

៥៥. [ចូរនឹកឃើញ]កាលពួកអ្នកបានថា៖ "មូសាអើយ ! ដរាបណាយើងមិនបានឃើញអល់ឡោះហ្ន៑ជាក់ស្តែងទេ (ឃើញរូបអល់ឡោះហ្ន៑ពិត) ដរាបនោះយើងមិនជឿលោកទេ !" រន្ទះបានបាញ់ពួកអ្នកក្នុងពេលដែលពួកអ្នកកំពុងសម្លឹងមើល ។

ثُمَّ بَعَثْنَـٰكُم مِّنۢ بَعْدِ مَوْتِكُمْ لَعَلَّكُمْ تَشْكُرُونَ ﴿٥٦﴾

៥៦. បន្ទាប់មកយើងបានឲ្យពួកអ្នករស់វិញក្រោយពីការស្លាប់របស់ពួកអ្នក ដើម្បីនឹងឲ្យពួកអ្នកដឹងគុណ ។

អធិប្បាយអាយ៉ាស់ ៥៥-៥៦

55–1/56. قَالَ: أَسْلاَفُكُمْ ﴿فَأَخَذَتْكُمُ اَلصّاعِقَةُ﴾ أَخَذَتْ أَسْلاَفَكُمُ [اَلصَّاعِقَةُ] ﴿وَ أَنْتُمْ تَنْظُرُونَ﴾ إِلَيْهِمْ ﴿ثُمَّ بَعَثْنَاكُمْ﴾ بَعَثْنَا أَسْلاَفَكُمْ ﴿مِنْ بَعْدِ مَوْتِكُمْ﴾ مِنْ بَعْدِ مَوْتِ أَسْلاَفِكُمْ ﴿لَعَلَّكُمْ تَشْكُرُونَ﴾ [اَلْحَيَاةَ] أَيْ لَعَلَّ أَسْلاَفَكُمْ يَشْكُرُونَ اَلْحَيَاةَ، اَلَّتِي فِيهَا يَتُوبُونَ وَ يُقْلِعُونَ، وَ إِلَى رَبِّهِمْ يُنِيبُونَ، لَمْ يُدِمْ عَلَيْهِمْ ذَلِكَ اَلْمَوْتَ فَيَكُونَ إِلَى اَلنَّارِ مَصِيرُهُمْ، وَ هُمْ فِيهَا خَالِدُونَ.

៥៥-៥៦/១. ព្រះអង្គ صلوات الله عليه والسلام (អ៊ីមុាំ អាល់-ហ្ការ៉ាសាន់ អាល់-អ៊ុ្ចស់ការី صلوات الله عليه والسلام) មានវចនៈថា៖ *"[២:៥៥] រន្ទះបានបាញ់ពួកអ្នក* ដូនតាពួកអ្នកត្រូវប្រហារដោយរន្ទះ *ក្នុងពេលដែលពួកអ្នកកំពុងសម្លឹងមើល* ពួកគេ ។ *បន្ទាប់មកយើងបានឲ្យពួកអ្នករស់វិញ* ឲ្យដូនតាពួកអ្នករស់ឡើងវិញ *ក្រោយពីការស្លាប់របស់ពួកអ្នក* ក្រោយពីការស្លាប់របស់ដូនតាពួកអ្នក *ដើម្បីនឹងឲ្យពួកអ្នកដឹងគុណ* ដែលមានជីវិត មានន័យថាឲ្យដូនតាពួកអ្នកដឹងគុណដែលមានជីវិតឡើងវិញ ដើម្បីស្នារលាទោសកន្លងមកនិងកែខ្លួន ត្រឡប់មករកម្ចាស់ ﷻ ពួកគេវិញ ដោយដឹងខ្លួនថាបើការស្លាប់ដំបូងរបស់ពួកគេជាការស្លាប់អចិន្ត្រៃយ៍ ពួកគេប្រាកដជាត្រូវចូលភ្លើងនរក នៅក្នុងនោះជានិច្ចអនន្ត ។

قَالَ[اَلْإِمَامُ عَلَيْهِ اَلسَّلاَمُ:] وَ ذَلِكَ أَنَّ مُوسَى عَلَيْهِ السَّلاَمُ لَمَّا أَرَادَ أَنْ يَأْخُذَ عَلَيْهِمْ عَهْداً بِالْفُرْقَانِ [فَرَّقَ] مَا بَيْنَ اَلْمُحِقِّينَ وَ اَلْمُبْطِلِينَ لِمُحَمَّدٍ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ بِنُبُوَّتِهِ وَ لِعَلِيٍّ عَلَيْهِ السَّلاَمُ بِإِمَامَتِهِ، وَ لِلْأَئِمَّةِ اَلطَّاهِرِينَ بِإِمَامَتِهِمْ، قَالُوا: ﴿لَنْ نُؤْمِنَ لَكَ﴾ أَنَّ هَذَا أَمْرُ رَبِّكَ ﴿حَتَّى نَرَى اَللّٰهَ جَهْرَةً﴾ عِيَاناً يُخْبِرُنَا بِذَلِكَ. فَأَخَذَتْهُمُ اَلصَّاعِقَةُ مُعَايَنَةً وَ هُمْ يَنْظُرُونَ إِلَى اَلصَّاعِقَةِ تَنْزِلُ عَلَيْهِمْ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 256)

អ៊ីមុាំ [អាល់-ហ្ការ៉ាសាន់ អាល់-អ៊ុ្ចស់ការី صلوات الله عليه والسلام] មានវចនៈថា៖ "កាលនោះមូសា عليه السلام ចង់បានកតិកាសញ្ញាពីពួកគេដោយឲ្យពួកគេជឿលក្ខណៈវិនិច្ឆ័យ (អាល់-ហ្ហ ូ ក្ន) ដែលវែកញែកឲ្យដឹងថាអ្នកណាខ្លះជាអ្នកត្រឹមត្រូវនិងអ្នកណាខ្លះជាអ្នកបន្ទំរឿងមូហ្ហាំម៉ាដ្ធ صلى الله عليه وآله وسلم ជាមួយតំណែងសាស្ត្ររបស់ព្រះអង្គ صلى الله عليه وسلم រឿងអ៊ុ្ចលី عليه السلام ជាមួយអ៊ីម៉ាម៉ាស់ព្រះអង្គ صلوات الله عليه والسلام និងរឿងអ៊ីមុាំ عليهم السلام បរិសុទ្ធជាមួយអ៊ីម៉ាម៉ាស់ព្រះអង្គ عليهم السلام នោះ ពួកគេបានថា៖ *"យើងមិនជឿលោកទេ* ថានេះជាព្រះបញ្ជារបស់ម្ចាស់ ﷻ លោក عليه السلام *ដរាបណាយើងមិនបានឃើញអល់ឡោះហ្ន៑ជាក់ស្តែងទេ* ទាល់តែយើងបានឃើញព្រះអង្គ ﷻ ប្រទានដំណឹងនេះមកឲ្យយើងផ្ទាល់ភ្នែក ។ ដូច្នេះរន្ទះបានបាញ់ពួកគេ ។ ពួកគេបានសម្លឹងមើលទៅឯរន្ទះដែលកំពុងចុះមករកពួក ។"

(التفسير المنسوب إلى الإمام العسكري عليه السلام 1: 256)

***

2/56-55. وَ قَالَ اَللَّهُ عَزَّ وَ جَلَّ: يَا مُوسَى إِنِّي أَنَا اَلْمُكَرَّمُ لِأَوْلِيَائِي، اَلْمُصَدِّقِينَ بِأَصْفِيَائِي وَ لاَ أُبَالِي، وَ كَذَلِكَ أَنَا اَلْمُعَذِّبُ لِأَعْدَائِي، اَلدَّافِعِينَ حُقُوقَ أَصْفِيَائِي وَ لاَ أُبَالِي.

៥៥-៥៦/២. អល់ឡោះហ្ស៊ីមានព្រះបន្ទូលថា៖ "មូសាអ៊ីយ! អញលើកតម្កើងមិត្តទាំងឡាយរបស់អញ បណ្តាអ្នកដែលព្រមទទួលស្គាល់អភិបុគ្គលទាំងឡាយរបស់អញ អញមិនខ្វល់[ពួកធ្វើអាក្រក់]ទេ។ ដូចគ្នាដែរ អញធ្វើទោសសត្រូវរបស់អញ ពួកដែលច្រានចោលសិទ្ធិរបស់អភិបុគ្គលទាំងឡាយរបស់អញ អញមិនខ្វល់ទេ។"

فَقَالَ مُوسَى عَلَيْهِ السَّلاَمُ لِلْبَاقِينَ اَلَّذِينَ لَمْ يَصْعَقُوا: مَا ذَا تَقُولُونَ؟ أَ تَقْبَلُونَ وَ تَعْتَرِفُونَ؟ وَ إِلاَّ فَأَنْتُمْ هَؤُلاَءِ لاَحِقُونَ.

មូសាបានប្រាប់ពួកឯទៀតដែលមិនត្រូវរន្ទះបាញ់ថា៖ "អស់លោកនឹងថាអ្វី ? អស់លោកព្រមទទួលស្គាល់ទេ ឬក៏អស់លោកចង់បានជោគវាសនាដូចបក្សពួកអស់លោក ?"

قَالُوا: يَا مُوسَى لاَ نَدْرِي مَا حَلَّ بِهِمْ وَ لِمَا ذَا أَصَابَتْهُمْ؟ كَانَتِ اَلصَّاعِقَةُ مَا أَصَابَتْهُمْ لِأَجْلِكَ، إِلاَّ أَنَّهَا كَانَتْ نَكْبَةً مِنْ نَكَبَاتِ اَلدَّهْرِ تُصِيبُ اَلْبَرَّ وَ اَلْفَاجِرَ،

ពួកគេបានថា៖ "មូសាអ៊ីយ! យើងមិនដឹងអ្វីកើតដល់ពួកគេទេ ហេតុអ្វីពួកគេត្រូវរន្ទះបាញ់នោះទេ។ ដែលរន្ទះបាញ់ពួកគេនោះមិនមែនដោយសារលោកទេ។ នេះដូចមហន្តរាយមួយក្នុងចំណោមមហន្តរាយក្នុងលោកនេះដែលវាយប្រហារទាំងមនុស្សល្អ ទាំងមនុស្សអាក្រក់ដែរ។

فَإِنْ كَانَتْ إِنَّمَا أَصَابَتْهُمْ لِرَدِّهِمْ عَلَيْكَ فِي أَمْرِ مُحَمَّدٍ وَ عَلِيٍّ وَ آلِهِمَا فَاسْأَلِ اَللَّهَ رَبَّكَ بِمُحَمَّدٍ وَ آلِهِ هَؤُلاَءِ اَلَّذِينَ تَدْعُونَا إِلَيْهِمْ أَنْ يُحْيِيَ هَؤُلاَءِ اَلْمَصْعُوقِينَ لِنَسْأَلَهُمْ لِمَا ذَا أَصَابَهُمْ [مَا أَصَابَهُمْ].

បើរន្ទះបាញ់ពួកគេដោយសារតែមិនព្រមជឿសម្តីលោករឿងមូហ្ហាម៉ាដ្ធ ﷺ រឿងអ្ហ្ម៉ាលី និងបណ្តាកូនចៅពួកគេមែនោះ លោកចូរសូមអល់ឡោះហ្ស៊ីម្ចាស់លោក ក្នុងនាមមូហ្ហាម៉ាដ្ធ ﷺ និងបណ្តាកូនចៅគេ ﷺ ដែលលោកឲ្យយើងជឿនោះ ឲ្យព្រះអង្គប្រសិទ្ធិពួកគេឲ្យរស់ឡើងវិញ ជនទាំងនោះដែលត្រូវរន្ទះបាញ់ស្លាប់ ដើម្បីយើងនឹងសួរពួកគេថាហេតុអ្វីពួកគេត្រូវ អ្វីបានប្រហារពួកគេ។"

فَدَعَا اَللَّهَ عَزَّ وَ جَلَّ بِهِمْ مُوسَى عَلَيْهِ السَّلاَمُ، فَأَحْيَاهُمُ اَللَّهُ عَزَّ وَ جَلَّ فَقَالَ مُوسَى عَلَيْهِ السَّلاَمُ: سَلُوهُمُ لِمَا ذَا أَصَابَهُمْ؟ فَسَأَلُوهُمْ، فَقَالُوا: يَا بَنِي إِسْرَائِيلَ أَصَابَنَا مَا أَصَابَنَا لِإِبَائِنَا اِعْتِقَادَ إِمَامَةِ عَلِيٍّ بَعْدَ اِعْتِقَادِنَا بِنُبُوَّةِ مُحَمَّدٍ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ

មូសាបានបួងសួងអល់ឡោះហ្ស៊ីតាមរយៈអល់ព្រះអង្គ អល់ឡោះហ្ស៊ីក៏បានឲ្យពួកគេរស់ឡើងវិញ។ មូសាបានថា៖ "ចូរសួរពួកគេទៅ ហេតុពួកគេត្រូវរន្ទះបាញ់។" ពួកគេបានសួរពួកដែលរស់ឡើងវិញ។ ពួកគេបានថា៖ "កូនចៅអ៊ីសរ៉ាអ៊ីលអ៊ីយ! មហន្តរាយនេះបានពើបពះលើយើងមកពីយើងមិនព្រមជឿអ៊ីម៉ាម៉ាស៊ូរបស់អ្ហ្ម៉ាលីក្រោយពីបានជឿតំណែងសាស្តារបស់មូហ្ហាម៉ាដ្ធ ﷺ។

لَقَدْ رَأَيْنَا بَعْدَ مَوْتِنَا هَذَا مَمَالِكَ رَبِّنَا مِنْ سَمَاوَاتِهِ وَ حُجُبِهِ وَ عَرْشِهِ وَ كُرْسِيِّهِ وَ جِنَانِهِ وَ نِيرَانِهِ، فَمَا رَأَيْنَا أَنْفَذَ أَمْراً فِي جَمِيعِ تِلْكَ اَلْمَمَالِكِ

وَ أَعْظَمَ سُلْطَاناً مِنْ مُحَمَّدٍ وَ عَلِيٍّ وَ فَاطِمَةَ وَ اَلْحَسَنِ وَ اَلْحُسَيْنِ عَلَيْهِمُ اَلسَّلاَمُ،

បន្ទាប់ពីយើងបានស្លាប់ យើងបានឃើញនៅក្នុងព្រះរាជាណាចក្រ របស់ម្ចាស់ﷻយើង មេឃទាំងឡាយ ព្រះរបាំងទាំងឡាយ ព្រះរាជបល្ល័ង្គ ព្រះអាសនៈ សួនសួគ៌ទាំងឡាយ និងឋាននរកទាំងឡាយរបស់ព្រះអង្គﷻនោះ ពុំមានអ្នកណាសោយរាជ្យខ្ពស់ជាងមូហាំម៉ាដ់ﷺ អាលី صلوات الله عليه والسلام ហ្វាទីម៉ាស់ سلام الله عليها អាល់-ហាសាន់ صلوات الله عليه والسلام និងអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ទេ ។

وَ إِنَّا لَمَّا مِتْنَا بِهَذِهِ اَلصَّاعِقَةِ ذُهِبَ بِنَا إِلَى اَلنِّيرَانِ. فَنَادَاهُمْ مُحَمَّدٌ وَ عَلِيٌّ عَلَيْهِ اَلسَّلاَمُ: كُفُّوا عَنْ هَؤُلاَءِ عَذَابَكُمْ، فَهَؤُلاَءِ يُحْيَوْنَ بِمَسْأَلَةِ سَائِلٍ [يَسْأَلُ] رَبَّنَا عَزَّ وَ جَلَّ بِنَا وَ بِآلِنَا اَلطَّيِّبِينَ. وَ ذَلِكَ حِينَ لَمْ يَقْذِفُونَا [بَعْدُ] فِي اَلْهَاوِيَةِ، وَ أَخَّرُونَا إِلَى أَنْ بُعِثْنَا بِدُعَائِكَ يَا مُوسَى بْنَ عِمْرَانَ بِمُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ.

កាលយើងបានស្លាប់ដោយសាររន្ទះបាញ់នេះ ពួកទេវតាបាននាំយើងទៅឋាននរក តែមូហាំម៉ាដ់ﷺ និងអាលី صلوات الله عليه والسلام សូមពរជ័យសិរីសួស្តីមានដល់ព្រះអង្គ عليهم السلام ទាំងពីរ បានស្រែកប្រាប់ពួកទេវតាថា៖ "សូមបញ្ឈប់ការធ្វើទណ្ឌកម្មពួកគេនេះភ្លាម ! ពួកគេនឹងរស់វិញពេលណាអ្នកបួងសួងនឹងបួងសួងម្ចាស់ﷻយើង عليهم السلام តាមរយៈយើង عليهم السلام និងកូនចៅបរិសុទ្ធ عليهم السلام យើង ។" ពួកទេវតាក៏បានឈប់ មិនបោះយើងទៅក្នុងរណ្តៅជ្រៅទេ ហើយឲ្យយើងរង់ចាំទាល់តែព្រះអង្គ عليه السلام មូសា عليه السلام ប៊ិន អ៊ីមរ៉ានអើយ ! បានបួងសួងសូមឲ្យអស់ទូលបង្គំរស់វិញតាមរយៈមូហាំម៉ាដ់ﷺ និងកូនចៅបរិសុទ្ធ عليهم السلام របស់ព្រះអង្គﷺ ។"

فَقَالَ اَللَّهُ عَزَّ وَ جَلَّ لِأَهْلِ عَصْرِ مُحَمَّدٍ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ: فَإِذَا كَانَ بِالدُّعَاءِ بِمُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ نَشَرَ ظُلْمَةُ أَسْلاَفِكُمُ اَلْمَصْعُوقِينَ بِظُلْمِهِمْ أَ فَمَا يَجِبُ عَلَيْكُمْ أَنْ لاَ تَتَعَرَّضُوا لِمِثْلِ مَا هَلَكُوا بِهِ إِلَى أَنْ أَحْيَاهُمُ اَللَّهُ عَزَّ وَ جَلَّ؟ (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 256)

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលនឹងប្រជានិករក្នុងសម័យកាលរបស់មូហាំម៉ាដ់ﷺថា៖ "កាលអល់ឡោះហ្ទ៍ﷻបានលើកទោសឲ្យដូនតាពួកអ្នកដែលបានសាងបាប ដោយសារតែបួងសួងតាមរយៈមូហាំម៉ាដ់ﷺ និងបណ្តាកូនចៅបរិសុទ្ធ عليهم السلام របស់គេﷺ ពួកគេបានរស់វិញក្រោយពីបានស្លាប់ដោយសារត្រូវរន្ទះបាញ់ ។ ពួកអ្នកចាំបាច់ត្រូវតែមិនប្រព្រឹត្តអំពើដែលដូនតាពួកអ្នកបានប្រព្រឹត្តរួចមកហើយ ដោយសារទង្វើអាក្រក់នោះឯងដែលពួកគេរងទុក្ខនិងត្រូវកម្ទេចចោល ។"

(التفسير المنسوب إلى الإمام العسكري عليه السلام 1: 256)

***

55-3/56. سَعْدُ بْنُ عَبْدِ اللَّهِ: عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ عِيسَى، عَنِ الْحَسَنِ بْنِ عَلِيِّ بْنِ فَضَّالٍ، عَنِ الْحُسَيْنِ بْنِ عُلْوَانَ، عَنْ مُحَمَّدِ بْنِ دَاوُدَ الْعَبْدِيِّ، عَنِ الْأَصْبَغِ بْنِ نُبَاتَةَ، عَنْ أَمِيرِ الْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ)- فِي كَلاَمِهِ لِابْنِ الْكَوَّاءِ- قَالَ لَهُ: «اسْأَلْ عَمَّا بَدَا لَكَ». فَقَالَ: نَعَمْ، إِنَّ أُنَاساً مِنْ أَصْحَابِكَ يَزْعُمُونَ أَنَّهُمْ يُرَدُّونَ بَعْدَ الْمَوْتِ؟ فَقَالَ أَمِيرُ الْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ): «نَعَمْ، تَكَلَّمْ بِمَا سَمِعْتَ، وَ لاَ تَزِدْ فِي الْكَلاَمِ، فَمَا قُلْتَ لَهُمْ».

៥៥-៥៦/៣. សាអុដ់ ប៊ិន អុប់ឌុលឡោះហ្ទ៍ បានតំណាលតមកពី អាស់ម៉ាដ់ ប៊ិន មូហាំម៉ាដ់ ប៊ិន អ៊ីសា តមកពី អាល់-ហាសាន់ ប៊ិន អាលី ប៊ិន ហ្វាដ្ឋល់ តមកពី អាល់-ហ៊ូសែន៍ ប៊ិន អ៊ុលវ៉ាន តមកពី មូហាំម៉ាដ់ ប៊ិន ដាវុដ អាល់-អុប់ឌី តមកពី អាល់-អាស្វ៉បាក់ ប៊ិន នូបាតាស់ តមកពី អាមីរុល-មមីនីន صلوات الله عليه والسلام នៅក្នុងព្រះវចនៈព្រះអង្គ صلوات الله عليه والسلام ទៅកាន់ អ៊ីបនូ អាល់-កាវ៉អ៍ ។ ព្រះអង្គ صلوات الله عليه والسلام មានវចនៈប្រាប់លោកថា៖ "សូមលោកសួរមកចុះអ្វីដែលកើតមានដល់លោកនោះ ។" លោកបានថា៖ "បពិត្រ ។ សាវកមួយចំនួនរបស់

ព្រះអង្គ ﷺ បានអះអាងថាពួកគេនឹងត្រឡប់វិញក្រោយពីស្លាប់ ។" អាមីរុល-មុមីនីន ﷺ មានវចន:ថា: "មែន ។ សូមលោកនិយាយអ្វីដែលលោកបានឮនោះទៅ ចូរកុំបំផ្លើសសម្ដី ។ តើលោកបានប្រាប់ពួកគេ វិញអ្វីខ្លះ ?"

قَالَ: قُلْتُ: لاَ أُؤْمِنُ بِشَيْءٍ مِمَّا قُلْتُمْ؟ فَقَالَ لَهُ أَمِيرُ الْمُؤْمِنِينَ (صَلَوَاتُ اللهِ عَلَيْهِ): «وَيْلَكَ، إِنَّ اللهَ عَزَّ وَ جَلَّ ابْتَلَى قَوْماً بِمَا كَانَ مِنْ ذُنُوبِهِمْ، فَأَمَاتَهُمْ قَبْلَ آجَالِهِمُ الَّتِي سُمِّيَتْ لَهُمْ، ثُمَّ رَدَّهُمْ إِلَى الدُّنْيَا لِيَسْتَوْفُوا رِزْقَهُمْ، ثُمَّ أَمَاتَهُمْ بَعْدَ ذَلِكَ».

លោក (អ៊ីបនូ អាល់-ការ៉ាអ៊ូ) បានថា: "ទូលបង្គំបានថា: "ខ្ញុំមិនជឿអ្វីដែលអស់លោកថានោះទេ ។"" អាមីរុល-មុមីនីន ﷺ មានវចន:ថា: "អពមង្គលលើលោក ! អល់ទ្បោះហ្ស៊ូ ﷻ បានល្បងពិសោធប្រជារាស្ត្រ មួយដោយសារពួកគេបានសាងបាបកម្ម ។ ព្រះអង្គ ﷻ បានសម្លាប់ពួកគេមុនកាលបរិច្ឆេទដែលគេបាន កាលកំណត់ឲ្យពួកគេ បន្ទាប់មកព្រះអង្គ ﷻ ឲ្យពួកគេត្រឡប់មកលោកនេះវិញ ព្រះអង្គ ﷻ បានផ្ដល់គ្រឿង ទ្រទ្រង់ជីវិតឲ្យពួកគេ ហើយបានសម្លាប់ពួកគេក្រោយពីនោះ ។"

قَالَ: فَكَبُرَ عَلَى ابْنِ الْكَوَّاءِ وَ لَمْ يَهْتَدِ لَهُ، فَقَالَ لَهُ أَمِيرُ الْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ): «وَيْلَكَ تَعْلَمُ أَنَّ اللهَ عَزَّ وَ جَلَّ قَالَ فِي كِتَابِهِ: ﴿وَ اخْتَارَ مُوسىٰ قَوْمَهُ سَبْعِينَ رَجُلاً لِمِيقَاتِنَا﴾ فَانْطَلَقَ بِهِمْ لِيَشْهَدُوا لَهُ إِذَا رَجَعُوا عِنْدَ الْمَلإِ مِنْ بَنِي إِسْرَائِيلَ أَنَّ رَبِّي قَدْ كَلَّمَنِي،

លោក[អ្នកអធិប្បាយ]បានថា: "រឿងនេះបានធ្វើឲ្យ អ៊ីបនូ អាល់-ការ៉ាអ៊ូ បារម្ភ ហើយមិនត្រូវគេដឹកនាំ ក្នុងរឿងនេះទេ ។" ដូច្នេះអាមីរុល-មុមីនីន ﷺ បានប្រាប់គាត់ថា: "អពមង្គលលើលោក ! លោកដឹងទេ ថាអល់ទ្បោះហ្ស៊ូ ﷻ មានព្រះរាជបន្ទូលនៅក្នុងព្រះគម្ពីរព្រះអង្គ ﷻ ថា *[៧:១៥៥] មូសាបានជ្រើសយកបុរស ចិតសិបនាក់ ក្នុងបណ្ដាប្រជាជាតិគេ ដើម្បី[ចូលរួមជាមួយ]ការណាត់ជួបយើង ។* ព្រះអង្គ ﷺ ក៏បាន ទៅជាមួយពួកគេ ដើម្បីជាសាក្សីឲ្យព្រះអង្គ ﷺ ចំពោះមហាជនកូនចៅអ៊ីសរ៉ាអ៊ីលពេលពួកគេត្រឡប់ មកវិញ [មូសា ﷺ មានវចន:]ថា: "ម្ចាស់ ﷻ ខ្ញុំ ﷺ បាននិយាយរកខ្ញុំ ﷺ ។"

فَلَوْ أَنَّهُمْ سَلَّمُوا ذَلِكَ لَهُ وَ صَدَّقُوهُ لَكَانَ خَيْراً لَهُمْ، وَ لَكِنَّهُمْ قَالُوا لِمُوسَى (عَلَيْهِ السَّلاَمُ): ﴿لَنْ نُؤْمِنَ لَكَ حَتَّى نَرَى اللهَ جَهْرَةً﴾ قَالَ اللهُ عَزَّ وَ جَلَّ: ﴿فَأَخَذَتْكُمُ الصَّاعِقَةُ﴾ يَعْنِي الْمَوْتَ ﴿وَ أَنْتُمْ تَنْظُرُونَ * ثُمَّ بَعَثْنَاكُمْ مِنْ بَعْدِ مَوْتِكُمْ لَعَلَّكُمْ تَشْكُرُونَ﴾ فَتَرَى- يَا ابْنَ الْكَوَّاءِ- أَنَّ هَؤُلاَءِ رَجَعُوا إِلَى مَنَازِلِهِمْ بَعْدَ مَا مَاتُوا؟».

បើពួកគេបានជឿរឿងនេះសប់ចិត្ត បានទទួលស្គាល់ថាព្រះអង្គ ﷺ និយាយពិតមែននោះវាជាការល្អ ប្រសើរសម្រាប់ពួកគេ តែពួកគេបែរជាប្រាប់មូសា ﷺ ថា: *"[២:៥៥] ដរាបណាយើងមិនបានឃើញ អល់ទ្បោះហ្ស៊ូជាក់ស្ដែងទេ ដរាបនោះយើងមិនជឿលោកទេ !"* អល់ទ្បោះហ្ស៊ូ ﷻ មានព្រះរាជបន្ទូលថា: *"[២:៥៥] រន្ទះបានបាញ់ពួកអ្នក"* មានន័យថាការស្លាប់ *ក្នុងពេលដែលពួកអ្នកកំពុងសម្លឹងមើល ។ [២:៥៦] បន្ទាប់មកយើងបានឲ្យពួកអ្នករស់វិញក្រោយពីការស្លាប់របស់ពួកអ្នក ដើម្បីនឹងឲ្យពួកអ្នកដឹង គុណ ។* ដូច្នេះ អ៊ីបនូ អាល់-ការ៉ាអ៊ូអ៊ីយ ! លោកមិនឃើញទេថាពួកគេបានត្រឡប់ទៅផ្ទះពួកគេវិញ បន្ទាប់ពីបានស្លាប់ ?"

فَقَالَ ابْنُ الْكَوَّاءِ: وَ مَا ذَلِكَ، ثُمَّ أَمَاتَهُمْ مَكَانَهُمْ؟ فَقَالَ لَهُ أَمِيرُ الْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ): «لاَ، وَيْلَكَ! أَ وَ لَيْسَ قَدْ أَخْبَرَكَ فِي كِتَابِ اللهِ حَيْثُ يَقُولُ: ﴿وَ ظَلَّلْنَا عَلَيْكُمُ الْغَمَامَ وَ أَنْزَلْنَا عَلَيْكُمُ الْمَنَّ وَ السَّلْوىٰ﴾؟ فَهَذَا بَعْدَ الْمَوْتِ إِذْ بَعَثَهُمْ». (البرهان في تفسير القرآن ١ – الجزء : ١ صفحة : ٢٢١ الحديث : ٩٩/ ٤٧٩ ، مختصر بصائر الدرجات – الجزء : ١ صفحة : ٢٢)**

អ៊ីបនូ អាល់-ការ៉ាអ៌ បានថា៖ "តើនោះគឺអ្វី ដែលបានសម្លាប់ពួកគេនៅកន្លែងពួកគេ ?" អាមីរុល-មុមីនីន صلوات الله عليه والسلام បានប្រាប់គាត់ថា៖ "ទេ អពមង្គលលើលោក ! ព្រះអង្គ عز وجل មិនបានប្រាប់ឲ្យលោកដឹងទេនៅក្នុងព្រះគម្ពីរអល់ឡោះហ្ស៊ូ عز وجل ត្រង់កន្លែងព្រះអង្គ عز وجل មានព្រះរាជបន្ទូលថា *[២:៥៧] យើងបានឲ្យពពកផ្តល់ម្លប់លើពួកអ្នក យើងបានចាត់បញ្ជូនអាល់-ម៉ាននិងក្រូចមកឲ្យពួកអ្នក* ? នេះគឺអ្វីដែលបានកើតឡើងបន្ទាប់ពីការស្លាប់ ពេលព្រះអង្គ عز وجل បានឲ្យពួកគេរស់ឡើងវិញ ។" (مختصر بصائر الدرجات: 22) 7:155-156

وَظَلَّلْنَا عَلَيْكُمُ ٱلْغَمَامَ وَأَنزَلْنَا عَلَيْكُمُ ٱلْمَنَّ وَٱلسَّلْوَىٰ ۖ كُلُوا۟ مِن طَيِّبَٰتِ مَا رَزَقْنَٰكُمْ ۚ وَمَا ظَلَمُونَا وَلَٰكِن كَانُوٓا۟ أَنفُسَهُمْ يَظْلِمُونَ ﴿٥٧﴾

៥៧. ហើយយើងបានឲ្យពពកផ្តល់ម្លប់លើពួកអ្នក យើងបានចាត់បញ្ជូនអាល់-ម៉াননិងក្រូចមកឲ្យពួកអ្នក ។ [យើងបានប្រាប់ពួកអ្នកថា៖] "ពួកអ្នកចូរបរិភោគរបស់ល្អដែលយើងបានផ្តល់ឲ្យពួកអ្នក ។" ពួកគេមិនបានប្រព្រឹត្តទុច្ចរិតលើយើងទេ តែពួកគេបានប្រព្រឹត្តទុច្ចរិតលើខ្លួនឯង ។

អធិប្បាយអាយ៉ាស់ ៥៧

1/57. قَالَ اَلْإِمَامُ عَلَيْهِ اَلسَّلاَمُ: قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿وَ﴾ اُذْكُرُوا يَا بَنِي إِسْرَائِيلَ إِذْ ﴿ظَلَّلْنَا عَلَيْكُمُ اَلْغَمَامَ﴾ لَمَّا كُنْتُمْ فِي التيه [اَلتِّيهِ] يَقِيكُمْ حَرَّ اَلشَّمْسِ وَ بَرْدَ اَلْقَمَرِ.

៥៧/១. អ៊ីមុាំ صلوات الله عليه والسلام [អាល់-ហ្ជាសាន់ អាល់-អ្ហាស់ការី صلوات الله عليه والسلام] មានវចនៈថា៖ "អល់ឡោះហ្ស៊ូ عز وجل មានព្រះរាជបន្ទូលថា *[២:៥៧] ហើយ* កូនចៅអ៊ីសរ៉ែ្អលអ៊ីយ ! ចូរនឹកឃើញកាល *យើងបានឲ្យពពកផ្តល់ម្លប់លើពួកអ្នក* ព្រោះតែពួកអ្នកនៅក្នុងរហោឋាន (កណ្តាលវាលគ្មានជម្រក) ការពារពួកអ្នកពីកម្តៅថ្ងៃនិងពីអាកាសត្រជាក់របស់ខែ ។

﴿وَ أَنْزَلْنَا عَلَيْكُمُ اَلْمَنَّ وَ اَلسَّلْوىٰ﴾ اَلْمَنُّ: اَلتَّرَنْجَبِينُ[1] كَانَ يَسْقُطُ عَلَى شَجَرِهِمْ فَيَتَنَاوَلُونَهُ وَ اَلسَّلْوَى[2]: اَلسُّمَانَى طَيْرٌ، أَطْيَبُ طَيْرٍ لَحْماً، يَسْتَرْسِلُ لَهُمْ فَيَصْطَادُونَهُ.

---

1. الترنجبين: معرّب الترانگبين، و هو كلّ طلّ ينزل من السّماء على شجر أو حجر، و يحلو و ينعقد عسلا، و يجفّ جفاف الصمغ. «تاج العروس- منن- ٩:٣٥٠».

2. السّماني: و هو طائر صغير من رتبة الدجاجيات، جسمه منضغط ممتلئ، و هو من القواطع التي تهاجر شتاء إلى الحبشة و السّودان، - - و يستوطن أوربة و حوض البحر المتوسط. «المعجم الوسيط -سلا-١:٤٤٦».

យើងបានចាត់បញ្ជូនអាល់-ម៉াননិងក្រូចមកឲ្យពួកអ្នក អាល់-ម៉ាន គឺលម្អងម្យ៉ាងដែលធ្លាក់មកនៅលើដើមឈើពួកគេ ដូច្នេះពួកគេបរិភោគវា ។ ក្រូច (អាស់-សាល់វ៉ា) គឺបក្សីមួយប្រភេទ (មាន់ព្រៃ) មានសាច់ឆ្ងាញ់ ត្រូវដាក់មកឲ្យពួកគេ ។ ពួកគេចាប់វា ។

قَالَ اَللَّهُ عَزَّ وَ جَلَّ [لَهُمْ]: ﴿كُلُوا مِنْ طَيِّبَاتِ مَا رَزَقْنَاكُمْ﴾ وَ اُشْكُرُوا نِعْمَتِي وَ عَظِّمُوا مَنْ عَظَّمْتُهُ، وَ وَقِّرُوا مَنْ وَقَّرْتُهُ مِمَّنْ أَخَذْتُ عَلَيْكُمُ اَلْعُهُودَ وَ اَلْمَوَاثِيقَ [لَهُمْ] مُحَمَّدٍ وَ آلِهِ اَلطَّيِّبِينَ.

អល់ឡោះហ្ស៊ូ عز وجل មានព្រះរាជបន្ទូលនឹងពួកគេថា *ពួកអ្នកចូរបរិភោគរបស់ល្អដែលយើងបានផ្តល់ឲ្យពួក*

អ្នក ហើយពួកអ្នកចូរអរព្រះគុណចំពោះព្រះសប្បុរសធម៌អញ្ជ ﷻ ពួកអ្នកចូរទុកជាធំអ្នកដែលអញ្ជ ﷻ បានតែងតាំងជាធំ ពួកអ្នកចូរគោរពអស់បុគ្គលទាំងនោះដែលអញ្ជ ﷻ លើកតម្កើង គឺបណ្ដាអ្នក عليهم السلام ទាំងនោះ ឯងដែលពួកអ្នកបានសន្យានឹងអញ្ជ ﷻ ថាពួកអ្នកព្រមទទួលយកវីឡាយ៉ាសុ៌ គឺមូហ្ចាំម៉ាដ្ដ ﷺ និងកូនចៅ បរិសុទ្ធ عليهم السلام របស់គេ ﷺ ។

قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿وَ مٰا ظَلَمُونٰا﴾ لَمَّا بَدَّلُوا، وَ قَالُوا غَيْرَ مَا أُمِرُوا [بِهِ] وَ لَمْ يَفُوا بِمَا عَلَيْهِ عُوهِدُوا، لِأَنَّ كُفْرَ اَلْكَافِرِ لاَ يَقْدَحُ فِي سُلْطَانِنَا وَ مَمَالِكِنَا، كَمَا أَنَّ إِيمَانَ اَلْمُؤْمِنِ لاَ يَزِيدُ فِي سُلْطَانِنَا ﴿وَ لٰكِنْ كٰانُوا أَنْفُسَهُمْ يَظْلِمُونَ﴾ يَضُرُّونَ بِهَا بِكُفْرِهِمْ وَ تَبْدِيلِهِمْ.

អល់ឡោះហ្ចាំ ﷻ មានព្រះរាជបន្ទូលថា *ពួកគេមិនបានប្រព្រឹត្ដទុច្ចរិតលើយើងទេ* (ពួកគេមិនបានធ្វើឲ្យអញ្ជ ﷻ ខូចខាតទេ) កាលពួកគេបានផ្លាស់ប្ដូរសម្ដីអញ្ជ ﷻ បានថាផ្សេងពីអ្វីដែលគេបានបញ្ជាឲ្យពួកគេថា ហើយមិនបានប្រព្រឹត្ដទៅតាមកតិកាសញ្ញាពួកគេទេនោះ (តែពួកគេបានធ្វើឲ្យខ្លួនឯងខូចខាត) ។ ការក្បត់ជំនឿរបស់ពួកអសទ្ធាដែលក្បត់ពាក្យស្ម័គ្រនោះមិនធ្វើឲ្យព្រះអាជ្ញាធរយើង ﷻ និងព្រះរាជាណាចក្រយើង ﷻ អន់ថយទេ ដូចការជឿរបស់អ្នកមានសទ្ធាមិនធ្វើឲ្យអ្វីកើនឡើងក្នុងព្រះអាជ្ញាធរយើង ﷻ នោះដែរ *តែពួកគេបានប្រព្រឹត្ដទុច្ចរិតលើខ្លួនឯង* ពួកគេធ្វើអាក្រក់មកលើខ្លួនឯងដោយសារពួកគេមិនជឿ និងដោយសារពួកគេប្ដូរផ្លាស់ ។"

ثُمَّ [قَالَ عَلَيْهِ السَّلاَمُ:] قَالَ رَسُولُ اَللَّهِ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ: عِبَادَ اَللَّهِ عَلَيْكُمْ بِاعْتِقَادِ وَلاَيَتِنَا أَهْلَ اَلْبَيْتِ وَ [أَنْ] لاَ تُفَرِّقُوا بَيْنَنَا، وَ أُنْظُرُوا كَيْفَ وَسَّعَ اَللَّهُ عَلَيْكُمْ حَيْثُ أَوْضَحَ لَكُمُ اَلْحُجَّةَ لِيُسَهِّلَ عَلَيْكُمْ مَعْرِفَةَ اَلْحَقِّ، ثُمَّ وَسَّعَ لَكُمْ فِي اَلتَّقِيَّةِ لِتَسْلَمُوا مِنْ شُرُورِ اَلْخَلْقِ، ثُمَّ إِنْ بَدَّلْتُمْ وَ غَيَّرْتُمْ عَرَضَ عَلَيْكُمُ اَلتَّوْبَةَ وَ قَبِلَهَا مِنْكُمْ، فَكُونُوا لِنَعْمَاءِ اَللَّهِ شَاكِرِينَ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 257)

បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام មានវចនៈថាវ៉ៃស៊ូលុលឡោះហ្ចាំ ﷺ មានព្រះវចនៈថា៖ "បាវអល់ឡោះហ្ចាំ ﷻ អើយ ! កាតព្វកិច្ចរបស់អស់លោកគឺជឿវីឡាយ៉ាសុ៌យើង عليهم السلام ព្រះរាជកុលដ្ឋាន عليهم السلام (អាស្ងុលុល-បៃត៌ عليهم السلام) ។ អស់លោកមិនមានសិទ្ធិរើសអើងយើង عليهم السلام ទេ ។ ចូរអស់លោកពិនិត្យមើលចុះថាអល់ឡោះហ្ចាំ ﷻ បានអធិប្បាយសព្វគ្រប់យ៉ាងល្អិតល្អន់ដូចម្ដេចខ្លះសម្រាប់អស់លោក ហើយបានបង្ហាញភ័ស្ដុតាងច្បាស់លាស់ដល់អស់លោកដើម្បីធ្វើឲ្យអស់លោកងាយយល់ការពិត ។ បន្ទាប់មកព្រះអង្គ ﷻ បានទុកសេរីភាពឲ្យអស់លោកទាក់ទងនឹងការលាក់ចាំងជំនឿរបស់ខ្លួន (តាគ្ងីយ៉ាសុ) ដើម្បីនឹងឲ្យអស់លោកចាកផុតពីអំពើអាក្រក់របស់មនុស្ស ។ បន្ទាប់ពីនោះ បើអស់លោកប្ដូរផ្លាស់វា (កតិកាសញ្ញា) ព្រះអង្គ ﷻ ចាំទទួលការស្នារលាទោសពីអស់លោក ។ ដូច្នេះចូរអស់លោកអរព្រះគុណអល់ឡោះហ្ចាំ ﷻ ដែលប្រកបដោយព្រះហឫទ័យទូលំទូលាយ ។"" (التفسير المنسوب إلى الإمام العسكري عليه السلام 1: 257)7:160-162

***

2/57. ابْنُ بَابَوَيْهِ: عَنْ مُحَمَّدِ بْنِ أَحْمَدَ بْنِ الْحُسَيْنِ بْنِ يُوسُفَ الْبَغْدَادِيِّ، قَالَ: حَدَّثَنَا عَلِيُّ بْنُ مُحَمَّدِ بْنِ عَنْبَسَةَ، قَالَ: حَدَّثَنَا دَارِمُ بْنُ قَبِيصَةَ، قَالَ: حَدَّثَنَا عَلِيُّ بْنُ مُوسَى الرِّضَا، عَنْ أَبِيهِ، عَنْ آبَائِهِ، عَنْ عَلِيِّ بْنِ أَبِي طَالِبٍ (عَلَيْهِمُ السَّلاَمُ)، قَالَ: «قَالَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ): الْكَمْأَةُ[1] مِنَ الْمَنِّ الَّذِي نَزَلَ عَلَى بَنِي إِسْرَائِيلَ، وَ هِيَ شِفَاءٌ لِلْعَيْنِ وَ الْعَجْوَةُ الَّتِي مِنَ الْبَرْنِيِّ مِنَ الْجَنَّةِ، وَ هِيَ شِفَاءٌ مِنَ السَّمِّ». (عيون أخبار الرّضا (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢٢٣ الحديث: ٩٩/ ٤٨١، عيون أخبار الرّضا (عليه السّلام) – الجزء: ١ الصفحة: ٧٥ الحديث : ٣٤٩)**

---

[1] الكماة: فطر من الفصيلة الكمئية، و هي أرضية تنتفخ حاملات أبواغها، فتجنى و تؤكل مطبوخة. «المعجم الوسيط–كمأ–٢:٧٩٧».

៥៧/២. អ៊ីបនូ បាប៊ូវៃហ៍ បានរាយការណ៍តមកពី មូហ៊ាំម៉ាដ់ ប៊ិន អាស្ម៉ាដ់ ប៊ិន អាល់-ហ៊ូសៃន៍ ប៊ិន យូនុស អាល់-បាក់ដាឌី តមកពី អាលី ប៊ិន មូហ៊ាំម៉ាដ់ ប៊ិន អាន់បាសាស់ តមកពី ដាវ៉ូម ប៊ិន ក៏ប៊ីស្សោះតុ៍ តមកពី អាលី ប៊ិន មូសា អាល់-រីដ៉្លស صلوات الله عليه والسلام តមកពីព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام តមកពីព្រះអយ្យកោ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام តមកពី អាលី صلوات الله عليه والسلام ប៊ិន អាប៊ូ តលិប ﷺ ដែលមានវចនៈថា រ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ផ្សិតម្យ៉ាងមកពី អាល់-ម៉ាន ដែលត្រូវប្រទានចុះមកឲ្យពួកកូនចៅអ៊ីសរ៉អ៊ីល ហើយវាជាថ្នាំព្យាបាលភ្នែក ។ រីឯ អាល់-អាជ្វ៉ាស់ ជាផ្លែលម៉ើប្រភេទល្អដែលមកពីឋានសួគ៌ ហើយវាជាថ្នាំបន្សាបថ្នាំបំពុល ។" (عيون أخبار الرّضا (عليه السلام) 1: 75/ 349)

***

3/57. أَحْمَدُ بْنُ مُحَمَّدِ بْنِ خَالِدٍ الْبَرْقِيُّ: عَنْ مُحَمَّدِ بْنِ عَلِيٍّ، عَنْ مُحَمَّدِ بْنِ الْفُضَيْلِ، عَنْ عَبْدِ الرَّحْمَنِ بْنِ زَيْدِ بْنِ أَسْلَمَ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ) أَنَّهُ قَالَ: «قَالَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ): الْكَمْأَةُ مِنَ الْمَنِّ، وَ الْمَنُّ مِنَ الْجَنَّةِ، وَ مَاؤُهَا شِفَاءُ الْعَيْنِ». (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢٢٣ الحديث: ٩٩/ ٣٨٢، المحاسن – الجزء: ١ الصفحة: ٥٢٧ الحديث : ٧٦١)**

៥៧/៣. អាស្ម៉ាដ់ ប៊ិន មូហ៊ាំម៉ាដ់ ប៊ិន ខ៏លិដ អាល់-បារគ៏ី បានរាយការណ៍តមកពី មូហ៊ាំម៉ាដ់ ប៊ិន អាលី តមកពី មូហ៊ាំម៉ាដ់ ប៊ិន អាល់-ហ្វាដ្ហៃល៍ តមកពី អាប់ឌុល-រ៉ោះហ៊្ម៉ាន ប៊ិន ស្សៃដ៍ ប៊ិន អាស់ឡាំ តមកពី អាប៊ូ អាប់ឌុលឡោះហ៍ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام មានវចនៈថារ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ផ្សិតម្យ៉ាង (truffle) មកពី អាល់-ម៉ាន អាល់-ម៉ានមកពីឋានសួគ៌ ទឹកវាជាថ្នាំសម្រាប់ព្យាបាលភ្នែក ។" (المحاسن: 527/ 761)

***

4/57. مُحَمَّدُ بْنُ يَعْقُوبَ: عَنْ عِدَّةٍ مِنْ أَصْحَابِنَا، عَنْ مُحَمَّدِ بْنِ عَبْدِ اللَّهِ، عَنْ عَبْدِ الْوَهَّابِ بْنِ بِشْرٍ، عَنْ مُوسَى بْنِ قَادِمٍ، عَنْ سُلَيْمَانَ، عَنْ زُرَارَةَ، عَنْ أَبِي جَعْفَرٍ (عَلَيْهِمُ السَّلاَمُ)، قَالَ: سَأَلْتُهُ عَنْ قَوْلِ اللَّهِ عَزَّ وَ جَلَّ: وَ ما ظَلَمُونا وَ لكِنْ كانُوا أَنْفُسَهُمْ يَظْلِمُونَ. قَالَ: «إِنَّ اللَّهَ أَعْظَمُ وَ أَعَزُّ وَ أَجَلُّ وَ أَمْنَعُ مِنْ أَنْ يُظْلَمَ، وَ لَكِنَّهُ خَلَطَنَا بِنَفْسِهِ، فَجَعَلَ ظُلْمَنَا ظُلْمَهُ، وَ وَلَايَتَنَا وَلَايَتَهُ، حَيْثُ يَقُولُ: ﴿إِنَّمَا وَلِيُّكُمُ اللَّهُ وَ رَسُولُهُ وَ الَّذِينَ آمَنُوا﴾ يَعْنِي الْأَئِمَّةَ مِنَّا». (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢٢٤ الحديث: ٩٩/ ٤٨٤، الكافي – الجزء: ١ الصفحة: ١١٣ الحديث : ١١)**

៥៧/៤. រាយការណ៍ដោយ មូហ៊ាំម៉ាដ់ ប៊ិន យ៉ាក់គូប តមកពីមិត្តយើងច្រើននាក់ តមកពី មូហ៊ាំម៉ាដ់ ប៊ិន អាប់ឌុលឡោះហ៍ តមកពី អាប់ឌុល វ៉ាហ្ហាប់ ប៊ិន ប៊ីស្សរ៍ តមកពី មូសា ប៊ិន ក៏ឌីម តមកពី ស៊ូឡៃម៉ាន តមកពី ស៊ូរ៉ោះតុ៍ តមកពី អាប៊ូ យ៉ាក់ហ្វារ صلوات الله عليه والسلام ថាខ្ញុំបានសួរព្រះអង្គ صلوات الله عليه والسلام អំពីព្រះបន្ទូលអល់ឡោះហ៍ عزّ وجلّ *[២:៥៧] ពួកគេមិនបានប្រព្រឹត្តទុច្ចរិតលើយើងទេ តែពួកគេបានប្រព្រឹត្តទុច្ចរិតលើខ្លួនឯង ។* ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "ពិតណាស់ អល់ឡោះហ៍ عزّ وجلّ មហាធំធ្ងើងបំផុត ព្រះអង្គ عزّ وجلّ មានមហិទ្ធិឫទ្ធិ មហារុងរឿងបំផុត ព្រះអង្គ عزّ وجلّ ខ្លាំងពូកែពេកក្រៃមិនអាចសង្កត់សង្កិនបានឡើយ តែព្រះអង្គ عزّ وجلّ បានលាយផ្សំយើង عليهم السلام ជាមួយព្រះអង្គ عزّ وجلّ ។ ដូច្នេះព្រះអង្គ عزّ وجلّ បានធ្វើឲ្យការសង្កត់សង្កិនមកលើយើង عليهم السلام នោះដូចជាការសង្កត់សង្កិនទៅលើព្រះអង្គ عزّ وجلّ ដែរ វិឡាយ៉ាស់យើង عليهم السلام ដូចជាវិឡាយ៉ាស់ព្រះអង្គ عزّ وجلّ ដែរ ព្រះអង្គ عزّ وجلّ មានព្រះរាជបន្ទូលត្រង់នេះថា *[៥:៥៥] អភិបាល (អ្នកទំនុកបម្រុង អ្នកគាំទ្រ...) របស់ពួកអ្នកគឺមានតែអល់ឡោះហ៍ ព្រះសាសនៈទូតរបស់ព្រះអង្គនិងបណ្ដាអ្នកមានសទ្ធាជ្រះថ្លា* មានន័យថាអស់អ៊ីម៉ាំ عليهم السلام ដែលមកពីយើង عليهم السلام ។" (الكافي 1: 113/ 11)

***

*5/57. الشَّيْخُ: مُرْسَلاً عَنِ الصَّادِقِ (عَلَيْهِ السَّلاَمُ)، قَالَ: «نَوْمَةُ الْغَدَاةِ مَشْئُومَةٌ تَطْرُدُ الرِّزْقَ، وَ تُصَفِّرُ اللَّوْنَ، وَ تُقَبِّحُهُ وَ تُغَيِّرُهُ، وَ هُوَ نَوْمُ كُلِّ مَشْئُومٍ، إِنَّ اللهَ تَعَالَى قَسَمَ الْأَرْزَاقَ مَا بَيْنَ طُلُوعِ الْفَجْرِ إِلَى طُلُوعِ الشَّمْسِ،

*៥៧/៥. អាល់-ស្ហ៊ីខ្ខ៊ុ (អាល់-ទ្ធ៊ូសុ៊ី) បានរាយការណ៍តាមបណ្តាញព័ត៌មានមិនដាច់តមកពី អាល់-ស្ហ៊ីឌ្ឌ៊ីក្ខ صلوات الله عليه والسلام ដែលមានវចន:ថា៖ "ការដេកពេលព្រឹកមិនសូវល្អទេព្រោះវាវាយច្រានលាភ[រ៉ីសុ៊ីក្ហ] ធ្វើឲ្យសម្បុរស្លាំង ធ្វើឲ្យវាអាក្រក់ ធ្វើឲ្យវាប្រែប្រួល ។ វាជាការដេករបស់ពួកខាតបង់ ។ អល់ឡោះហ្ស៊ីវ៉ាជ្ជ ចែកលាភ[រ៉ីសុ៊ីក្ហ]នៅចន្លោះពេល អាល់-ហ្ហាច្ចុ៌រ (ពេលស្ហ៊ីឡាតុ៌មុនថ្ងៃរះ) និងពេលថ្ងៃចាប់ផ្តើមរះ ។

وَ إِيَّاكُمْ وَ تِلْكَ النَّوْمَةَ، وَ كَانَ الْمَنُّ وَ السَّلْوَى يَنْزِلُ عَلَى بَنِي إِسْرَائِيلَ مَا بَيْنَ طُلُوعِ الْفَجْرِ إِلَى طُلُوعِ الشَّمْسِ، فَمَنْ نَامَ تِلْكَ السَّاعَةَ لَمْ يَنْزِلْ نَصِيبُهُ، وَ كَانَ إِذَا انْتَبَهَ فَلاَ يَرَى نَصِيبَهُ احْتَاجَ إِلَى السُّؤَالِ وَ الطَّلَبِ». (البرهان في تفسير القرآن - الجزء: ١ الصفحة: ٢٢٤ الحديث: ٩٩/ ٤٨٣، التّهذيب - الجزء: ٢ الصفحة: ١٣٩ الحديث : ٥٤٠)**

ចូរប្រយ័ត្នការដេកនេះ ។ អាល់-ម៉ាន និង អាល់-សាល់វ៉ា ដែលគេបានដាក់ចុះមកឲ្យបណ្តាកូនចៅអ៊ីសរ៉ាអ៊ីលនោះ ត្រូវដាក់ចុះមកនៅពេលចន្លោះអាល់-ហ្ហាច្ចុ៌រ (ពេលស្ហ៊ីឡាតុ៌មុនថ្ងៃរះ) ដល់ទៅពេលថ្ងៃចាប់ផ្តើមរះ ។ ដូច្នេះអ្នកណាដេកពេលនោះ ចំណែករបស់អ្នកនោះនឹងមិនចុះមកទេ ។ ពេលអ្នកនោះភ្ញាក់ឡើងនឹងមិនឃើញមានចំណែករបស់ខ្លួនទេ ។ អ្នកនោះនឹងត្រូវតែសូម នឹងត្រូវតែស្វែងរក ។" (التّهذيب 2: 139/ 540)

وَإِذْ قُلْنَا ٱدْخُلُواْ هَٰذِهِ ٱلْقَرْيَةَ فَكُلُواْ مِنْهَا حَيْثُ شِئْتُمْ رَغَدًا وَٱدْخُلُواْ ٱلْبَابَ سُجَّدًا وَقُولُواْ حِطَّةٌ نَّغْفِرْ لَكُمْ خَطَٰيَٰكُمْ ۚ وَسَنَزِيدُ ٱلْمُحْسِنِينَ ﴿٥٨﴾

៥៨. ហើយ[ចូរនឹកឃើញ]កាលយើងមានព្រះតម្រាស់ថា៖ "ចូរពួកអ្នកចូលទៅក្នុងបុរីនេះទៅ ។ ពួកអ្នកចូរបរិភោគ[នូវចំណី]បរិបូរពីនោះ គ្រប់ទីកន្លែងស្រេចតែចិត្តពួកអ្នកចុះ ។ ពួកអ្នកចូរចូលតាមទ្វារដោយក្រាបប្រណិប័តន៍ ។ ចូរពួកអ្នកថា៖ "សូមខមាទោស ។" យើងនឹងអត់ឱនឲ្យពួកអ្នកដែលបានធ្វើខុស ។ យើងនឹងបន្ថែមឲ្យបណ្តាអ្នកប្រព្រឹត្តល្អ ។"

អធិប្បាយអាយ៉ាស់ ៥៨

1/58. قَالَ اَلْإِمَامُ عَلَيْهِ اَلسَّلاَمُ: قَالَ اَللَّهُ تَعَالَى: ﴿وَ﴾ اُذْكُرُوا يَا بَنِي إِسْرَائِيلَ ﴿إِذْ قُلْنَا﴾ لِأَسْلاَفِكُمْ: ﴿اُدْخُلُوا هٰذِهِ اَلْقَرْيَةَ﴾ وَ هِيَ ''أَرِيحَا'' مِنْ بِلاَدِ اَلشَّامِ، وَ ذَلِكَ حِينَ خَرَجُوا مِنَ اَلتِّيهِ ﴿فَكُلُوا مِنْهَا﴾ مِنَ اَلْقَرْيَةِ ﴿حَيْثُ شِئْتُمْ رَغَداً﴾ وَاسِعاً، بِلاَ تَعَبٍ [وَ لاَ نَصَبٍ] ﴿وَ اُدْخُلُوا اَلْبَابَ﴾ بَابَ اَلْقَرْيَةِ ﴿سُجَّداً﴾.

៥៨/១. អ៊ីមុ៉ាំ صلوات الله عليه والسلام [អាល់-ហ្ហាសាន់ អាល់-អ្ហ្ស៊ីការី صلوات الله عليه والسلام] មានវចន:ថាអល់ឡោះហ្ស៊ីវ៉ាជ្ជ មានព្រះរាជបន្ទូលថា៖ *"[២:៥៨] ហើយ* កូនចៅអ៊ីសរ៉ាអ៊ីលអើយ ! ចូរនឹកឃើញ *កាលយើងមានព្រះតម្រាស់* នឹងដូនតាពួកអ្នក *ថា៖ "ចូរពួកអ្នកចូលទៅក្នុងបុរីនេះទៅ* បុរីនេះគឺបុរី "អារ្ហា" ជាបុរីនៃប្រទេសស៊ីរី កាលពួកគេចេញមកពីរហោឋាន (វាល) *ពួកអ្នកចូរបរិភោគបរិបូរពីនោះ* ពីបុរីនេះ *គ្រប់ទីកន្លែងស្រេចតែចិត្តពួកអ្នកចុះ* ការសម្បូរបែបរបស់ស្រុកនេះ ដោយមិនធុញទ្រាន់ មិនមានអ្នកណាប្រឆាំង ។ *ពួកអ្នកចូលតាមទ្វារ* ទ្វាររបស់បុរីនេះ *ដោយក្រាបប្រណិប័តន៍ ។*

مَثَّلَ اَللَّهُ تَعَالَى عَلَى اَلْبَابِ مِثَالَ مُحَمَّدٍ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ وَ عَلِيٍّ عَلَيْهِ السَّلاَمُ وَ أَمَرَهُمْ أَنْ يَسْجُدُوا تَعْظِيماً لِذَلِكَ اَلْمِثَالِ، وَ يُجَدِّدُوا عَلَى أَنْفُسِهِمْ بَيْعَتَهُمَا وَ ذِكْرَ مُوَالاَتِهِمَا، وَ لِيَذْكُرُوا اَلْعَهْدَ وَ اَلْمِيثَاقَ اَلْمَأْخُوذَيْنِ عَلَيْهِمْ لَهُمَا.

អល់ឡោះហ្ស៊ីតាអាឡាបានដាក់គំរូមូហ្ហាំម៉ាដ្ធ៉ូ ﷺ និងអ្ហាលីនៅខាងលើទ្វារស្រុក បានបញ្ជាឲ្យពួកគេក្រាបសំពះដោយសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ចំពោះគំរូទាំងពីរនោះ ឲ្យពួកគេសច្ចាស្មោះស្ម័គ្រសាច្ចីចំពោះព្រះអង្គទាំងពីរ ﷺ ឪពួកគេនឹករលឹកដល់អស់ព្រះអង្គ ﷺ ជាព្រះបរមគ្រូ និងឲ្យពួកគេនឹកឃើញពាក្យសម្បថនិងពាក្យសន្យាដែលគេបានទទួលយកពីពួកគេថាពួកគេព្រមគោរពព្រះអង្គទាំងពីរ ﷺ ។

﴿وَ قُولُوا حِطَّةٌ﴾ أَيْ قُولُوا: إِنَّ سُجُودَنَا لِلَّهِ تَعَالَى تَعْظِيماً لِمِثَالِ مُحَمَّدٍ وَ عَلِيٍّ وَ اِعْتِقَادَنَا لِوَلاَيَتِهِمَا حِطَّةٌ لِذُنُوبِنَا وَ مَحْوٌ لِسَيِّئَاتِنَا. قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿نَغْفِرْ لَكُمْ﴾ [أَيْ] هَذَا اَلْفِعْلِ ﴿خَطَايَاكُمْ﴾ اَلسَّالِفَةَ، وَ نُزِيلُ عَنْكُمْ آثَامَكُمُ اَلْمَاضِيَةَ.

ចូរពួកអ្នកថា៖ "សូមខមាទោស" មានន័យថា ចូរថា៖ "អស់ទូលព្រះបង្គំជាខ្ញុំសូមក្រាបប្រណិប័តន៍ចំពោះអល់ឡោះហ្ស៊ីតាអាឡា ដើម្បីសម្ដែងសេចក្ដីគោរពដល់គំរូរបស់មូហ្ហាំម៉ាដ្ធ៉ូ ﷺ និងអ្ហាលី ﷺ ដល់ជំនឿរបស់អស់ទូលព្រះបង្គំជាខ្ញុំចំពោះវីឡាយ៉ាតុ់របស់ព្រះអង្គ ﷺ ទាំងពីរ សូមព្រះអង្គ ﷻ អត់ឱនឲ្យអស់ទូលព្រះបង្គំជាខ្ញុំដែលបានសាងបាប សូមព្រះអង្គ ﷻ លុបលាងកំហុសរបស់អស់ទូលព្រះបង្គំជាខ្ញុំផង ។" អល់ឡោះហ្ស៊ីតាអាឡា ﷻ មានព្រះរាជបន្ទូលថា *យើងនឹងអត់ឱនឲ្យពួកអ្នក* មានន័យថាដោយសារតែបានធ្វើដូច្នោះ (ទង្វើក្រាបប្រណិប័តន៍នេះ) *ដែលបានធ្វើខុស* រួចមកហើយ យើង ﷻ នឹងលុបលាងបាបកាលពីមុនឲ្យពួកអ្នក ។

﴿وَ سَنَزِيدُ اَلْمُحْسِنِينَ﴾ مَنْ كَانَ مِنْكُمْ لَمْ يُقَارِفِ اَلذُّنُوبَ اَلَّتِي قَارَفَهَا مَنْ خَالَفَ اَلْوَلاَيَةَ، [وَ ثَبَتَ عَلَى مَا أَعْطَى اَللَّهُ مِنْ نَفْسِهِ مِنْ عَهْدِ اَلْوَلاَيَةِ] فَإِنَّا نَزِيدُهُمْ بِهَذَا اَلْفِعْلِ زِيَادَةَ دَرَجَاتٍ وَ مَثُوبَاتٍ وَ ذَلِكَ قَوْلُهُ عَزَّ وَ جَلَّ ﴿وَ سَنَزِيدُ اَلْمُحْسِنِينَ﴾. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 259)

យើងនឹងបន្ថែមឲ្យបណ្ដាអ្នកប្រព្រឹត្តល្អ បណ្ដាពួកអ្នកដែលមិនទៅក្បែរបណ្ដាបាបដែមពួកប្រឆាំងវីឡាយ៉ាតុ់ប្រព្រឹត្ត ដែលខ្ជាប់ខ្ជួននឹងអ្វីដែលអល់ឡោះហ្ស៊ីតាអាឡា ﷻ បានឲ្យមកពីព្រះអង្គ ﷻ ផ្ទាល់ គឺវីឡាយ៉ាតុ់ យើង ﷻ នឹងបង្កើនឋានៈនិងរង្វាន់ឲ្យអ្នកនោះដែលបានធ្វើប្រការទាំងនេះ ។ នេះគឺព្រះបន្ទូលអល់ឡោះហ្ស៊ីតាអាឡា ﷻ *យើងនឹងបន្ថែមឲ្យបណ្ដាអ្នកប្រព្រឹត្តល្អ ។* ((التفسير الإمام العسكري (عليه السلام)) វគ្គ ១២៧)

***

2/58. عَنْ سُلَيْمَانَ اَلْجَعْفَرِيِّ قَالَ: سَمِعْتُ أَبَا اَلْحَسَنِ اَلرِّضَا عَلَيْهِ السَّلاَمُ: فِي قَوْلِ اَللَّهِ ﴿وَ قُولُوا حِطَّةٌ نَغْفِرْ لَكُمْ خَطَايَاكُمْ﴾ قَالَ: فَقَالَ أَبُو جَعْفَرٍ عَلَيْهِ السَّلاَمُ نَحْنُ بَابُ حِطَّتُكُمْ. (تفسير العياشى ج١ ص٤٥)

៥៨/២. រាយការណ៍ដោយ ស៊ូឡៃម៉ាន អាល់-យ៉ាកុ៌ហ្ជារី ថាខ្ញុំបានឮ អាប៊ូ អាល់-ហ្ហាសាន់ អាល់-រីដ្ធ៉ា ﷺ មានវចន:អំពីព្រះបន្ទូលអល់ឡោះហ្ស៊ីតាអាឡា ﷻ *[២:៥៨] ចូរពួកអ្នកថា៖ "សូមខមាទោស ។" យើងនឹងអត់ឱនឲ្យពួកអ្នកដែលបានធ្វើខុស ។* ព្រះអង្គ ﷺ មានវចន:ថា៖ "យើង ﷺ គឺទ្វារ ហ្ស៊ីតុ៌ត្ដោ:ត្ដុ៌ (ខមាទោស) សម្រាប់អស់លោក ។" (تفسير العياشى 1: 45)

فَبَدَّلَ ٱلَّذِينَ ظَلَمُواْ قَوۡلًا غَيۡرَ ٱلَّذِى قِيلَ لَهُمۡ فَأَنزَلۡنَا عَلَى ٱلَّذِينَ ظَلَمُواْ رِجۡزًا مِّنَ ٱلسَّمَآءِ بِمَا كَانُواْ يَفۡسُقُونَ ۝٥٩

៥៩. តែបណ្ដាជនទុច្ចរិតបានផ្លាស់សម្ដីខុសពីអ្វីដែលគេបាននិយាយនឹងពួកគេ ។ ដូច្នេះយើងបានចាត់បញ្ជូនទៅលើបណ្ដាជនទុច្ចរិតនូវទារុណកម្មពីលើមេឃ ព្រោះពួកគេបានបំពារបំពាន ។

អធិប្បាយអាយ៉ាស់ ៥៩

1/59. قَوْلُهُ عَزَّ وَ جَلَّ: ﴿فَبَدَّلَ الَّذِينَ ظَلَمُوا قَوْلاً غَيْرَ الَّذِي قِيلَ لَهُمْ﴾ إِنَّهُمْ لَمْ يَسْجُدُوا كَمَا أُمِرُوا، وَ لاَ قَالُوا مَا أُمِرُوا، وَ لَكِنْ دَخَلُوهَا مُسْتَقْبِلِيهَا بِأَسْتَاهِهِمْ وَ قَالُوا: هطا سمقانا أَيْ حِنْطَةٌ حَمْرَاءُ نَتَقَوَّتُهَا أَحَبُّ إِلَيْنَا مِنْ هَذَا الْفِعْلِ وَ هَذَا الْقَوْلِ.

៥៩/១. [អ៊ីម៉ាំហ្ជាសាន់ អាល់-អ្ហ្ការ៉ាមានវចនៈថា៖] ព្រះរាជបន្ទូលអល់ឡោះហ្ជ៉ា ﷻ *[២:៥៩] តែបណ្តាជនទុច្ចរិតបានផ្លាស់សម្តីខុសពីអ្វីដែលគេបាននិយាយនឹងពួកគេ* ពួកគេមិនបានក្រាបប្រណិប័តន៍ដូចដែលគេបានបញ្ជាឲ្យពួកគេធ្វើទេ ពួកគេមិនបាននិយាយដូចដែលគេបានបញ្ជាឲ្យពួកគេនិយាយទេ តែពួកគេបានចូលទៅក្នុងស្រុកដោយបែរខ្នងដាក់ទ្វារ ដោយថា៖ "ហ្ជ៊ីតុ ត្តុ៌ សាំ ក្ខ៉ណា" មានន័យថានេះជាច្រកចូលខ្ពស់មួយ ហេតុអ្វីយើងត្រូវបង្ហោនខ្លួន ពេលដើរចូល ? ទង្វើនេះនិងសម្តីនេះត្រូវចិត្តយើងជាង ។"

قَالَ اللَّهُ تَعَالَى: ﴿فَأَنْزَلْنَا عَلَى الَّذِينَ ظَلَمُوا﴾ غَيَّرُوا وَ بَدَّلُوا مَا قِيلَ لَهُمْ، وَ لَمْ يَنْقَادُوا لِوَلاَيَةِ مُحَمَّدٍ وَ عَلِيٍّ وَ آلِهِمَا الطَّيِّبِينَ الطَّاهِرِينَ. ﴿رِجْزاً مِنَ السَّمَاءِ بِمَا كَانُوا يَفْسُقُونَ﴾ يَخْرُجُونَ عَنْ أَمْرِ اللَّهِ وَ طَاعَتِهِ.

អល់ឡោះហ្ជ៉ាតាអាឡាមានព្រះរាជបន្ទូលថា *យើងបានចាត់បញ្ជូនទៅលើបណ្តាជនទុច្ចរិត* ដែលផ្លាស់ប្តូរអ្វីដែលគេបាននិយាយប្រាប់ពួកគេ (ឲ្យថា) ពួកគេមិនជឿវីឡាយ៉ាស៊ុំរបស់មូហ្ហាំម៉ាដ្ជ៉ូ ﷺ អ្ហ្លីរ៉ា ﷺ និងកូនចៅល្អ បុគ្គលបរិសុទ្ធ ﷺ របស់ពួកគេ ﷺ ទេ *នូវទារុណកម្មពីលើមេឃព្រោះពួកគេបានបំពានបំពាន* ដោយចាកចេញពីព្រះបញ្ជារបស់អល់ឡោះហ្ជ៉ា ﷻ មិនស្តាប់ព្រះឱវាទអង្គ ﷻ ទេ ។

قَالَ: وَ الرِّجْزُ الَّذِي أَصَابَهُمْ أَنَّهُ مَاتَ مِنْهُمْ بِالطَّاعُونِ فِي بَعْضِ يَوْمٍ مِائَةٌ وَ عِشْرُونَ أَلْفاً، وَ هُمْ مَنْ عَلِمَ اللَّهُ تَعَالَى مِنْهُمْ أَنَّهُمْ لاَ يُؤْمِنُونَ وَ لاَ يَتُوبُونَ، وَ لَمْ يَنْزِلْ هَذَا الرِّجْزُ عَلَى مَنْ عَلِمَ أَنَّهُ يَتُوبُ، أَوْ يَخْرُجُ مِنْ صُلْبِهِ ذُرِّيَّةٌ طَيِّبَةٌ تَوَحَّدُ اللَّهَ، وَ تُؤْمِنُ بِمُحَمَّدٍ وَ تَعْرِفُ مُوَالاَةَ عَلِيٍّ وَصِيِّهِ وَ أَخِيهِ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 260)

ព្រះអង្គ ﷺ (អ៊ីម៉ាំហ្ជាសាន់ អាល់-អ្ហ្ការ៉ាមានវចនៈថា៖ ﷺ) "ទារុណកម្មលើពួកគេនោះ គឺពួកគេបានស្លាប់ ១២០០០០ នាក់តែមួយប៉ែកនៃថ្ងៃប៉ុណ្ណោះដោយសារជម្ងឺអាសន្នរោគ ។ អល់ឡោះហ្ជ៉ា ﷻ ទ្រង់ញាណថាអ្នកខ្លះមិនជឿនិងមិនស្តារលាទោសទេ ។ ព្រះអង្គ ﷻ មិនទម្លាក់ជម្ងឺអាសន្នរោគមកលើអ្នកណាដែលព្រះអង្គ ﷻ ទ្រង់ញាណថាអ្នកនោះបានស្តារលាទោសនោះទេ ឬមិនទម្លាក់ជម្ងឺអាសន្នរោគនោះមកលើបណ្តាអ្នកណាដែលកូនចៅរបស់ខ្លួននឹងកើតមកនៅពេលអនាគតទេ ដែលជាមនុស្សល្អដែលនឹងទទួលស្គាល់អល់ឡោះហ្ជ៉ា ﷻ ជាព្រះតែមួយគត់ ដែលនឹងជឿមូហ្ហាំម៉ាដ្ជ៉ូ ﷺ ដែលនឹងទទួលស្គាល់វីឡាយ៉ាស៊ុំរបស់អ្ហ្លីរ៉ា ﷺ ព្រះឧត្តរាធិការ ﷺ របស់ព្រះអង្គ ﷺ និងជាប្អូនប្រុសរបស់ព្រះអង្គ ﷺ នោះ ។" (التفسير المنسوب إلى الإمام العسكري عليه السلام 1: 260) 7:160-162

***

2/59. مُحَمَّدِ بْنِ يَعْقُوبَ: عَنْ أَحْمَدُ بْنُ مِهْرَانَ، عَنْ عَبْدِ الْعَظِيمِ بْنِ عَبْدِ اللَّهِ، عَنْ مُحَمَّدِ بْنِ الْفُضَيْلِ، عَنْ أَبِي حَمْزَةَ، عَنْ أَبِي جَعْفَرٍ (عليه السلام)، قَالَ: «نَزَلَ جَبْرَئِيلُ (عليه السلام) بِهَذِهِ الْآيَةِ عَلَى مُحَمَّدٍ (صلى الله عليه وآله) هَكَذَا: فَبَدَّلَ الَّذِينَ ظَلَمُوا آلَ مُحَمَّدٍ حَقَّهُمْ قَوْلًا غَيْرَ الَّذِي قِيلَ لَهُمْ، فَأَنْزَلْنَا عَلَى الَّذِينَ ظَلَمُوا آلَ مُحَمَّدٍ حَقَّهُمْ رِجْزاً مِنَ السَّماءِ بِما كانُوا يَفْسُقُونَ». (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢٢٩ الحديث: ٩٩/ ٤٨٨، الكافي – الجزء: ١ الصفحة: ٣٥٠ الحديث : ٥٨)**

⊛وَإِذِ ٱسۡتَسۡقَىٰ مُوسَىٰ لِقَوۡمِهِۦ فَقُلۡنَا ٱضۡرِب بِّعَصَاكَ ٱلۡحَجَرَۖ فَٱنفَجَرَتۡ مِنۡهُ ٱثۡنَتَا عَشۡرَةَ عَيۡنٗاۖ قَدۡ عَلِمَ كُلُّ أُنَاسٖ مَّشۡرَبَهُمۡۖ كُلُواْ وَٱشۡرَبُواْ مِن رِّزۡقِ ٱللَّهِ وَلَا تَعۡثَوۡاْ فِي ٱلۡأَرۡضِ مُفۡسِدِينَ ٦٠

៦០. ហើយ[ចូរនឹកឃើញ]កាលមូសាបានបួងសួងសូមទឹកឲ្យប្រជាជាតិគេ យើងមានព្រះតម្រាស់ថា៖ "អ្នកចូរវាយផ្ទាំងសិលាដោយដំបងអ្នកទៅ ។" ដប់ពីរប្រភពទឹកបាញ់ចេញមកពីផ្ទាំងសិលានោះ ។ ប្រជាជាតិ[នៃកុលសម្ព័ន្ធ]នីមួយៗដឹងទីកន្លែងផឹករបស់ខ្លួន ។ [យើងមានព្រះតម្រាស់នឹងពួកគេថា៖] "ពួកអ្នកចូរបរិភោគនិងផឹកនូវគ្រឿងទ្រទ្រង់ជីវិតរបស់អល់ឡោះហ្ន៑ចុះ ។ ពួកអ្នកចូរកុំបង្ករិនាសនៅលើផែនដី ដោយបង្ករអន្តរាយ ។"

អធិប្បាយអាយ៉ាស់ ៦០

1/60. ثُمَّ قَالَ اللَّهُ عَزَّ وَ جَلَّ: ﴿وَ إِذِ اسْتَسْقىٰ مُوسىٰ لِقَوْمِهِ﴾ قَالَ: وَ اُذْكُرُوا يَا بَنِي إِسْرَائِيلَ إِذِ اسْتَسْقَى مُوسَى لِقَوْمِهِ، طَلَبَ لَهُمُ السُّقْيَا، لَمَّا لَحِقَهُمُ الْعَطَشُ فِي التِّيهِ، وَ ضَجُّوا بِالْبُكَاءِ إِلَى مُوسَى، وَ قَالُوا: أَهْلَكَنَا الْعَطَشُ. فَقَالَ مُوسَى: اَللَّهُمَّ بِحَقِّ مُحَمَّدٍ سَيِّدِ الْأَنْبِيَاءِ، وَ بِحَقِّ عَلِيٍّ سَيِّدِ الْأَوْصِيَاءِ وَ بِحَقِّ فَاطِمَةَ سَيِّدَةِ النِّسَاءِ، وَ بِحَقِّ الْحَسَنِ سَيِّدِ الْأَوْلِيَاءِ، وَ بِحَقِّ الْحُسَيْنِ سَيِّدِ الشُّهَدَاءِ وَ بِحَقِّ عِتْرَتِهِمْ وَ خُلَفَائِهِمْ سَادَةِ الْأَزْكِيَاءِ لَمَّا سَقَيْتَ عِبَادَكَ هَؤُلَاءِ.

៦០/១. បន្ទាប់មកអល់ឡោះហ្ន៑ﷻមានព្រះរាជបន្ទូលថា៖ *[២:៦០] ហើយកាលមូសាបានបួងសួងសូមទឹកឲ្យប្រជាជាតិគេ* ព្រះអង្គﷻមានព្រះរាជបន្ទូលថា៖ "កូនចៅអ៊ីសរ៉ាអ៊ីលអើយ! ចូរនឹកឃើញកាលមូសាបានបួងសួងសូមឲ្យមានទឹកសម្រាប់ប្រជាជាតិគេ ដោយស្វែងរកទឹកផឹកឲ្យពួកគេ ដោយសារតែពួកគេស្រេកទឹកនៅក្នុងរហោឋាន ។ ពួកគេបានតួ្ពញប្រាប់មូសាថា៖ "យើងកំពុងតែស្លាប់ដោយសារស្រេកទឹក ។" មូសាបានទូលថា៖ "ម្ចាស់ﷻអើយ! ដោយនូវសិទ្ធិមូហ្ន៑ាម៉ាដ្ធ ﷺ ព្រះអគ្គមហាប្រមុខរបស់អស់ព្រះសាស្ត្រា ដោយនូវសិទ្ធិអ្ហាលី ﷺ ព្រះអគ្គមហាប្រមុខរបស់អស់ព្រះឧបរាជ ដោយនូវសិទ្ធិហ្ជាទ្ធីម៉ាស៊ុ ﷺ ព្រះអគ្គមហាប្រមុខរបស់អស់នារីថ្លៃថ្នូ ដោយនូវសិទ្ធិអាល់-ហ្ជាសាន់ ﷺ ព្រះអគ្គមហាប្រមុខរបស់អស់អភិបាល ដោយនូវសិទ្ធិអាល់-ហ្ជ៊ូសៃន៑ ﷺ ព្រះអគ្គមហាប្រមុខរបស់អស់ទុក្ករ:បុគ្គល និងដោយនូវសិទ្ធិព្រះរាជបុត្ររាជនត្តា ﷺ របស់អស់ព្រះអង្គ ﷺ បណ្ដាខ្ជ៑លិហ្ជ ﷺ របស់អស់ព្រះអង្គ ﷺ និងព្រះអគ្គប្រមុខរបស់បុគ្គលបរិសុទ្ធទាំងឡាយ ﷺ សូមព្រះអង្គﷻប្រទានទឹកផឹងឲ្យពួកគេ បាវបម្រើរបស់ព្រះអង្គﷻ ។"

فَأَوْحَى اَللَّهُ تَعَالَى إِلَيْهِ: يَا مُوسَى ﴿اِضْرِبْ بِعَصَاكَ اَلْحَجَرَ﴾ . فَضَرَبَهُ بِهَا ﴿فَانْفَجَرَتْ مِنْهُ اِثْنَتَا عَشْرَةَ عَيْناً قَدْ عَلِمَ كُلُّ أُنَاسٍ﴾ كُلُّ قَبِيلَةٍ مِنْ بَنِي أَبٍ مِنْ أَوْلاَدِ يَعْقُوبَ ﴿مَشْرَبَهُمْ﴾ فَلاَ يُزَاحِمُ اْلآخَرِينَ فِي مَشْرَبِهِمْ.

អល់ឡោះហ្ស៊ីវ៉ាបានបើកឲ្យព្រះអង្គ អ.ស.ម ដឹងថា៖ "មូសា អ.ស.ម អើយ ! *អ្នកចូរវាយផ្ទាំងសិលាដោយដំបងអ្នកទៅ ។* ព្រះអង្គ អ.ស.ម បានវាយវាដោយដំបង *ដប់ពីរប្រភពទឹកបាញ់ចេញមកពីផ្ទាំងសិលានោះ ។ ប្រជាជាតិនីមួយៗដឹង* កុលសម្ព័ន្ធនីមួយៗដែលជាកូនចៅរបស់ឪពុកមួយដែលជាកូនម្នាក់របស់យ៉ាកុ៊ប អ.ស.ម *ទឹកនៃកន្លែងផឹករបស់ខ្លួន ។* មិនដណ្តើមកន្លែងគ្នាផឹកទឹកទេ ។

قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿كُلُوا وَ اِشْرَبُوا مِنْ رِزْقِ اَللهِ﴾ اَلَّذِي آتَاكُمُوهُ ﴿وَ لاَ تَعْثَوْا فِي اَلْأَرْضِ مُفْسِدِينَ﴾ وَ لاَ تَسْعَوْا فِيهَا وَ أَنْتُمْ مُفْسِدُونَ عَاصُونَ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 261)

អល់ឡោះហ្ស៊ីវ៉ាមានព្រះរាជបន្ទូលថា *ពួកអ្នកចូរបរិភោគនិងផឹកនូវគ្រឿងទ្រទ្រង់ជីវិតរបស់អល់ឡោះហ្ស៊ីចុះ* ដែលព្រះអង្គ ﷻ បានប្រទានឲ្យពួកអ្នក *ពួកអ្នកចូរកុំបង្កវិនាសនៅលើផែនដីដោយបង្ករអន្តរាយ ។* ចូរកុំដើរនៅលើផែនដីដោយបង្កឲ្យមានការខូចបង់ ដោយល្មើសបង្គាប់ ។

(التفسير المنسوب إلى الإمام العسكري عليه السلام 1: 261) 7:160-162

وَإِذْ قُلْتُمْ يَـٰمُوسَىٰ لَن نَّصْبِرَ عَلَىٰ طَعَامٍ وَٰحِدٍ فَٱدْعُ لَنَا رَبَّكَ يُخْرِجْ لَنَا مِمَّا تُنۢبِتُ ٱلْأَرْضُ مِنۢ بَقْلِهَا وَقِثَّآئِهَا وَفُومِهَا وَعَدَسِهَا وَبَصَلِهَا ۖ قَالَ أَتَسْتَبْدِلُونَ ٱلَّذِى هُوَ أَدْنَىٰ بِٱلَّذِى هُوَ خَيْرٌ ۚ ٱهْبِطُوا۟ مِصْرًا فَإِنَّ لَكُم مَّا سَأَلْتُمْ ۗ وَضُرِبَتْ عَلَيْهِمُ ٱلذِّلَّةُ وَٱلْمَسْكَنَةُ وَبَآءُو بِغَضَبٍ مِّنَ ٱللَّهِ ۗ ذَٰلِكَ بِأَنَّهُمْ كَانُوا۟ يَكْفُرُونَ بِـَٔايَـٰتِ ٱللَّهِ وَيَقْتُلُونَ ٱلنَّبِيِّـۧنَ بِغَيْرِ ٱلْحَقِّ ۗ ذَٰلِكَ بِمَا عَصَوا۟ وَّكَانُوا۟ يَعْتَدُونَ ﴿٦١﴾

៦១. [ចូរនឹកឃើញ]កាលពួកអ្នកថា៖ "មូសាអើយ ! យើងមិនអាចអត់ទ្រាំនឹងអាហារតែមួយ[មុខ]បានទេ ។ សូមលោកជួយសូមម្ចាស់លោកឲ្យយើងផង ឲ្យព្រះអង្គប្រទានឲ្យយើងនូវអ្វីដែលផែនដីបណ្តុះចេញមក [ដូចជា៖] តិណទេស ត្រសក់ ខ្ទឹមស សណ្តែកសំប៉ែត ខ្ទឹមបារាំង ។" គេបានថា៖ "អស់លោកនឹងយករបស់អាក្រក់មកដូរនឹងរបស់ល្អឬ ? អស់លោកចូរចូលទៅក្នុងស្រុកនីមួយទៅ អស់លោកនឹងបានអ្វីដែលអស់លោកសូមនោះ ។" សេចក្ដីអាម៉ាស់បានបាក់ស្រោចមកលើពួកគេ ព្រមទាំងទុគ្គតភាព ។ ពួកគេបានមកលើខ្លួនឯងវិញនូវព្រះពិរោធអល់ឡោះហ្ស៊ី ។ នេះព្រោះតែពួកគេបានបដិសេធបណ្តាព្រះសញ្ញារបស់អល់ឡោះហ្ស៊ី បានសម្លាប់បណ្តាព្រះសាស្តាដោយគ្មានសិទ្ធិ ។ នេះព្រោះតែពួកគេបានប្រព្រឹត្តល្មើស បានប្រព្រឹត្តបំពានច្បាប់ ។

អធិប្បាយអាយ៉ាស់ ៦១

1/61. ثُمَّ قَالَ اَللَّهُ عَزَّ وَ جَلَّ: ﴿وَ إِذْ قُلْتُمْ يَا مُوسىٰ لَنْ نَصْبِرَ عَلىٰ طَعَامٍ وَاحِدٍ﴾ وَ اُذْكُرُوا إِذْ قَالَ أَسْلاَفُكُمْ: لَنْ نَصْبِرَ عَلَى طَعَامٍ وَاحِدٍ: اَلْمَنِّ وَ اَلسَّلْوَى، وَ لاَ بُدَّ لَنَا مِنْ خَلْطٍ مَعَهُ. ﴿فَادْعُ لَنَا رَبَّكَ يُخْرِجْ لَنَا مِمَّا تُنْبِتُ اَلْأَرْضُ مِنْ بَقْلِهَا وَ قِثَّائِهَا وَ فُومِهَا وَ عَدَسِهَا وَ بَصَلِهَا﴾. قَالَ مُوسَى ﴿أَ تَسْتَبْدِلُونَ اَلَّذِي هُوَ أَدْنىٰ بِالَّذِي هُوَ خَيْرٌ﴾ يُرِيدُ: أَ تَسْتَدْعُونَ اَلْأَدْنَى لِيَكُونَ لَكُمْ بَدَلاً مِنَ اَلْأَفْضَلِ؟ ثُمَّ قَالَ: ﴿اِهْبِطُوا مِصْراً﴾ [مِنَ اَلْأَمْصَارِ] مِنْ هَذَا اَلتِّيهِ ﴿فَإِنَّ لَكُمْ مَا سَأَلْتُمْ﴾ فِي اَلْمِصْرِ.

៦១/១. បន្ទាប់មកអល់ឡោះហ្ស៊ីវ៉ាមានព្រះរាជបន្ទូលថា៖ *[២:៦១] កាលពួកអ្នកថា៖ "មូសាអើយ ! យើង*

មិនអាចអត់ទ្រាំនឹងអាហារតែមួយ[មុខ]បានទេ ។ ចូរពួកអ្នកនឹកឃើញកាលដូនតាពួកអ្នកបានថា៖ "យើងមិនអាចទ្រំនឹងអាហារតែមួយមុខបានដាច់ខាត គឺ អាល់-ម៉ាន និង អាល់-សាល់វ៉ា យើងចៀសមិនផុតពីលាយផ្សំអ្វីផ្សេងជាមួយអាហារនេះទេ ។ *សូមលោកជួយសូមម្ចាស់លោកឲ្យយើងផង ឲ្យព្រះអង្គប្រទានឲ្យយើងនូវអ្វីដែលផែនដីបណ្តុះចេញមក [ដូចជា៖] តិណាទេស ត្រសក់ ខ្ទឹមស សណ្តែកសំបែ័ត ខ្ទឹមបារ៉ាង ។* មូសាﷺបានថា៖ *"អស់លោកនឹងដូវរបស់ល្អបំផុតជាមួយរបស់អប្រិយជាងនោះឬ ?"* មូសាﷺមានវចន:ថា៖ *"អស់លោកនឹងយករបស់អាក្រក់មកដូវនឹងរបស់ល្អឬ ?"* ព្រះអង្គﷺចង់និយាយថា "អស់លោកអ្វីដែលអន់ជាជំនួសអ្វីដែលល្អប្រសើរសម្រាប់អស់លោក ?" បន្ទាប់មកព្រះអង្គﷻមានព្រះរាជបន្ទូលថា៖ *អស់លោកចូរចូលទៅក្នុងស្រុកនីមួយទៅ* ក្នុងចំណោមស្រុកឯទៀតដែលនៅឆ្ងាយពីទីរហោឋានេះ *អស់លោកនឹងបានអ្វីដែលអស់លោកសូមនោះ* នៅក្នុងស្រុក ។

ثُمَّ قَالَ اَللّٰهُ عَزَّ وَ جَلَّ: ﴿وَ ضُرِبَتْ عَلَيْهِمُ اَلذِّلَّةُ﴾ اَلْجِزْيَةُ أُخْزُوا بِهَا عِنْدَ رَبِّهِمْ وَ عِنْدَ مُؤْمِنِي عِبَادِهِ، ﴿وَ اَلْمَسْكَنَةُ﴾ هِيَ اَلْفَقْرُ وَ اَلذِّلَّةُ ﴿وَ بَاؤُ بِغَضَبٍ مِنَ اَللّٰهِ﴾ اِحْتَمَلُوا اَلْغَضَبَ وَ اَللَّعْنَةَ مِنَ اَللّٰهِ ﴿ذٰلِكَ بِأَنَّهُمْ كَانُوا﴾ بِذَلِكَ اَلَّذِي لَحِقَهُمْ مِنَ اَلذِّلَّةِ وَ اَلْمَسْكَنَةِ وَ اِحْتَمَلُوهُ مِنْ غَضَبِ اَللّٰهِ، ذَلِكَ بِأَنَّهُمْ كَانُوا ﴿يَكْفُرُونَ بِآيَاتِ اَللّٰهِ﴾ قَبْلَ أَنْ تُضْرَبَ عَلَيْهِمْ هَذِهِ اَلذِّلَّةُ وَ اَلْمَسْكَنَةُ

បន្ទាប់មកអល់ឡោះហ្គ៌ﷻមានព្រះរាជបន្ទូលថា៖ *សេចក្ដីអាម៉ាស់បានបាក់ស្រោចមកលើពួកគេ* អ្វីដែលពួកគេត្រូវបង់ឲ្យទៅម្ចាស់ﷻ ពួកគេត្រូវបង់ឲ្យទៅបណ្ដាបាវបម្រើរបស់ព្រះអង្គﷻដែលមានសទ្ធាជ្រះថ្លា ។ *ទុគ្គតភាព* នេះគឺសេចក្ដីក្រីក្រនិងសេចក្ដីអាម៉ាស់ ។ *ពួកគេបានមកលើខ្លួនឯងវិញនូវព្រះពិរោធអល់ឡោះហ្ន៌* ព្រះកំហឹងនិងព្រះបណ្ដាសាមកពីអល់ឡោះហ្ន៌ﷻធ្លាក់មកលើខ្លួនពួកគេ ។ *នេះព្រោះតែ* មូលហេតុដែលពួកគេរងសេចក្ដីអាម៉ាស់ រងសេចក្ដីក្រីក្រ និងរងព្រះពិរោធអល់ឡោះហ្ន៌ﷻនោះព្រោះតែ *ពួកគេបានបដិសេធបណ្ដាព្រះសញ្ញារបស់អល់ឡោះហ្ន៌* មុនពួកគេត្រូវរងសេចក្ដីអាម៉ាស់និងសេចក្ដីក្រីក្រនេះ

﴿وَ يَقْتُلُونَ اَلنَّبِيِّينَ بِغَيْرِ اَلْحَقِّ﴾ وَ كَانُوا يَقْتُلُونَهُمْ بِغَيْرِ حَقٍّ بِلاَ جُرْمٍ كَانَ مِنْهُمْ إِلَيْهِمْ وَ لاَ إِلَى غَيْرِهِمْ ﴿ذٰلِكَ بِمَا عَصَوْا﴾ ذَلِكَ اَلْخِذْلاَنُ اَلَّذِي اِسْتَوْلَى عَلَيْهِمْ - حَتَّى فَعَلُوا اَلْآثَامَ - اَلَّتِي مِنْ أَجْلِهَا ﴿ضُرِبَتْ عَلَيْهِمُ اَلذِّلَّةُ وَ اَلْمَسْكَنَةُ، وَ بَاؤُ بِغَضَبٍ مِنَ اَللّٰهِ﴾ [بِمَا عَصَوْا] ﴿وَ كَانُوا يَعْتَدُونَ﴾ [أَيْ] يَتَجَاوَزُونَ أَمْرَ اَللّٰهِ إِلَى أَمْرِ إِبْلِيسَ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 263)

បានសម្លាប់បណ្ដាព្រះសាស្ដាដោយគ្មានសិទ្ធិ ពួកគេសម្លាប់ពួកគេﷺទោះបីពួកគេﷺមិនបានប្រព្រឹត្តខុសលើពួកគេ ឬលើអ្នកណាមួយទេក៏ដោយ ។ *នេះព្រោះតែពួកគេបានប្រព្រឹត្តល្មើស* នេះដោយសារតែពួកគេបារម្ភអំពីការបោះបង់ចោលបានជាពួកគេប្រព្រឹត្តបាបទាំងនោះ បណ្ដាលឲ្យរងសេចក្ដីអាម៉ាស់ សេចក្ដីក្រីក្រនិងព្រះពិរោធអល់ឡោះហ្ន៌ﷻ ដោយសារតែពួកគេប្រព្រឹត្តល្មើស *បានប្រព្រឹត្តបំពានច្បាប់* មានន័យថាពួកគេប្រព្រឹត្តកន្លងព្រះបញ្ជាអល់ឡោះហ្ន៌ﷻ ក្រោមការណែនាំរបស់អ៊ីប្លីស﷿ ។

(التفسير المنسوب إلى الإمام العسكري عليه السلام 1: 263)

***

2/61. مُحَمَّدُ بْنُ يَعْقُوبَ: بِإِسْنَادِهِ، يُونُسُ، عَنِ ابْنِ سِنَانٍ، عَنْ إِسْحَاقَ بْنِ عَمَّارٍ، عَنْ أَبِي عَبْدِ اللَّهِ (عليه السلام)، وَ تَلَا هَذِهِ الْآيَةَ: ﴿ذٰلِكَ بِأَنَّهُمْ كانُوا يَكْفُرُونَ بِآياتِ اللَّهِ وَ يَقْتُلُونَ النَّبِيِّينَ بِغَيْرِ الْحَقِّ ذٰلِكَ بِما عَصَوْا وَ كانُوا يَعْتَدُونَ﴾. قَالَ: وَ اللَّهِ، مَا قَتَلُوهُمْ بِأَيْدِيهِمْ، وَ لَا ضَرَبُوهُمْ بِأَسْيَافِهِمْ، وَ لَكِنَّهُمْ سَمِعُوا أَحَادِيثَهُمْ فَأَذَاعُوهَا، فَأُخِذُوا عَلَيْهَا، فَقُتِلُوا، فَصَارَ قَتْلًا وَ اعْتِدَاءً وَ مَعْصِيَةً». (البرهان في تفسير القرآن – الجزء: ١ الصفحة: ٢٢٩ الحديث: ٩٩/ ٤٩٤، الكافي – الجزء: ٢ الصفحة: ٢٧٥ الحديث : ٦)**



៦១/២. ម្ហ៊ូ៉ាំម៉ាដ្ទ ប៊ិន យ៉ាកុ៉ាប ១ បានរ៉ាយការណ៍ យោលតាមបណ្តាញព័ត៌មានលោក តមកពី យូនុស តមកពី អ៊ីបនូ ស៊ីណាន តមកពី អ៊ីសហ្ហាក ប៊ិន អ៊ុ៉ាម៉ារ តមកពី អាប៊ូ អ៊ុ៉ាប់ឌុលឡោះហ្ហ៑ صلوات الله عليه والسلام បានសួត្រ អាយ៉ាស៊ុ០នេះ *[២:៦១] នេះព្រោះតែពួកគេបានបដិសេធបណ្តាព្រះសញ្ញារបស់អល់ឡោះហ្ហ៑ បានសម្លាប់បណ្តាព្រះសាស្តាដោយគ្មានសិទ្ធិ ។ នេះព្រោះតែពួកគេបានប្រព្រឹត្តល្មើស បានប្រព្រឹត្តបំពានច្បាប់ ។* ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "សូមស្បថនឹងអល់ឡោះហ្ហ៑ عز وجل ! ពួកគេមិនបានសម្លាប់ព្រះសាស្តា عليهم السلام ដោយដៃពួកគេទេ មិនបានប្រហារអស់ព្រះអង្គ عليهم السلام ដោយដាវពួកគេនោះទេ តែពួកគេបានឮបណ្តាហ្ការ៉ីស្ស (សម្ពី) របស់អស់ព្រះអង្គ عليهم السلام ហើយបានបើកឲ្យគេដឹងហ្ការ៉ីស្សទាំងនេះ បណ្តាលឲ្យគេប្រទូសប្រឆាំងអស់ព្រះអង្គ عليهم السلام ហើយត្រូវគេសម្លាប់ ។ អាស្រ័យហេតុដូច្នេះ ពួកគេក្លាយទៅជាអ្នកសម្លាប់ ជាអ្នកប្រព្រឹត្តល្មើស ជាអ្នកប្រព្រឹត្តបំពានច្បាប់ ។" (الكافي 2: 275/ 6)

ពាក្យរាយ

-ខ្ញុំ ﷺ ជាបាវម្នាក់របស់អល់ឡោះហ្ស៊ីﷻ ឈ្មោះខ្ញុំ ﷺ គឺអ៊ីសរ៉អ៊ីល ﷺ -> [២:៤៧]..... ១២០
-អ៊ីបនូ អ៊ុប់បាស់ សច្ចាទទួលស្គាល់ អាប៊ូ បាការ -> [២:១៧-២០] ៤៤
-អ្ហមដ ធ្វើសាក្សីឲ្យមូហ្ហាំម៉ាដ្ស៊ុ ﷺ និងអ៊ីសា ﷺ -> [២:១] ១២
-អត្ថន័យរបស់ អ៊ីសរ៉អ៊ីល [២:៤០, ២៦:១០-២២] ។..... ១០៩
-អត្ថន័យរបស់ អាលិហ្ម ឡ្យ៉ាំ មីម -> [២:១]..... ៦
-មេឃទាំង ៧ ជាន់ -> [២:២៩] ៧១
-លក្ខណៈវិនិច្ឆ័យគឺ វីឡ្យ៉ាយ៉ាស្ស៊ុ -> ២:៥៣ ។..... ១៣២
-មូលហេតុរបស់ តាវ៉ាហ្ស ៧ ជុំ -> [២:៣០-៣៣] ៧៥
-ប្រជានិករនានារបស់ឋានលោកនេះ -> [២:៣០-៣៣] ៧៨
-ប្រវត្តិរបស់អ៊ីប្លីស ﷺ -> [២:៣៤]..... ៨៥
-ព្រះគម្ពីរ គឺអ៊ីសា ﷺ-> [២:២]..... ១៤
-សំលៀកបំពាក់ពួកយ៉ាហ្ស៊ូ ឌ្ស៊ីធ្វើសាក្សីឲ្យមូហ្ហាំម៉ាដ្ស៊ុ ﷺ និងអ៊ីសា ﷺ -> [២:១]..... ១២
-អាល់-ម៉ាន [២:៥៧]..... ១៤១
-អាល់-អ៊ុច្ច៉ាស្ស៊ុ ផ្លែលម៉ើមកពីឋានសួគ៌ ជាថ្នាំបន្សាបថ្នាំបំពុល [២:៥៧] ១៤១
-អាយ៉ាស្ស៊ុការពារខ្លួន គ្រួសារ និងទ្រព្យ -> [០/១]..... ៣
-អាយ៉ាស្ស៊ុត្រូវកាត់ចោល [២:៥៩] ១៤៥
-អាយ៉ាស្ស៊ុត្រូវកាត់ចោល -> [២:២៣]..... ៥៦